ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ មណ្ឌលទទួលពលករកំរៀង

របាយការណ៍បូកសរុបលទ្ធផល
ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២១
និងទិសដៅអនុវត្ត ឆ្នាំ ២០២២

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ន.ជ.ប.ជ

សារលិខិតផ្តែចអំណរគុណ

សូមគោរព សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំស្ថាប័នកំពូលឬបស់ជាតិ!

ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រី រាជការ គ្រប់ក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរអង្គភាពគ្រប់វិស័យ ស្ថានបេសកកម្ម និងស្ថានតំណាងកម្ពុជានៅក្រៅប្រទេស!

លោក លោកស្រី បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ!

កងកម្លាំងសមត្ថកិច្ចគ្រប់ប្រភេទ ទាំងនៅក្នុងប្រទេស និងនៅឈរជើងតាមតំបន់ព្រំដែន!

ដៃគូពាក់ព័ន្ធ ជាទីភ្នាក់ងារអង្គការសហប្រជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល!

លោក លោកស្រីក្នុងវិស័យឯកជន យុវជន យុវនារី និងបងប្អូនជនរួមជាតិទាំងអស់ ជាទីស្រឡាញ់រាប់អាន!

ពីរឆ្នាំកន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសនានានៅក្នុងតំបន់ និងលើពិភពលោក ពិតជាទទួលរងនូវឥទ្ធិពលនៃភាពប្រឈមជាសាកល ទៅលើវិស័យសេដ្ឋកិច្ច សង្គម និងនយោបាយយ៉ាងធ្ងន់ធ្ងរ ។ ឧបទ្ទវហេតុផ្លួនៗ ដែលកើតឡើង រួមមានគ្រោះធម្មជាតិធ្ងន់ធ្ងរ ការឆ្លងរាលដាលជម្ងឺកូវីដ ១៩ លើសពីនេះទៅទៀត ភាពវឹកវរ អសន្តិសុខ និងចម្បាំងរាំងជល់ដែលបានផ្ទុះឡើងរវាងប្រទេសមួយចំនួន បានជះឥទ្ធិពលដល់សុវត្ថិភាព សន្តិសុខ សុខភាព ជីវភាព និងជីវិតមនុស្សរាប់រយលាននាក់ លើពិភពលោក ។

ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** រាជរដ្ឋាភិបាលបានដាក់ចេញនូវគ្រប់វិធានការ មានជាអាទិ៍ វិធានការដោះស្រាយបញ្ហាខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងកាលៈទេសៈដ៏លំបាក វិធានការបង្ការទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ ១៩ តាមរយៈការផ្តល់ការអប់រំផ្សព្វផ្សាយ ការរៀបចំមណ្ឌលចត្តាឡីស័ក មណ្ឌលព្យាបាល និងការស្វែងរកវ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋឲ្យបានគ្រប់ និងលើសពីផែនការ លើសពីនេះទៅទៀត គឺវិធានការ ទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់រូបភាព ជាពិសេសអំពើជួញដូរមនុស្ស ដែលជនឆ្លៀតឱកាសព្យាយាមបោកបញ្ឆោត អូសទាញ នាំមនុស្សឆ្លងដែនខុសច្បាប់ដើម្បីកេងប្រវ័ញ្ចជាដើម ។ វិធានការទាំងនេះទទួលបានលទ្ធផលល្អប្រសើរ ដោយធ្វើឲ្យអត្រានៃការឆ្លង និងស្លាប់ដោយកូវីដ ១៩ បានថយចុះគួរឲ្យមោទនៈ និងធ្វើឲ្យស្ថានភាពសេដ្ឋកិច្ច និងសង្គមវិលមកមានប្រក្រតីភាពតាមគន្លងថ្មី ដែលប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់អបអរសាទរ និងទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ។

ក្នុងដំណាក់កាលនេះដែរ ពលករទេសន្តរប្រវេសន៍ដែលទៅធ្វើការនៅក្រៅប្រទេស ជាពិសេសនៅក្នុងប្រទេសថៃ បានវិលត្រឡប់មកវិញប្រមាណជិត ១៥ម៉ឺននាក់ក្នុងមួយឆ្នាំ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការទទួល សង្គ្រោះ ផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជន និងសហគមន៍ ។ ដៃម្ខាងរួមគ្នាបង្ការទប់ស្កាត់ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ ដៃម្ខាងទៀតការដោះស្រាយភាពប្រឈម និងជីវភាពប្រជាពលរដ្ឋ ក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលក្នុងនោះ ទាំងរាជរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជនបានចូលរួមលះបង់ខ្ពស់ប្រកបដោយស្មារតីមនុស្សធម៌ ។ ទន្ទឹមនឹងនោះ មេខ្យល់បានឆ្លៀតឱកាសចលនាអូសទាញពលករឲ្យចេញទៅប្រទេសក្រៅវិញ ក្នុងស្ថានភាពកំពុងប្រឈមខ្លាំងធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស និងរបិតកូវីដ ១៩ ។

ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងសូមកោតសរសើរដោយស្មោះ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃគ្រប់ក្រសួងស្ថាប័ន ដែលជាសមាជិករបស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យន្តការថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល និងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅគ្រប់ប្រទេសពាក់ព័ន្ធ ដែលបានរួមសហការគ្នា ប្រកបដោយការទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ មានសាមគ្គីភាពឯកភាពគ្នាជាធ្លុងមួយ ស្រុះស្រៃដៃគ្នាដោះស្រាយបញ្ហាប្រឈមដើម្បីផ្តល់កិច្ចការពារប្រជាពលរដ្ឋដែលរងគ្រោះ និងងាយរងគ្រោះនៅគ្រប់ស្ថានភាព គ្រប់ទីតាំង ទាំងនៅតាមបណ្តោយព្រំដែន និងនៅផ្ទៃក្នុងប្រទេស យ៉ាងម៉ត់ចត់ ដោយគ្មានការធ្វេសប្រហែស រហូតអាចគ្រប់គ្រងស្ថានភាពបានយ៉ាងល្អប្រសើរ ។ ខ្ញុំក៏សូមកោតសរសើរ និងវាយតម្លៃខ្ពស់ផងដែរ ចំពោះសមត្ថកិច្ចយើងគ្រប់ផ្នែក ដែលបានសហការគ្នាទប់ស្កាត់ និងបង្ក្រាបសកម្មភាពទាំងនោះបានជាបន្តបន្ទាប់ និងនៅតែបន្តតាមដានស្វែងរកមេខ្យល់ និងមេខ្លោងដើម្បីផ្តន្ទាទោសតាមច្បាប់ដោយមិនមានការអត់ឱនឲ្យឡើយ ។

ជាទីបញ្ចប់នេះ ខ្ញុំសូមបួងសួងដល់ព្រះរតនត្រ័យ បារមីវត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយបីបាច់រក្សា ព្រះរាជាណាចក្រកម្ពុជាដ៏អច្ឆរិយៈ ឲ្យមានក្តីសុខក្សេមក្សាន្ត សម្បូរសប្បាយជារៀងរហូត ។ សូមករុណាព្រះមហាក្សត្រ និងព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈ មានព្រះជន្មាយុយឺនយូរ ព្រះសុខភាពល្អគង់ជាម្លប់ដ៏ត្រជាក់នៃកូនចៅយូរអង្វែងតរៀងទៅ ។ សូមថ្វាយព្រះពរ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គមានព្រះសុខភាពល្អបរិបូណ៌ គោរពជូនពរសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការ កងកម្លាំង និងប្រជាពលរដ្ឋគ្រប់រូប សូមមានសិរីសួស្តី ជ័យមង្គលវិបុលសុខ គ្រប់ប្រការ និងសុខភាពមាំមួនជៀសផុតរោគា និងទទួលបានជោគជ័យគ្រប់ការកិច្ច កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ សុក្រ ១៥ កើត ខែ ស្រាពណ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២២

ប្រធាន គ.ជ.ប.ជ

សម្តេចក្រឡាហោម ស ខេង

មាតិកា

I. ស្ថានភាពទូទៅ ១
II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២
ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ២
ក.១. ការកសាងច្បាប់ ២
ក.២. គោនយោបាយ និងអនុស្សរណៈនៃការយោគយល់ ២
ក.៣. លិខិតបទដ្ឋានគតិយុត្ត ២
ក.៤. ការពង្រឹងកិច្ចសហប្រតិបត្តិការ ៤
ខ. ការបង្ការ ទប់ស្កាត់ ៦
ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង ៦
ខ.២ .ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ ១៥
គ. ប្រព័ន្ធយុត្តិធម៌ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ២៤
គ. ការងារអនុវត្តច្បាប់ ២៤
គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ២៥
គ.១.២. ការបង្ក្រាបករណីនាំទារកឆ្លងដែនខុសច្បាប់ ២៦
គ.២. កិច្ចការយុត្តិធម៌ ២៦
ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ ២៨
ឃ.១. ការទទួល និងសម្គាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព ២៨
ឃ.១.១. ការទទួល និងសម្គាសន៍ពលករបញ្ជូនត្រឡប់ ២៨
ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់ ២៩
ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ២៩
ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ ២៩
III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល ៣០
ក. ការងារបណ្តុះបណ្តាល និងសិក្ខាសាលា ៣០
ក.១. ការងារបណ្តុះបណ្តាល ៣០

ក.២. សិក្ខាសាលា ៣២
ខ. សន្និសីទ កិច្ចប្រជុំ ជំនួបពិភាក្សាការងារ និងទស្សនៈកិច្ច ៣៤
ខ.១. សន្និសីទ ៣៤
ខ.២. កិច្ចប្រជុំក្នុងប្រទេស ៣៤
ខ.៣ .ជំនួបពិភាក្សាការងារ ៣៥
ខ.៤. ទស្សនៈកិច្ច ៣៧
គ .ការងារសម្របសម្រួល ៣៨
IV. ការសន្និដ្ឋានវាយតម្លៃ ៣៨
ក.ចំណុចខ្លាំង ៣៨
ខ .ចំណុចខ្វះខាត ឬភាពប្រឈម ៣៨
គ. សំណូមពរ ៣៩
ឃ .ការសន្និដ្ឋាន ៣៩
V. ទិសដៅ ឆ្នាំ ២០២២ ..... ៤០
ក.ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ ៤០
ខ.ការងារបង្ការ ទប់ស្កាត់ ៤០
គ.ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ៤២
ឃ.ការងារការពារជនរងគ្រោះ ៤២
ង.ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ ៤៣
- ឧបសម្ព័ន្ធ
- កម្រងរូបភាព

របាយការណ៍
ស្តីពី
ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០២១ និងទិសដៅអនុវត្ត ឆ្នាំ២០២២

I. ស្ថានភាពទូទៅ

រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុក ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាអាទិភាពខ្ពស់ បើទោះបីជាការរាតត្បាតនៃជម្ងឺកូវីដ ១៩ បានកើនឡើងខ្លាំង ព្រមទាំងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន ជួបគ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់...) ក្នុងឆ្នាំ២០២១នេះ ក៏ដោយ។ ទាំងនៅតាមបណ្តាក្រសួងស្ថាប័ន ទាំងនៅថ្នាក់ក្រោមជាតិ រហូតដល់នៅតាមខ្សែបណ្តោយព្រំដែន មន្ត្រីគ្រប់លំដាប់ថ្នាក់ បានបង្កើនការយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវ និងបង្ក្រាបអំពើជួញដូរមនុស្ស ដែលជ្រកក្រោមរូបភាពផ្សេងៗ បង្កើតឡើងដោយឧក្រិដ្ឋជន និងបណ្តាញរបស់ខ្លួន ។

ស្ថានភាពប្រែប្រួល ចាប់ផ្តើមពីខែមករា ឆ្នាំ២០២១ និងព្រឹត្តិការណ៍នៃការឆ្លងរាលដាល កូវីដ ១៩ ទៅក្នុងសហគមន៍ ថ្ងៃ ២០កុម្ភៈ ឆ្នាំ២០២១ បានធ្វើឲ្យរបៀបរបបការងាររបស់ក្រសួងស្ថាប័ន និងរាជធានីខេត្ត ត្រូវផ្លាស់ប្តូរតាមបែបគន្លងថ្មី ពោលគឺត្រូវបង្កើនសកម្មភាពអប់រំ ប្រជុំពិភាក្សា បណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញ ដើម្បីបញ្ចៀសហានិភ័យពីកូវីដ ១៩ និងផ្តោតលើផលប៉ះពាល់ដ៏ធំធេងលើជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ដែលជាភាពប្រឈមថ្មី ។

រាជរដ្ឋាភិបាល បានបង្កើនថវិកាសម្រាប់វិស័យសង្គមកិច្ច ដើម្បីទ្រទ្រង់ជីវភាពកម្មករដែលបាត់បង់ការងារ ប្រជាពលរដ្ឋក្រីក្រ ពលករដែលវិលត្រឡប់ក្នុងអំឡុងពេលនៃការបិទខ្ទប់ក្នុងប្រទេសគោលដៅ ដែលមានចំនួនច្រើនលើសលប់ រហូតដល់ ១៤០.៦៦៤នាក់ ក្នុងនោះមានស្ត្រី ៦២.២៩៤នាក់ និងភាគច្រើនជាអ្នកដែលខ្វះលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពពេលត្រឡប់មកវិញ ហើយងាយរងគ្រោះ។ នេះជាការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហារបស់រាជរដ្ឋាភិបាល ដើម្បីបង្ការទប់ស្កាត់ភាពរងគ្រោះរបស់ប្រជាពលរដ្ឋពីហានិភ័យដោយអំពើជួញដូរមនុស្ស ដែលជនឆ្លៀតឱកាសកេងប្រវ័ញ្ចក្នុងពេលដែលជនងាយរងគ្រោះប្រឈមនឹងភាពខ្វះខាត ហើយប្រថុយប្រថានឹងគ្រោះថ្នាក់។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានបង្កើនសកម្មភាព ទប់ស្កាត់សកម្មភាពមេខ្យល់ក្នុងការចលនាអូសទាញឱ្យពលករឆ្លងដែនខុសច្បាប់ និងត្រូវប្រឈមនឹងជម្ងឺរាតត្បាតដែលកំពុងមានសន្ទុះកើនឡើង ក្នុងប្រទេសគោលដៅ ដែលចាំបាច់ត្រូវរឹតបន្តឹង ។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ រួមគ្នាអនុវត្តសកម្មភាពយ៉ាងមមាញឹក ទាំងនៅតាមព្រំដែនដើម្បីទទួល និងសង្គ្រោះពលករដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅដើម្បីកំណត់រកអ្នកសង្ស័យផ្ទុកកូវីដ ១៩ ការបញ្ជូនទៅមណ្ឌលចត្តាឡីស័ក និងការតាមដាន និងថែទាំសុខភាព ការឧបត្ថម្ភម្ហូបអាហារ សម្ភារៈប្រើប្រាស់ ការជិតជូនទៅលំនៅដ្ឋានតាមបណ្តាខេត្ត និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព ព្រមទាំងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងឧបត្ថម្ភដីកោរ នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។

ជាលទ្ធផលដែលទទួលបានក្នុងឆ្នាំ២០២១ មានដូចខាងក្រោម៖

II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បាន៖
  - ចុះសន្ធិសញ្ញា ស្តីពី «ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយកូរ៉េខាងត្បូង និងជាមួយសហព័ន្ធរុស្ស៊ី។
  - ចុះសន្ធិសញ្ញាស្តីពី បត្យាប័ន ជាមួយប្រទេសបារាំង។
  - បន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»។
  - រៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៊ែលហ្សិក ប៉េរូ និងប្រទេសឡាវ ស្តីពី «ការបញ្ជូនទណ្ឌិត»។
  - រៀបចំសន្ធិសញ្ញា ស្តីពី បត្យាប័ន ជាមួយប្រទេសឥណ្ឌា និងប្រទេសបេឡារូស។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖
  - បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។
  - ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពី«កិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា»។

ក.២. គោនយោបាយ និងអនុស្សរណៈនៃការយោគយល់

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** បាន៖
  - ចុះអនុស្សរណៈយោគយល់ជាមួយ អង្គការវើរើលអនលូស (We World Onlus) ស្តីពី «ការលើកកម្ពស់ និងការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍កម្ពុជាដែលមានជំនាញទាប»។
  - ចុះកិច្ចព្រមព្រៀងជាមួយ អង្គការមូលនិធិអន្តរជាតិហាការ (HAGAR) ស្តីពី «ការផ្លាស់ប្តូរឥរិយាបថបុគ្គល និងសហគមន៍ ដើម្បីលើកកម្ពស់សុវត្ថិភាពជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស»។
  - ប្រជុំសមាជិកគណៈកម្មាធិការ និងមន្ត្រីជំនាញពីតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូជាតិ និងអន្តរជាតិ តាមប្រព័ន្ធអនឡាញ ស្តីពី «ការពិនិត្យឡើងវិញនូវ លទ្ធផលការងារ ភាពប្រឈម» (២០១៩-២០២១) និងគំនិតផ្តួចផ្តើមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របន្ត(២០២២-២០២៣)។
  - សហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ(Winrock International) ជួលអ្នកជំនាញវាយតម្លៃពីខាងក្រៅ ដើម្បីធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ(២០១៩-២០២៣)។
  - រៀបចំកិច្ចប្រជុំជាច្រើនលើក តាមប្រព័ន្ធអនឡាញ ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកការងារទេសន្តរប្រវេសន៍ នៅទីក្រុងហ្សឺណែវ បណ្តាញអង្គការទេសន្តរប្រវេសន៍របស់អង្គការសហប្រជាជាតិប្រចាំតំបន់ អគ្គលេខាធិការដ្ឋានអាស៊ាន និងជាមួយអន្តរក្រសួង ស្ថាប័ន ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមជាប្រទេសជ័យលាភីក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។
- **ក្រសួងទេសចរណ៍** បានរៀបចំ និងត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពី ការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

ក.៣. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងមហាផ្ទៃ** បានចេញសេចក្តីជូនដំណឹងទៅអភិបាលខេត្តជាប់ព្រំដែន លេខ១៣៩៦ សជណ ស្តីពី «ការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ កុំឱ្យឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសជិតខាងតាមច្រករបៀងនានា» និងវិធានការជាបន្តបន្ទាប់ដើម្បីពង្រឹងការគ្រប់គ្រងច្រកព្រំដែន និងដាក់បញ្ជូនទៅថ្នាក់ក្រោមជាតិ

ក្នុងការតាមដាន ស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ដែលព្យាយាមនាំពលករចេញទៅប្រទេសថៃ ក្នុងដំណាក់កាលរឹតបន្តឹង ដើម្បីបង្ការ ទប់ស្កាត់ ការរាតត្បាតដោយជំងឺកូវីដ-១៩។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - បង្កើតគណៈកម្មការប្រឹក្សាយោបល់ ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន (ប្រកាសអន្តរក្រសួងលេខ ០៨៦/២១ ក.ប/ប្រ.ក.ម.ហ ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១)។
  - បង្កើតក្រុមការងារចម្រុះ (សេចក្តីសម្រេចលេខ ៦៦ សសរ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១) ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់រវាង កម្ពុជា-ថៃ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ (៣០ តុលា ២០១៤)។
  - ចេញប្រកាសជូនដំណឹង ស្តីពី វិធានការថ្មីអំពីការបញ្ជូនស្ត្រីជំនួយការមេផ្ទះកម្ពុជា នៅប្រទេសសឹង្ហបុរី (១៦ កញ្ញា ២០២១) បង្កើត និងកែសម្រួលសមាសភាពលេខាធិការដ្ឋានក្រុមការងារទេសន្តរប្រវេសន៍ តាមរយៈប្រកាសលេខ ៣៩៨/២០ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០ និងក្រុមការងារអនុវត្តអនុស្សរណៈនៃការយោគយល់រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ។
- **ក្រសួងកិច្ចការនារី** បានរៀបចំ៖
  - សេចក្តីព្រាងវិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (COMMIT)។
  - សេចក្តីព្រាងយន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដារួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោលរបស់ប្រទេសជាសមាជិកឧមមីត (COMMIT) នីមួយៗ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បាន៖
  - ធ្វើសេចក្តីព្រាងអនុក្រឹត្យ ស្តីពី «របបគោលនយោបាយ សម្រាប់ជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ស្នាក់នៅក្នុងមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍»។
  - ប្រកាសផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ នីតិវិធីប្រតិបត្តិបទដ្ឋាន រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ (SOP) ស្តីពី «ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។
  - កែសម្រួលគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី «កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) គាំទ្រក្រសួងសុខាភិបាល និងជួយសម្របសម្រួលកិច្ចសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំនិងពិនិត្យសម្រេចលើគោលនយោបាយជាតិ ស្តីពី «សុខភាពជនទេសន្តរប្រវេសន៍» និងចុះសិក្សាតាមបណ្តាខេត្តជាប់ព្រំដែន ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយ រយៈពេល១០ឆ្នាំ (២០២១-២០៣០)។ ឯកសារទាំងពីរនេះ នឹងត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ២០២២។

- **ក្រសួងទេសចរណ៍** បាន៖
  - ដាក់ចេញនូវវិធានការរដ្ឋបាល ដោយធ្វើការផ្អាក និងដកហូតអាជ្ញាបណ្ណាទេសចរណ៍ចំពោះមូលដ្ឋានអាជីវកម្មទាំងឡាយណាដែលមិនគោរពតាមការណែនាំនានា និងច្បាប់ស្តីពីទេសចរណ៍ ដោយសហការជាមួយអាជ្ញាធរដែនដី រាជធានី ខេត្តទូទាំងប្រទេស។ ក្នុងនោះមានផ្ទះសំណាក់ សណ្ឋាគារ និងក្លឹបកម្សាន្តមួយចំនួនដែលបានអនុវត្តខុសច្បាប់ ត្រូវបង្ក្រាប និងបិទជាស្ថាពរ ទាក់ទងនឹងករណីសញ្ជោកម្ម

ដែលម្ចាស់អាជីវកម្ម និងមេការត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ដោយយោងតាមអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ(ឆ្នាំ២០០៩)។

- ចេញសេចក្តីប្រកាស សារាចរ សេចក្តីណែនាំមួយចំនួន ស្តីពី «ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍» ក្នុងនោះផ្តោតទៅលើការប្រើប្រាស់បន្ទប់ស្នាក់នៅរបស់អនីតិជនដែលគ្មានក្រុមគ្រួសារ ឬអាណាព្យាបាលស្របច្បាប់មកជាមួយ និង(មិនអនុញ្ញាតឱ្យអនីតិជន ប្រើប្រាស់បន្ទប់ស្នាក់នៅដោយគ្មានក្រុមគ្រួសារ ឬអាណាព្យាបាលស្របច្បាប់មកជាមួយ)។

▪ **គណៈកម្មាធិការខេត្ត(គ.ខ.ប.ជ)** ចំនួន ១៩ខេត្ត បានស្នើសុំកែសម្រួលរចនាសម្ព័ន្ធ ដោយយោងសេចក្តីសម្រេចលេខ ០២៦/១៥ស.ស.រ ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពី «ការតែងតាំងសមាសភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.រ.ប.ជ និង គ.ខ.ប.ជ)»។

▪ **ខេត្តព្រះសីហនុ៖** រដ្ឋបាលខេត្តបានចេញសេចក្តីជូនដំណឹង ស្តីពី «ការចាត់វិធានការរដ្ឋបាលនិងច្បាប់ចំពោះម្ចាស់សណ្ឋាគារ និងកាស៊ីណូដែលប្រើប្រាស់ហត្ថពលករដោយបង្ខំ» ដើម្បីដោះស្រាយ និងកាត់បន្ថយវិទេការងារជាពិសេសទប់ស្កាត់ការបំពេញការងារដោយបង្ខំ ឬជាកាតព្វកិច្ច ដែលអាចប្រឈមនឹងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោមរូបភាពរកការងារឱ្យធ្វើក្នុងទម្រង់កេងប្រវ័ញ្ចពលកម្ម។

ក.៤. ការពង្រឹងកិច្ចសហប្រតិបត្តិការ

▪ **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បាន៖

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ កម្រឹតថ្នាក់ដឹកនាំ ដើម្បីសម្រេចជ្រើសរើសគោលបំណងអាទិភាព និងសូចនាករសម្រាប់អភិបាលកិច្ចទេសន្តរប្រវេសន៍(Migration Governance Indicators) ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី «ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់» ។
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ០២លើក ស្តីពី "វឌ្ឍនភាព នៃការអនុវត្តអនុសាសន៍ប្រចាំឆ្នាំ របស់សហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា" រវាងមន្ត្រីជាន់ខ្ពស់ក្រសួងពាក់ព័ន្ធ ជាមួយឯកឧត្តមអគ្គរដ្ឋទូត វិសាមញ្ញ និងពេញសមត្ថភាព សហរដ្ឋអាមេរិក និងគណៈប្រតិភូអមស្ថានទូត និងបានជួបពិភាក្សាជាមួយ មន្ត្រីជំនាញជាច្រើនលើក។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ០២លើក រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** រហូតឈានដល់ការរៀបចំ និងអនុវត្តគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាលនៃការរាតត្បាតដោយជំងឺកូវីដ-១៩ នៅក្នុងខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ ក្រោមមូលនិធិ MPTF របស់អង្គការសហប្រជាជាតិ។
- ពិភាក្សាពិគ្រោះយោបល់ជាមួយ រាជធានី ខេត្ត អង្គការដៃគូជាតិ និងអន្តរជាតិជាច្រើនលើក ដើម្បីរកគន្លឹះដោះស្រាយបញ្ហាប្រឈម បន្ថែមលើគោលនយោបាយជាតិសម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស ចំពោះការវិលត្រឡប់របស់ពលករដ៏ច្រើន មិនតាមច្រកផ្លូវការ និងបន្តចូលដោយគ្មានពេលវេលា និងចំនួនកំណត់ ហើយប្រឈមនឹងស្ថានភាពសុខភាព និងជីវភាពយ៉ាងធ្ងន់ធ្ងរ។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន ៖

- បន្តពិភាក្សាការងារ ជាមួយក្រសួងការងារថៃ តាមប្រព័ន្ធអនឡាញ ដើម្បីរកគន្លឹះដោះស្រាយភាពប្រឈមរបស់ពលកម្មទេសន្តរប្រវេសន៍ ដែលកំពុងស្ថិតនៅក្នុងប្រទេសថៃ ក្នុងស្ថានភាពតឹងតែន និងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ-១៩។
- បន្តពង្រឹងការអនុវត្តអនុស្សរណៈនៃការយោគយល់ តាមរយៈកិច្ចប្រជុំទ្វេភាគីជាមួយប្រទេសថៃ និង ជប៉ុន ដើម្បីការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ព្រមទាំងរក្សាអត្ថប្រយោជន៍ផ្សេងៗរបស់ពលករ។

- រៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៦ នៃប្រទេស CLMTV (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម) ដើម្បីពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាងសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារ ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍នៃប្រទេស CLMTV ដែលត្រូវពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី៦ និងថ្នាក់មន្ត្រីការងារលើកទី៤ ដែលប្រទេសឡាវ នឹងធ្វើជាម្ចាស់ផ្ទះ។
- សហការរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីជាន់ខ្ពស់កម្ពុជា-ថៃ តាមប្រព័ន្ធវីដេអូ ជាមួយក្រសួងការងារថៃ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ និងកិច្ចព្រមព្រៀង ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ក្នុងអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១។
- បង្កើតក្រុមការងារអនុព័ន្ធការងារអមស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេស(ថៃចំនួន ០៣នាក់ កូរ៉ ០២នាក់ ជប៉ុន ០១នាក់ និងនៅប្រទេសម៉ាឡេស៊ី ០២នាក់)។
- អនុព័ន្ធការងារប្រចាំស្ថានទូតកម្ពុជានៅប្រទេសថៃ បានជួបប្រជុំជាមួយភាគីថៃ ស្តីពីការបន្តសុពលភាពលិខិតធ្វើដំណើររបស់ពលករកម្ពុជា នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

▪ **ក្រសួងកិច្ចការនារី** បាន៖

១-បន្តពិភាក្សាការអនុវត្តផែនការសកម្មភាពមហាអនុតំបន់មេគង្គ ស្តីពី «ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស» លើកទី៤ សម្រាប់ឆ្នាំ២០២០-២០២២(SPA-IV 2015-2018) ត្រូវបានបន្តសុពលភាពអនុវត្តលើកទី១(២០១៨-២០២០) និងត្រៀមរៀបចំផែនការសកម្មភាពនេះ លើកទី៥(SPA-V) ដែលត្រូវបញ្ចូលនិន្នាការថ្មីនៃអំពើជួញដូរមនុស្ស ព្រមទាំងមានការចូលរួមពីអង្គការសង្គមស៊ីវិល និងបណ្តាញយុវជន។

២-ពិនិត្យ និងកែសម្រួលលើសំណៅបកប្រែឯកសារជាភាសាអង់គ្លេស មកជាភាសាខ្មែរ របស់គណៈកម្មាការអាស៊ាន(ACWC) ស្តីពី គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ សម្រាប់ឆ្លើយតបចំពោះតម្រូវការនៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជាកញ្ចប់ឧបករណ៍គំរូអនុវត្ត សម្រាប់អ្នកអនុវត្តការងារគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ នៃគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)។

៣-**លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី** និង**ជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានដឹកនាំក្រុមការងារទាំង៦ នៃគ.ជ.ប.ជ រៀបចំកិច្ចប្រជុំជាមួយ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់កម្ពុជា លេខ២ ក្រោមបញ្ជីឃ្លាំមើល និងអនុសាសន៍ទាំង១៦ចំណុច នៅក្នុងរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ នៅទីស្តីការក្រសួងយុត្តិធម៌ ក្នុងគោលបំណងដើម្បីឆ្លើយតប និងធ្វើការបំភ្លឺនូវអនុសាសន៍ទាំង ១៦ ដែលអាមេរិកបានស្នើមកកម្ពុជា នៅក្នុងឆ្នាំ២០២១។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បាន៖

- សហការ និងទទួលការឧបត្ថម្ភថវិកា ដើម្បីសាងសង់មណ្ឌលទទួលពលករកំរៀង នៅព្រំដែនកម្ពុជា ថៃ ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។ អង្គការការីតាស់ស្វីស បានបន្តគាំទ្រសកម្មភាពមណ្ឌលយៈពេល ០៣ឆ្នាំ(២០២២-២០២៤)។
- សហការជាមួយ អង្គការអាស៊ានអាក់(ASEAN-ACT), A21 ហាការអន្តរជាតិ(HAGAR) វីនរ៉ក់អន្តរជាតិ (Winrock International)/USAID, ChildFund/educo ការីតាស់កម្ពុជា(CARITAS Cambodia) បោះពុម្ពសៀវភៅ របាយការណ៍ជាតិ ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងទិសដៅឆ្នាំ ២០២១ ចំនួន **១,000**ក្បាល។

- សហការជាមួយ អង្គការASEAN-ACT, A21, HAGAR, IJM ដើម្បីរៀបចំឯកសារបណ្តុះបណ្តាល និងប្រមូលទិន្នន័យជាព័ត៌មានត្រឡប់ អំពីសេចក្តីត្រូវការក្នុងការធ្វើបច្ចុប្បន្នភាព សៀវភៅគោលការណ៍ណែនាំ ស្តីពី «បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» និងបើកវគ្គបណ្តុះបណ្តាលមន្ត្រីជួរមុខ ក្នុងខេត្តចំនួន ០៣(សៀមរាប បាត់ដំបង ឧត្តរមានជ័យ) ចំនួន ០៦វគ្គ(តាមអនឡាញ ០២វគ្គ) មានសិក្ខាកាមចូលរួមសរុបចំនួន **៥៨៨**នាក់ (ស្រី **២២៩**នាក់)។

ខ. ការបង្ការ ទប់ស្កាត់

ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

ខ.១.១ .ការផ្សព្វផ្សាយដោយផ្ទាល់

ការផ្សព្វផ្សាយដោយផ្ទាល់	ចំនួនលើក	ចំនួនអ្នកចូលរួម	ចំនួនស្ត្រី
ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស	២០	១.០៧១.០៥៧	៥៥៤.៧៧០
កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ	១២៧.៩៩៦	៥.៥៤១.៥៨៤	២.៩១៩.៩៥០
កម្មវិធីផ្សេងៗ	១៦	៣.៤៩៩	៤៤១
អង្គការដៃគូ	៨៧	១៧.១២៧	៨.៨៥៥
សរុប	**១២៨.១១៩លើក**	**៦.៦៣៣.២៦៧នាក់**	**៣.៤៨៤.០១៦នាក់**



ខ.១.១.១. វេទិកាអន្តរសាសនា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួងធម្មការ និងសាសនា ប្រារព្ធពិធីអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «**សូមពិភពលោករួចផុតពីគ្រោះកូវីដ-១៩ និងអំពើជួញដូរមនុស្ស**» ដោយបានរៀបចំធ្វើឡើងជាវីដេអូ ដែលមានការគោរពអញ្ជើញដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការថ្លែងសុន្ទរកថាបើកកម្មវិធីនេះ ដោយបានធ្វើការផ្សព្វផ្សាយ តាមប៉ុស្តិ៍ទូរទស្សន៍ បណ្តាញសង្គមហ្វេសប៊ុក និងវិទ្យុជាតិ នៅវេលាម៉ោង ៦:០០នាទី ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ និងក្នុងពេលជាមួយគ្នានោះដែរ ក៏មានពិធីទូងស្គរ វាយដួងនៅគ្រប់វត្តអារ៉ាម ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ខ.១.១.២. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានសហការជាមួយទូរទស្សន៍បាយ័ន ផលិតវីដេអូបទយកការណ៍ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ លើកទី១៥ ឆ្នាំ២០២១ ក្រោមប្រធានបទ «សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស» ដែលមានការគោរពអញ្ជើញដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន **គ.ជ.ប.ជ** ថ្លែងសុន្ទរកថាបើកកម្មវិធីនេះ ដោយបានធ្វើការផ្សព្វផ្សាយតាមប៉ុស្តិ៍ទូរទស្សន៍ បណ្តាញសង្គមហ្វេសប៊ុក និងវិទ្យុជាតិ។

•**លេខាធិការដ្ឋាន គ.ជ.ប.ជ/គ.ខ.ប.ជ បានសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត** និងអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ ក្រោមប្រធានបទ «សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស» ដោយបានផលិតសម្ភារៈកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សម្រាប់អប អរក្នុងយុទ្ធនាការ។ ក្នុងនោះរាជធានី-ខេត្ត១៨៖ រាជធានីភ្នំពេញ ខេត្តសៀមរាប កោះកុង ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ ក្រចេះ រតនគិរី កំពត កែប តាកែវ ព្រៃវែង ស្វាយរៀង និងកំពង់ចាម បានរៀបចំការផ្សព្វផ្សាយទិវា១២ធ្នូនេះជាក្រុមតូច ធំ នៅតាមសាលារៀនទូទាំងប្រទេស ដែលមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **១.០៧១.០៥៧**នាក់(ស្រី **៥៥៤.៧៧០**នាក់)។ ខេត្តមួយចំនួនទៀតបានផ្សព្វផ្សាយតាមរយៈការចែកខិត្តប័ណ្ណ ចងបដាពាក្យស្លោកពាក់ព័ន្ធនឹង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមសាលាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ តាមសាលារៀន និងនៅតាមទីសាធារណៈ មួយចំនួនទៀត និងផ្សព្វផ្សាយបទយកការណ៍ដែលសហការផលិតដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងទូរទស្សន៍ ឬធ្វើបទសម្ភាសន៍នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខេត្ត សរុបចំនួន **១២៤**បដា និងពាក្យស្លោក **៤៦**ផ្ទាំង។

•**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានផលិតវីដេអូអប់រំខ្លីរឿង **"សន្យាខ្យល់"** ដើម្បីចូលរួមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ២០២១។ **មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្វាយរៀង** បានចូលរួមដំឡើង និងសម្តែងឈុតល្ខោនអប់រំខ្លីរឿង **"កំហុសអ្នកណា"** សម្រាប់ទិវាជាតិនេះផងដែរ និងមានអ្នកចូលរួមចំនួន **២០០**នាក់(ស្រី **៧០**នាក់)។

ខ.១.១.៣. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

ឆ្នាំ២០២១ នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំ មានសុវត្ថិភាព"** និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **១២៧,៩៩៦លើក** មានអ្នកចូលរួមសរុបចំនួន **៥.៥៤១.៤៨៤នាក់** (បើប្រៀបធៀបនឹង ឆ្នាំ២០២០ មានចំនួន **៦.១២០.៩៣០**នាក់ គឺមានការថយចុះចំនួន **៥៧៩.៤៤៦**នាក់ ស្មើនឹង **៩,៤៦%**) ក្នុងនោះស្ត្រីចំនួន **២.៩១៩.៩៥០**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

ល.រ	ក្រសួង ស្ថាប័ន រាជធានី-ខេត្ត	ផ្សព្វផ្សាយ			វេទិកាសាធារណៈ		
		ចំនួន ដង/លើក	ចំនួន មនុស្ស	ចំនួន ស្ត្រី	ចំនួន ដង/លើក	ចំនួន មនុស្ស	ចំនួន ស្ត្រី
ក្រសួង ស្ថាប័ន							
១	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	១៧	១.៥៩៦	៩៣០	១០	១.៥០០	០
២	ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	២	៤៣១	៩៥			
៣	អគ្គស្នងការដ្ឋាននគរបាលជាតិ	១.១១០	៦៩.៣១១	៤០.៦៦៧	៨៦៥	៤៥.៨០៩	២៣.៦៤៧
	សរុបក្រសួង ស្ថាប័ន	**១.១២៩ លើក**	**៧១.៣៣៨ នាក់**	**៤១.៦៩២ នាក់**	**៨៧៥ លើក**	**៤៧.៣០៩ នាក់**	**២៣.៦៤៧ នាក់**
រាជធានី-ខេត្ត							
១	រាជធានីភ្នំពេញ	៤	២២៨	០៥៨	១	២១០	១១៣
២	ខេត្តកណ្តាល	៥.៤៤២	១៧២.៧៩៩	៨៦.៩៤៣	៨.២៧៦	៥១០.២១៨	២៥២.៣៨៦

៣	ខេត្តបាត់ដំបង	១០.៤២៨	៣៦៧.៨៥៧	២០៩.២៨៣	៦.៨០៧	១៨៨.៥១១	១០១.៦៤០
៤	ខេត្តពោធិ៍សាត់	៤.៦៥៤	២១១.០៨៦	១០៦.៨៦៣	៨៧៧	៣៦.៦៦៧	១៦.០៩២
៥	ខេត្តសៀមរាប	១.២៨៩	៤៩.៤៦៤	៣០.៥៩៦	៤៥០	១២.០២៧	៦.៧៣៧
៦	ខេត្តកំពង់ឆ្នាំង	១៩.២១០	៤៤៩.៥៧៥	២០៧.៦៦២	៨.៣២៨	១៩៧.៧០៦	៩៧.២៥៣
៧	ខេត្តកំពង់ចាម	២៥.៩៨៣	១.៦៨៩.៧២៨	៩៦៩.១០២	១៧.២២១	៨៣១.៧៦៧	៤៦៩.២៨៧
៨	ខេត្តព្រះសីហនុ	១៥	៦៤៤	៣៨៥	៤	២៨១	១៥៣
៩	ខេត្តព្រះវិហារ	២៣៥	៣៣.៦៦៧	១៧.៩៣០	១១០	៤.៥៣៣	២.៥២៨
១០	ខេត្តស្វាយរៀង	១.២២៨	៣៧.៤៦០	២០.៨៥៩	២.៧៥៥	៨០.៥៤៤	៤៤.៧៤០
១១	ខេត្តប៉ៃលិន	៨០៣	១៤.៨៣៥	៧.២៩៣	៣៥០	១២.៨០៥	៥.៩១៥
១២	ខេត្តកោះកុង	២៩	៦៨០	៣០២	៣៤២	៦.៤៨៨	៣.៣២១
១៣	ខេត្តកំពត	២២៥	៤.៧១៣	១.៩០៥	១២៦	២.៨៤៨	១.៧៥០
១៤	ខេត្តកំពង់ធំ	៩	២.៧០០	១.៨០០	០	០	០
១៥	ខេត្តតាកែវ	២.៧២២	១០៤.៨២២	៤៦.៦៣៧	៩២៧	២៨.០៦៩	១២.៦១៣
១៦	ខេត្តក្រចេះ	៣៩៣	១៣៨.៩១៦	២០.២៥៨	០	០	០
១៧	ខេត្តកែប	១២៣	២៧.៥៦៩	១២.៧៣៦	១៨៥	១៣.៦៥៥	៤.៤៣៤
១៨	ខេត្តកំពង់ស្ពឺ	៨០៨	៤០.១៣៥	២២.២៥១	១០៧	១១.១១៨	១.៥០៣
១៩	ខេត្តស្ទឹងត្រែង	៣	១៦៦	១២១	០	០	០
២០	ខេត្តរតនគិរី	៥៦	១២.៧១៩	៦.៤៧៣	៦៩	៣.៩៩២	១.៤៨៤
២១	ខេត្តព្រៃវែង	៤	៩.១២៦	៣.៨២៩	៤១៦	១៥.៧៦៥	៦.៧៦៤
២២	ខេត្តត្បូងឃ្មុំ	៥១	៦.១៩១	៣.៦៣៨	០	០	០
២៣	ខេត្តបន្ទាយមានជ័យ	៤.៨៣៣	៨៣.៤៩៨	៤៥.៥២៩	៩	១.៩០១	៣០១
២៤	ខេត្តឧត្តរមានជ័យ	១០	៤.២៣០	២.៧៩៤	០	០	០
២៥	ខេត្តមណ្ឌលគិរី	៧៥	៩២៤	៣៥០	០	០	០
សរុប រាជធានី-ខេត្ត		**៧៨.៦៣២**	**៣.៤៦៣.៧៣២**	**១.៨២៥.៥៩៧**	**៤៧.៣៦០**	**១.៩៥៩.១០៥**	**១.០២៩.០១៤**
សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត		**ចំនួនលើក ១២៧.៩៩៦ លើក**		**ចំនួនមនុស្ស ៥.៥៤១.៤៨៤ នាក់**		**ចំនួនស្ត្រី ២.៩១៩.៩៥០ នាក់**	

ខ.១.១.៤. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

• ថ្នាក់ជាតិ៖

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការក្លែនអន្តរជាតិកម្ពុជា អង្គការសេកម្មភាពដើម្បីកុមារ ធាលហ្វាន់កម្ពុជា អង្គភាពការពារកុមារ និងដៃគូ បានរៀបចំពិធី «ប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ផែនការអនុវត្តន៍គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ ២០១៨-២០២៩» តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឯកឧត្តម ង៉ែត សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** មានអ្នកចូលរួមសរុបប្រមាណ ៣០០នាក់។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

១-សហការបច្ចេកទេសពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ បានរៀបចំកម្មវិធី «ផ្សព្វផ្សាយ តាមប្រព័ន្ធអនឡាញ ស្តីពី ក្រមសីលធម៌ មន្ត្រីនៅមណ្ឌលចត្តាឡីស័ក និង

សេវាគាំទ្រ» ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួមសរុបប្រមាណ **៤០០**នាក់។

២-ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE បើកកម្មវិធី «យុទ្ធនាការ ស្តីពីយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម» ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានជាតិអប់រំ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ សរុបប្រមាណ **២៥០**នាក់ និងបានបន្តចូលរួមក្នុងការផ្សព្វផ្សាយនៅសាលាប៊ែលធី អន្តរជាតិមួយលើកបន្ថែមទៀត មានលោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សចូលរួមតាមប្រព័ន្ធអនឡាញ ប្រមាណ **២៥០**នាក់បន្ថែមទៀត។

៣-ចូលរួមសហការបច្ចេកទេសពីក្រសួងសុខាភិបាល ដែលទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ រៀបចំកម្មវិធី «អប់រំ ផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ ស្តីពី ក្រមសីលធម៌មន្ត្រីនៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ» សម្របសម្រួលដោយ លោកជំទាវ **វ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ និងមានការចូលរួមពីតំណាងក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ TPO និងមន្ត្រីពាក់ព័ន្ធនឹងការងារចត្តាឡីស័ករាជធានី ខេត្តទាំង២៥ ដោយមានអ្នកចូលរួមសរុបប្រមាណ **២.២៣៧**នាក់(ស្រី **៤០១**នាក់)។

- **អង្គការជៃគូ**

តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយរបស់អង្គការជៃគូ

អង្គការ	សកម្មភាព	ចំនួនដង/លើក	ចំនួនមនុស្ស	ចំនួនស្រី
សាម៉ារីតាន់ភឹស (ខេត្តបន្ទាយមានជ័យ)	ផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករត្រឡប់មកពីប្រទេសថៃ។	០១	២.៥៥៧	១.២០៨
តំណក់ទឹក ត្រួសារថ្មី និងកឿន (ខេត្តបន្ទាយមានជ័យ)	ផ្សព្វផ្សាយ និងចែកលេខទូរស័ព្ទមជ្ឈមណ្ឌលព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករត្រឡប់មកពីប្រទេសថៃ និងម៉ាឡេស៊ី។	០១	១៨៤	៨១
APLE (ខេត្តសៀមរាប)	បានផ្សព្វផ្សាយ អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ ដល់ក្រុមគោលដៅយុវជន និងកុមារនៅក្នុងអង្គការជៃគូ។	០២	២៣	១៤
មូលនិធីអេ២១ (ខេត្តសៀមរាប)	ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិកុមារ រូបភាពនៃអំពើជួញដូរមនុស្ស រូបភាពនៃការកេងប្រវ័ញ្ចលើកុមារតាមដងផ្លូវ និងកិច្ចការពារកុមារ ដល់អាជ្ញាធរ តាមប្រព័ន្ធបណ្តាញសង្គម និងខិត្តប័ណ្ណ។	៥៧	១២.៩៥៦	៦.៨៤៤
អង្គការបន្ទាយស្រី (ខេត្តសៀមរាប)	-រៀបចំវេទិការកុមារ ស្តីពីការទទួលបានការអប់រំសម្រាប់កុមារដែលធ្វើចំណាកស្រុក សម្របសម្រួលដោយ បណ្តាញកុមារថ្នាក់ជាតិ តាមប្រព័ន្ធអនឡាញ។ -ធ្វើកិច្ចសន្ទនារវាងក្រុមបុរស និងកុមារ ដើម្បីផ្សព្វផ្សាយ និងជំរុញការគាំទ្រដល់ស្ត្រី និងកុមារី ដែលរងផលប៉ះពាល់ពីការធ្វើចំណាកស្រុក សម្របសម្រួលដោយក្រុមប្រឹក្សាឃុំ។	០២ ០២	២២ ៥៥	២០

អង្គការទេសន្តរប្រវេសន៍ IOM (ខេត្តសៀមរាប)	សហការជាមួយរដ្ឋបាលស្រុកស្រីស្នំ ស្រុកក្រឡាញ់ ស្រុកជីក្រែង និងស្រុកស្វាយលើ រៀបចំទិវាអន្តរជាតិជនទេសន្តរប្រវេសន៍ ១៨ធ្នូ និងបើកវគ្គអប់រំផ្សព្វផ្សាយ ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជ្រើសរើសពលករចូលរៀនជំនាញវិជ្ជាជីវៈ។	១១	៥០៧	២៥១
អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី)	សហការជាមួយអាជ្ញាធរស្រុកស្នួល និងស្រុកពេជ្រដា ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ។	០៥	៥៧៩	៣៤៩
ILO, ការីតាស់ (ខេត្តបាត់ដំបង)	ផ្សព្វផ្សាយ ស្តីពី ចំណាកស្រុកដោយសុវត្ថិភាព និងឱកាសការងារក្នុងស្រុក នៅស្រុកភ្នំព្រឹក កំរៀង សំឡូត រុក្ខគិរី និងស្រុកថ្មគោល។	០៥	១៧៤	៨៨
អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ខេត្តកំពង់ចាម	សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត រៀបចំវេទិកាសាធារណៈ ផ្សព្វផ្សាយច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងចំណាកស្រុកដោយសុវត្ថិភាព ដល់ពលរដ្ឋដែលរងគ្រោះចុះទូកនេសាទនៅប្រទេសថៃ នៅស្រុកស្ទឹងត្រង់។	០១	៧០	០០
សរុប		**៨៧ លើក**	**១៧.១២៧ នាក់**	**៨.៨៥៥ នាក់**

ខ.១.២. ការផ្សព្វផ្សាយ តាមរយៈឧបករណ៍ផ្សព្វផ្សាយ (IEC)

• ថ្នាក់ជាតិ៖

▪ **ក្រសួងអប់រំ យុវជន និងកីឡា** បានសហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការដៃគូ បោះពុម្ពសៀវភៅអប់រំ ស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» សម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ ចំនួន **៤.000**ក្បាល។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយ៖ អង្គការសាម៉ារីតាន់ភឹស អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការភឿន(ថៃ) អង្គការអន្តរជាតិទេសន្តរប្រវេសន៍អន្តរជាតិ(IOM) អង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការប្រឹក្សាយោបល់អំពីរបៀបក្លាយខ្លួនជាពលករស្របច្បាប់ដល់ពលករចំណាកស្រុកដែលត្រឡប់មកពីប្រទេសថៃ និងម៉ាឡេស៊ី។

▪ **ក្រសួងកិច្ចការនារី៖** បានសហការជាមួយអង្គការសហប្រជាជាតិ តាមរយៈកម្មវិធីសុវត្ថិភាព និងយុត្តិធម៌សម្រាប់ស្ត្រីពលករទេសន្តរប្រវេសន៍ បានសម្រេចនូវសកម្មភាពមួយចំនួនដូចជា៖

១-ផលិតរូបភាពចំនួន **០៨**ផ្ទាំង ដើម្បីផ្សព្វផ្សាយតាមបណ្តាញហ្វេសប៊ុក ស្តីពី «ការទប់ស្កាត់អំពើហិង្សាការរើសអើងលើស្ត្រីពលករចំណាកស្រុក ការផ្តល់សេវាគាំទ្រនានា និងការផ្តល់ព័ត៌មានអំពីប្រព័ន្ធទំនាក់ទំនងដែលអាចជួយដល់ស្ត្រី និងក្មេងស្រីរងគ្រោះ និងផលិតផ្ទាំងរូបភាព ចំនួន **១២**ច្បាប់ ស្តីពី «ការលើកកម្ពស់សុវត្ថិភាពសម្រាប់ពលករចំណាកស្រុកជាស្ត្រី តាំងពីមុនចេញដំណើរ» ក្នុងគោលបំណងបណ្តុះបណ្តាលបន្តដល់មន្ត្រីថ្នាក់ខេត្ត/ស្រុក ដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ។។

២-ផលិតខិត្តប័ណ្ណ **១.000**សន្លឹក សម្រាប់ផ្តល់ព័ត៌មាន អំពីលេខទូរស័ព្ទក្នុងការទំនាក់ទំនងដែលអាចព្រមគ្រាណ៌សុំកិច្ចអន្តរាគមន៍ក្នុងករណីបានឃើញ ឬបានជួបប្រទះអំពើហិង្សា អំពើជួញដូរស្ត្រី ឬការរំលោភបំពានលើស្ត្រីពលករចំណាកស្រុក ដែលនឹងធ្វើការផ្តល់ជូនទៅថ្នាក់ក្រោមជាតិ។

▪ **ក្រសួងទេសចរណ៍** បានសហការជាមួយអង្គការដៃគូ ផលិតសម្ភារៈផ្សព្វផ្សាយ ស្តីពី «ការលើកកម្ពស់សុវត្ថិភាពកម្មករក្នុងវិស័យទេសចរណ៍» ដូចជា៖ វីដេអូខ្លីៗ ស្លាកបិទ សៀវភៅតូចៗ ផ្ទាំងរូបភាពតូច ធំ សម្រាប់ចែកចាយ និងផ្សព្វផ្សាយតាមសហគមន៍ទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ នៅតាមបណ្តារាជធានី-ខេត្ត។

• ថ្នាក់ក្រោមជាតិ៖

▪ **រាជធានីភ្នំពេញ** បានចងបដា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខទំនាក់ទំនង នៅតាមទីតាំងគ្រប់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ក្នុងរាជធានីភ្នំពេញ។

▪ **ខេត្តសៀមរាប៖**

១.បានបន្តផ្សព្វផ្សាយសារ និងវីដេអូអប់រំ **០៨**វីដេអូ ស្តីពី **"សុវត្ថិភាពតាមប្រព័ន្ធអនឡាញ"** តាមទំព័រហ្វេសប៊ុករបស់អង្គការសេកម្មភាពដើម្បីកុមារ (APLE) ដល់ក្រុមគោលដៅដែលជាកុមារ យុវជន ឪពុកម្តាយ អ្នកមើលថែកុមារ និងអ្នកធ្វើការជាមួយកុមារ សំដៅលើកទឹកចិត្តឲ្យមានការរក្សាសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ មានមនុស្សចូលមើលចំនួន **១.២៤៦.១៤៤**នាក់ និងឆ្លើយតបចំនួន **១២០.៦៣៦**នាក់។

២.បានបញ្ចប់ និងផ្សព្វផ្សាយ «សៀវភៅជំនួយស្មារតី ស្តីពីសេវាសម្រាប់ជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ»។

៣-មន្ទីរទេសចរណ៍ខេត្ត បានចុះផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ សេវាកម្មទេសចរណ៍ តាមមូលដ្ឋានអាជីវកម្ម និងបញ្ជាបអំពីការទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ លើកុមារ និងធ្វើការណែនាំអំពីវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវី-១៩ ចំនួន **២៥**លើក មនុស្សចំនួន **១៩២**នាក់ (ស្រី **១៧៥**នាក់)។

•**អង្គការដៃគូ៖**

▪ **អង្គការ IOM (ខេត្តបន្ទាយមានជ័យ)** បានចែកសៀវភៅចំណាកស្រុកដោយសុវត្ថិភាព និងនាមប័ណ្ណរបស់មជ្ឈមណ្ឌលផ្តល់ព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករត្រឡប់ពីប្រទេសថៃ និងម៉ាឡេស៊ី ចំនួន **៤.១១០**នាក់(ស្ត្រី **១.៤៩៩**នាក់) និងខិត្តប័ណ្ណផ្សព្វផ្សាយចំនួន **១៨៤**ច្បាប់។

▪ **អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង)** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំណាកស្រុកដែលវិលត្រឡប់ពីប្រទេសថៃវិញ ចំនួន **១៧.២២៧**នាក់(ស្រី**៦.០៤៦**នាក់) កុមារ **៧៥៩**នាក់ កុមារី **៦៥៨**នាក់។

▪ **អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប)** បានចែកជូននូវសម្ភារអប់រំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងរូបភាពអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក និងកិច្ចការពារកុមារពីការរំលោភបំពាននានា បានចំនួន **១៣៦**ច្បាប់ និងបានផ្សព្វផ្សាយតាមបណ្តាញសង្គម ស្តីពី កិច្ចការពារកុមារ **០១**លើក អ្នកចូលរួម **២៥៧**នាក់(ស្រី **១៤៧**នាក់)។

▪ **អង្គការ APLE (ខេត្តសៀមរាប)** បានធ្វើកម្មវិធីបញ្ចូលរួមសហគមន៍ ឧស្សាហ៍កម្ម និងប្រព័ន្ធផ្សព្វផ្សាយជាសារវីដេអូអប់រំកម្មវិធីលើកកម្ពស់ការយល់ដឹងវគ្គបណ្តុះបណ្តាល យុទ្ធនាការ និងសិក្ខាសាលា ដើម្បីបង្ការទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ លើទំព័រហ្វេសប៊ុករបស់អង្គការAPLE។

▪ **អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)** សហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ចាម បានចុះចែកខិត្តប័ណ្ណ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយស្របច្បាប់ ចំនួន០៤ស្រុក នៅស្រុកកងមាស ព្រៃឈរ ចំការលើ និងស្រុកស្ទឹងត្រង់។

▪ **អង្គការសម្ព័ន្ធចាប់ដៃ** បានសហការជាមួយអាជ្ញាធរ ស្រុកពេជ្រដា ខេត្តមណ្ឌលគិរី និងស្រុកស្នួល ខេត្តក្រចេះ ចែកប័ណ្ណផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាជនក្នុងសហគមន៍ បានចំនួន **៥.៦០០**សន្លឹក និងរួមភាព តូច ធំចំនួន **១០២**ឈុត ដែលមានប្រជាជនចូលរួមសរុបចំនួន **៦៥៦**នាក់(ស្រី **៣២៣**នាក់)។

ខ.ប.ជ តាមផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

•**ថ្នាក់ជាតិ៖**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖**

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន **៤២.៣០៨**កន្លែង និងវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន **៤៣៦**វគ្គ ដោយផ្សព្វផ្សាយតាមរយៈគេហទំព័រមជ្ឈមណ្ឌលការងារ Facebook និងកម្មវិធីនាទីទីផ្សារការងារ និងមុខរបរ នៅតាមស្ថានីយទូរទស្សន៍នានា។
- បានពង្រីកការផ្តល់ព័ត៌មានទីផ្សារការងារ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយមានអ្នកចូលប្រើប្រាស់គេហទំព័រចំនួន **២.១៤២.៤៣៣**លើក Facebook ចំនួន **៨.៩៥៣**នាក់ YouTube ចំនួន **២៤.៧៤៧**នាក់ និងអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើ Mobile App ចំនួន **៧៤១**នាក់។
- បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមប្រព័ន្ធអនឡាញ **៣.៥៨២**ដង បានចងក្រងនិងផលិតស្តុត **៣៥៦**ដង ផ្សព្វផ្សាយតាមភូមិភាគ **២**ដង កម្មវិធី Roadshow និងផ្សព្វផ្សាយ **៥០**ដង មានមនុស្ស **៣.០១០**នាក់(ស្រី **១.៥៥៨**នាក់)។

▪ **ក្រសួងកិច្ចការនារី៖** ក្រោមកិច្ចសហការជាមួយអង្គការសហប្រជាជាតិ តាមរយៈកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ សម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី បានផលិតនូវរឿងខ្លីៗចំនួនពីរតាមកម្មវិធីវិទ្យុ រឿងទីមួយ "បំបែកភាពស្ងៀមស្ងាត់ និងសេវាគាំទ្រដល់ស្ត្រីពលករចំណាកស្រុក" និងរឿងទីពីរ "បញ្ឈប់ការកេងប្រវ័ញ្ចកម្លាំងការងារ និងការរើសអើងលើស្ត្រីពលករចំណាកស្រុក" សម្រាប់ផ្សព្វផ្សាយក្នុងខេត្តគោលដៅចំនួនបី មានខេត្ត(ព្រះសីហនុ កំពង់ស្ពឺ និងខេត្តសៀមរាប) បានចំនួន ១៣៧លើក និងផ្សព្វផ្សាយតាមបណ្តាញ Facebook។

▪ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖** បានអប់រំផ្សព្វផ្សាយទូលំទូលាយក្នុងប្រព័ន្ធព័ត៌មានសង្គមស្តីពី៖**១**-បរិមាណទីផ្សារតម្រូវការកសិផលកម្ពុជា ដែលអាចអូសទាញកម្លាំងពលករក្នុងវិស័យកសិកម្ម ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក។ **២**-បានកៀរគរការចូលរួមពីផ្នែកឯកជនធ្វើការផ្សព្វផ្សាយ ស្តីពីការអប់រំវិធីសាស្ត្រដាំដុះដំណាំអនុផលដែលអាចលើកកម្ពស់ជីវភាពគ្រួសារមិនចាំបាច់ការធ្វើចំណាកស្រុក។

▪ **ក្រសួងព័ត៌មាន៖ ក/** បានពង្រឹងសមត្ថភាពដល់អ្នកសារព័ត៌មានឲ្យយល់ពីតម្លៃខ្ពឹមសារព័ត៌មាន និងជំរុញឲ្យមានការផ្សព្វផ្សាយដល់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដូចជាបាន៖ **១**-គ្រប់គ្រងគ្រឹះស្ថានព័ត៌មានធ្វើការផ្សព្វផ្សាយព័ត៌មានពិតទាន់ហេតុការណ៍ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការសង្គ្រោះជនរងគ្រោះទាន់ពេលវេលា។ **២**-បញ្ចូលសារអប់រំ ស្តីពីការចូលរួមបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមកម្មវិធីទូរទស្សន៍ជាតិ។ **ខ/** មន្ទីរព័ត៌មាន រាជធានី ខេត្ត (ភ្នំពេញ ព្រះវិហារ បន្ទាយមានជ័យ បាត់ដំបង កោះកុង ព្រះសីហនុ កែប និងខេត្តកំពង់ចាម) បានសហការជាមួយអង្គការដៃគូ និងមន្ទីរអង្គភាពពាក់ព័ន្ធ រៀបចំផ្សព្វផ្សាយជាស្តុត និងតាមវិទ្យុជាតិ ទូរទស្សន៍ជាតិខេត្ត និងតាមកម្មវិធីកិច្ចសន្ទនាមតិ ក្រោមប្រធានបទ " ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការឆ្លងដែនខុសច្បាប់" ក្នុងអំឡុងវិបត្តិកូវីដ-១៩ បានចំនួន **៤.៣០៥**លើក។

▪ **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ចូលសារអប់រំពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ទៅក្នុង VCD, DVD រាល់ពេលដែលអាជីវករសុំទិដ្ឋាការផ្សព្វផ្សាយក្នុងផលិតកម្មភាពយន្ត ចំនួន **២៣០.០៧៧** ផលិតផល។

▪ **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** បានសហការជាមួយ**ក្រសួងអប់រំ យុវជន និងកីឡា** ផ្សព្វផ្សាយតាមរយៈគេហទំព័រ កម្មវិធីសិក្ខាសាលា ស្តីពី «កិច្ចការពារកុមារលើប្រព័ន្ធអនឡាញនៅកម្ពុជា» មានអ្នកមើលតាមរណ្តាញ Facebook ចំនួន **៥.០០០**នាក់។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បាន៖ **១**-សហការជាមួយនិយ័តការទូរគមនាគមន៍កម្ពុជា(TRC) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំរុញប្រតិបត្តិការផ្នែកសេវាកម្មទូរគមនាគមន៍មានដូចជាក្រុមហ៊ុន Smart Axiata, CamGSM, South East Asia Telecom, Viettel បានធ្វើការផ្ញើសារតាមរយៈ

ទូរស័ព្ទចល័ត ផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋចំនួន ០៣លើក៖ (**ក.**យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់ សីលធម៌ ដើម្បីសុវត្ថិភាពសង្គម ដែលមានខ្លឹមសារថា "រាល់ទម្រង់នៃការរំលោភបំពាន និងការជួញដូរកុមារជាបទល្មើស"។ **ខ.** អបអរសាទរទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា "យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ"។ **គ.**អបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានខ្លឹមសារថា "សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស")។ **២-**ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក ដែលមានអ្នកទស្សនា សរុបចំនួន **១៣៧.៤៥៦**នាក់។

- **ថ្នាក់ក្រោមជាតិ៖**

▪ **ខេត្តសៀមរាប៖**

១-លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរព័ត៌មានខេត្ត៖ បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស សរុបចំនួន **៤២៣**លើក(ផ្សាយផ្ទាល់ **១៧៧**លើក ចាក់ផ្សាយឡើងវិញ **២៤៦**លើក)។

២-អង្គការមូលនិធិ A២១៖ បានធ្វើការផ្សព្វផ្សាយអំពីសិទ្ធិកុមារ ការធ្វើចំណាកស្រុក រូបភាពអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកុមារតាមដងផ្លូវ តាមប្រព័ន្ធបណ្តាញសង្គមហ្វេសប៊ុក វិទ្យុ និងទូរទស្សន៍ ចំនួន **១០**លើក មានអ្នកចូលរួមសរុបចំនួន **៨.៣២៣**នាក់(ស្រី **៣.៧៨៩**នាក់)។

▪ **ខេត្តតាកែវ៖**

-ក្រុមការងារលេខាធិការដ្ឋានគ.ខ.ប.ជ សហការជាមួយមន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍គោកធ្លក អំពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការបង្ការទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ និងកិច្ចការពារកុមារ ចំនួន **៧.៦៩៨**លើក។

-**មន្ទីរព័ត៌មានខេត្ត** បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមវិទ្យុ និងទូរទស្សន៍គោកធ្លក សរុប **៨៩៣**លើក ក្នុងនោះផ្សព្វផ្សាយព័ត៌មាន និងសារអប់រំខ្លីៗអំពីសកម្មភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស **៤១៤**លើក ផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរនិងការធ្វើអាជីវកម្ម **៣០**លើក និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀន **៤៤៩**លើក។

▪ **ខេត្តមណ្ឌលគិរី៖** មន្ទីរធម្មការ និងសាសនាខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងកម្មវិធី "**ព្រះពុទ្ធសាសនា ផ្សារភ្ជាប់សង្គម**" ចំនួន **១៤០**លើក។

▪ **ខេត្តកំពង់ចាម៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិភ្នំប្រុសភ្នំស្រី ចាក់សារអប់រំស្តីពី ការទប់ស្កាត់ការប្រើប្រាស់ពលកម្មលើកុមារ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល សរុប **៩១**លើក។

▪ **ខេត្តត្បូងឃ្មុំ៖** បានចាក់ផ្សាយបទយកការណ៍ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ ក្រោមប្រធានបទ "សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស" តាមទូរទស្សន៍ និងវិទ្យុជាតិត្បូងឃ្មុំ ដោយចាក់ផ្សាយក្នុងមួយថ្ងៃ ០៣លើក សរុបរួម **៦០**លើក។

▪ **ខេត្តកំពង់ស្ពឺ៖** បានចាក់ផ្សាយរឿងអប់រំខ្លី២រឿង(បំបែកភាពស្ងៀមស្ងាត់និងសេវាគាំទ្រពលករចំណាកស្រុក និងបញ្ឈប់អំពើកេងប្រវ័ញ្ចការងារការើសអើងលើស្ត្រីពលករចំណាកស្រុក) តាមវិទ្យុគិរីរម្យ ចំនួន **៤៥**លើក ឧបត្ថម្ភពីក្រសួងកិច្ចការនារី និងអង្គការ UN WOMEN។

▪ **ខេត្តព្រះវិហារ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការទប់ស្កាត់ការធ្វើចំណាកស្រុកដោយប្រជុំយប្រថាន និងផ្សព្វផ្សាយទិវាជាតិ១២ធ្នូ ឆ្នាំ២០២១ តាមវិទ្យុ ទូរទស្សន៍ និងហ្វេសប៊ុកផេក សរុប **៥២**លើក។

▪ **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការ IJM បង្កើតកម្មវិធីផ្សព្វផ្សាយវេទិកាតុមូលក្រោមប្រធានបទ «យើងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ពិសេសស្ត្រី និងកុមារ» និងបទយកការណ៍ទិវាជាតិលើកទី១៥ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តិអំពើជួញដូរមនុស្ស» នៅប៉ុស្តិ៍ទូរទស្សន៍ជាតិវិដ្ឋលស្វាយរៀងចំនួន **០២**លើក ។

ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីនានា

•ថ្នាក់ជាតិ៖

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស នៃកម្មវិធីទូរទស្សន៍បាយ័ន ស្តីពី «**យុទ្ធនាការរួមគ្នាបញ្ឈប់ការជួញដូរមនុស្ស**» ដោយបានផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងការងារ និងច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ផងដែរ។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ចូលរួមជាវាគ្មិនក្នុង៖ **១**-វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ(CWCC) នៅភ្នំពេញ។ **២**-កម្មវិធីវិទ្យុលើប្រធានបទ "យើងទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងអំឡុងពេលការឆ្លងរាលដាលនៃជំងឺកូវីដ-១៩"។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**: បានចូលរួមជាវាគ្មិនក្នុង៖ **១**-ការផ្សាយផ្ទាល់កម្មវិធី "សម្លេងសមភាពយេនឌ័រ" ដើម្បីជជែកពិភាក្សាអំពីរបៀប នៃការធ្វើចំណាកស្រុកទៅក្រៅប្រទេសប្រកបដោយសុវត្ថិភាព និងរបៀបការពារខ្លួន។ **២**-សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង "ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព" នៅសាលាខេត្តកំពង់ស្ពឺ និងសាលាខេត្តព្រះសីហនុ។ **៣**-កម្មវិធី "**ដឹង គិត យល់ ជោគជ័យ**" ស្តីពីការរើសអើងលើពលករចំណាកស្រុកជាស្ត្រី និងក្មេងស្រី។ **៤**-សិក្ខាសាលា ស្តីពីការពង្រឹងគុណភាព នៃការបណ្តុះបណ្តាលពលកររទេសន្តរប្រវេសន៍ពេលចេញដំណើរ។ **៥**-វេទិកាសាធារណៈ ស្តីពីការជម្នះឧបសគ្គរបស់ពលករចំណាកស្រុក ក្នុងបរិបទកូវីដ-១៩។

▪ **ក្រសួងអប់រំ យុវជន និងកីឡា** ▫ បានចូលរួមជាវាគ្មិននៅក្នុងកិច្ចសន្ទនាស្តីពី«អន្តរាគមន៍សំខាន់ៗក្នុងការទប់ស្កាត់ និងឆ្លើយតបហានិភ័យរបស់កុមារ ជាពិសេសក្មេងស្រីតាមប្រព័ន្ធអនឡាញ»។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

-លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ និងលោកស្រី **ព្រុំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញជាវាគ្មិនកិត្តិយស នៅវិទ្យុដូនពេញ និងវិទ្យុទន្លេ ចំនួន ០៣លើក ក្នុងកម្មវិធីគ្រួសាររឹងមាំលើប្រធានបទ «ការបង្ការ និងឆ្លើយតបនឹងការជួញដូរកុមារ» ហើយក៏មានការផ្សព្វផ្សាយតាមទំព័រហ្វេសប៊ុកផងដែរ។

-ឯកឧត្តម ឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ បានដឹកនាំក្រុមការងារជំនាញមានលោកឧត្តមសេនីយ៍ទោ **វ៉ែន សុភ័ក្ត្រវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ និងលោកអនុសេនីយ៍ឯក **ហង្ស ពុទ្ធារិទ្ធិ** ចូលរួមធ្វើជាគ្រូឧទ្ទេស ជាមួយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្នុងវគ្គសិក្ខាសាលាបំប៉ន ស្តីពី «ការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន» ជូនលោកគ្រូ អ្នកគ្រូ ជាគ្រូបង្គោល នៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម តាមប្រព័ន្ធអនឡាញ។

•ថ្នាក់ក្រោមជាតិ៖

▪ **ខេត្តសៀមរាប** ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីវិទ្យុ ស្តីពីដំណើរការគ្រប់គ្រងស្ថិតិពលករចំណាកស្រុក ការបង្ការទប់ស្កាត់ការរំលោភផ្លូវភេទលើស្ត្រីនិងកុមារ ការលើកកម្ពស់ការយល់ដឹងរបស់ស្ត្រីពីការជួញដូរផ្លូវភេទ និងការលើកទឹកចិត្តឱ្យមានមន្ត្រីនគរបាលជាស្ត្រីនៅតាមមូលដ្ឋាន ចំនួន ០៦លើក។

▪ **ខេត្តបាត់ដំបង៖** បានចូលរួមជាវាគ្មិននៅវិទ្យុជាតិចំការចេក ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផលប៉ះពាល់ពីការធ្វើចំណាកស្រុកដោយខុសច្បាប់ ទប់ស្កាត់ការរំលោភបំពានសិទ្ធិ និងការកេងប្រវ័ញ្ចពលកម្មកុមារ ចំនួន ០៤លើក។

▪ **ខេត្តកំពង់ចាម៖** ក្រុមការងារជំនាញនៃគ.ខ.ប.ជ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ នៅវិទ្យុជាតិនៃមន្ទីរព័ត៌មានខេត្ត ដើម្បីផ្សព្វផ្សាយស្តីពីដំណើរការគ្រប់គ្រងស្ថិតិពលករចំណាកស្រុក និងស្តីពីការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ ព្រមទាំងវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល ដល់ពលករចំណូលស្រុក បានចំនួន **៣១**លើក ហើយក៏បានផ្សព្វផ្សាយតាមហ្វេសប៊ុកផេកផងដែរ។

▪ **ខេត្តព្រៃវែង៖** បានចូលរួមជាវាគ្មិនក្នុង៖ **១**-កម្មវិធីរបស់មជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍ខេត្ត ស្តីពីក្រមសីលធម៌របស់ទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីបណ្តុះបណ្តាលដល់គ្រូបង្គោលតាមមន្ទីរ និងអង្គភាពពាក់ព័ន្ធនិងស្រុក ឃុំ សង្កាត់។ **២**-វគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកឆ្លាតវៃ ការធ្វើការងារឆ្លាតវៃ ដល់ជនបង្គោលតាមមន្ទីរ អង្គភាព និងអាជ្ញាធរមូលដ្ឋាន មានអ្នកចូលរួមចំនួន **៦០**នាក់(ស្រី **២៥**នាក់)។

▪ **ខេត្តស្ទឹងត្រែង៖** ស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីជំនាញ០១រូប ចូលរួមជាវាគ្មិន ស្តីពីការរំលោភបំពានលើកុមារ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅស្ថានីយទូរទស្សន៍ ខេត្តស្ទឹងត្រែង ០១លើក។

ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

ខ.២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

▪**ក្រសួងអប់រំ យុវជន និងកីឡា៖**

១-បានសហការជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការ Plan International Cambodia, CWCC, A21 Foundation, Caritas Cambodia, Cambodia Acts, APLE, First Step Cambodia, Solidar Suisse, Child Fund Cambodia, Care Cambodia តាក់តែងខ្លឹមសារ រៀបចំសៀវភៅមេរៀន ស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» សម្រាប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ។

២-បានបន្តបណ្តុះបណ្តាលគ្រូបង្គោល អំពីវិធីសាស្ត្រប្រើប្រាស់សៀវភៅទាំងពីរកម្រិតនេះ ដល់គ្រូឧទ្ទេសក៏ថ្នាក់ជាតិ និងគ្រូឧទ្ទេសក៏នៅសាលាគរុកោសល្យទូទាំងប្រទេស។

៣-បាន និងកំពុងបន្តសហការជាមួយអង្គការ Plan International-Thai បង្កើតគម្រោងបណ្តុះបណ្តាលសម្រាប់ការសិក្សាពីរភាសា ខ្មែរ-ថៃ សម្រាប់កុមារដែលរស់នៅជាយដែន ក្នុងខេត្តកោះកុង(កម្ពុជា) និងខេត្តត្រាត(ថៃ) និងសម្រាប់កុមារក្នុងគ្រួសារជនទេសន្តរប្រវេសន៍ ក្នុងគោលបំណងធ្វើសមាហរណកម្មកុមារទេសន្តរប្រវេសន៍ ទៅក្នុងប្រព័ន្ធសិក្សាធិការ នៅពេលធ្វើមាតុភូមិនិវត្តន៍។ គម្រោងនេះបានផលិតមេរៀនជាវីដេអូសម្រាប់បង្រៀនសាកល្បង ចំនួន ៤០ឃ្លីប និងបានបង្រៀនសាកល្បងដល់សិស្សកម្ពុជា នៅសាលាបឋមសិក្សា ហ៊ុន សែន ចាំយាម និងនៅការិយាល័យអប់រំស្រុកមណ្ឌលសីមា សរុបចំនួន ៥០នាក់។

៤-បានពង្រឹកសកម្មភាពរៀបចំ គណៈកម្មការទប់ស្កាត់ការជួញដូរមនុស្ស ពីថ្នាក់មន្ទីរអប់រំ រហូតដល់ថ្នាក់ស្រុក និងសាលារៀននៅគ្រប់ខេត្ត និងរាជធានី ព្រមទាំងបានផ្សព្វផ្សាយសកម្មភាពប្រឆាំងការជួញដូរមនុស្ស តាមរយៈការប្រជុំប្រចាំខែតាមប្រព័ន្ធអនឡាញ។

▪**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានផ្សព្វផ្សាយណែនាំចាងហ្វាងផលិតកម្មភាពយន្ត ឱ្យដំឡើងសារអប់រំ ស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស» ទៅក្នុងផលិតផលភាពយន្ត និងចម្រៀង ចំនួន ៣០ក្រុមហ៊ុនផលិតកម្ម។

ខ.២.២. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់

▪**អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន **០៥** បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដោយខុសច្បាប់បានចំនួន **៣៦៣**លើក មនុស្សចំនួន **៣.៣៤០នាក់**(ស្រី **១.២៣៨**នាក់) អនីតិជន **១២៤**នាក់ ក្នុងនោះមាន៖

-ខេត្តបាត់ដំបង ៨២លើក មនុស្សចំនួន ៧៣០នាក់(ស្រី ២៧២នាក់) អនីតិជន ៦៧នាក់។

- ខេត្តកោះកុង ១៣៧លើក មនុស្សចំនួន ៧០២នាក់(ស្រី ១៩៤នាក់)។
- ខេត្តបន្ទាយមានជ័យ ១៣១លើក មនុស្សចំនួន ១.៧៣៩នាក់(ស្រី ៧១៦នាក់) អនីតិជន ៥៧នាក់។
- ខេត្តតាកែវ ១២លើក មនុស្សចំនួន ១៥៩នាក់ (ស្រី ៥៥នាក់)។
- ខេត្តស្វាយរៀង ០១លើក មនុស្សចំនួន ១០នាក់ (ស្រី ០១នាក់)។

✓ **ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។**

▪**ដោយឡែក ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ចំណុះទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន នៃក្រសួងការពារជាតិ** បាន៖

- បង្ការទប់ស្កាត់ពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ទៅប្រទេសថៃបានចំនួន **៧៣៣**នាក់(ស្រី **២៤៤**នាក់) អនីតិជន **៣៨**នាក់ ក្នុងនោះបានឃាត់ខ្លួនមេខ្យល់បាន **០៥**នាក់(អ្នករត់មូតូឌុប ០៣នាក់ និងអ្នកបើកបររថយន្ត ០២នាក់)។
- ទទួលពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃ ដោយមូលហេតុឆ្លងដែនខុសច្បាប់ចំនួន **៤៩១**នាក់(ស្រី **១៦៣**នាក់) កុមារ **១០**នាក់ និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។
- ឃាត់ខ្លួនពលរដ្ឋថៃដែលឆ្លងដែនខុសច្បាប់ ពីប្រទេសខ្លួនមកកម្ពុជា ចំនួន **០៩**នាក់(ស្រី **០៣**នាក់) និងពលរដ្ឋបរទេសដែលឆ្លងដែនខុសច្បាប់ពីកម្ពុជាទៅថៃ ចំនួន **១៧០**នាក់(ស្រី **៧២**នាក់) ក្នុងនោះមាន ជនជាតិថៃ **១៦៤**នាក់(ស្រី **៧២**នាក់) ជនជាតិចិន **០៤**នាក់ វៀតណាម **០១**នាក់ និងជនជាតិកាណាដា **០១**នាក់ ឃាត់ខ្លួនមេខ្យល់រត់ម៉ូតូឌុប **០១**នាក់ ដោយបានប្រគល់ទៅសមត្ថកិច្ចជំនាញ។

ខ.២.៣. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

• **ថ្នាក់ជាតិ៖**

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

- ធ្វើការអប់រំណែនាំតម្រង់ទិសពលកររមុនចេញដំណើរ អំពីភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបធ្វើការងារ និងច្បាប់របស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ ការរស់នៅ និងទំនៀមទម្លាប់ប្រពៃណីនៃប្រទេសទទួលបានចំនួន **០៧**លើក មានចំនួនមនុស្ស **៦៣៤**នាក់(ស្រី **១៥៦**នាក់)។
- ប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន **៥១,១៧៤**កន្លែង និងវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន **៤៤៦**វគ្គ ពីគ្រប់ប្រភព។
- សហការជាមួយអង្គការ IOM រៀបចំវគ្គបណ្តុះបណ្តាល «ស្តីពីប្រព័ន្ធអន្តរជាតិនៃការជ្រើសរើសពលករដោយសុចរិត(IRIS)» សម្រាប់ទីភ្នាក់ងារជ្រើសរើសពលករនៅក្នុងប្រទេសកម្ពុជា ចំនួន **២**លើក នៅខេត្តសៀមរាប និងរាជធានីភ្នំពេញ។
- សហការជាមួយអង្គការ ILO រៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីគោលការណ៍ណែនាំ ស្តីពីការដោះស្រាយវិវាទ ទាក់ទងនឹងពលករទេសន្តរប្រវេសន៍ និងគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ នៅខេត្តសៀមរាប។
- រៀបចំពិព័រណ៌ការងារចល័តចំនួន **២២**ដង មានអ្នកចូលរួមចំនួន **២.៩៥៤**នាក់ និងរៀបចំវេទិកាការងារចំនួន **១០**លើក មានអ្នកចូលរួមចំនួន **១.១៣៧**នាក់។
- ផ្គុំឈ្មោះអ្នកស្វែងរកការងារ ចំនួន **៣.៣០៥**នាក់(ស្រី **២.៣០៩**នាក់) និងជួយស្វែងរកការងារជូនប្រជាពលរដ្ឋតាមរយៈយន្តការផ្តល់ផ្តែងការងារតាមបច្ចេកវិទ្យាព័ត៌មាន មជ្ឈមណ្ឌលការងារ និងវេទិកាការងារថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន ចំនួន **៦.៨៥៨**នាក់(ស្រី **៣.៩៧២**នាក់) និងមានអ្នកទទួលបានការងារធ្វើចំនួន **៨៣៧**នាក់(ស្រី **៤៤៥**នាក់)។
- ផ្តល់សេវាប្រឹក្សាយោបល់អាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើចំនួន **៤.៥២៧**នាក់(ស្រី **១,០៥៥**នាក់)។

- ផ្តល់កម្មវិធីតម្រង់ទិសអាជីពការងារ និងវិជ្ជាជីវៈនៅតាមសាលារៀនមធ្យមសិក្សាចំណេះទូទៅ បានចំនួន **៥២៨**សាលា ដែលមានសិស្សសរុបចំនួន **៣៥.៥៧៧**នាក់(ស្រី **១៨.៦៧៧**នាក់)។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)៖**

- ក្រុមការងារការិយាល័យនីតិកម្ម និងអធិការកិច្ច បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀង ជាមួយក្រសួងស.អ.យ និងមណ្ឌលសំចត សរុបចំនួន ១៨មណ្ឌល (មជ្ឈមណ្ឌលរបស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែតរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះចំនួន០១កន្លែង) ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យដល់មជ្ឈមណ្ឌលទាំងអស់នោះត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។
- ឯកឧត្តម **ញ៉ឹក ឥណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ បានដឹកនាំក្រុមការងារអន្តរក្រសួង ស្ថាប័ន ចុះត្រួតពិនិត្យការគ្រប់គ្រងស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានវិលត្រឡប់តាមច្រកព្រំដែនអន្តរជាតិ និងច្រកតំបន់នៃខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន កោះកុង ពោធិ៍សាត់ និងខេត្តស្វាយរៀង និងដោយបានយកអំណោយនូវសម្ភារ គ្រឿងឧបភោគ បរិភោគទៅចែកជូនដល់មន្ត្រីប្រចាំការនៅតាមច្រកនីមួយៗ និងកងកម្លាំងប្រចាំការនៅច្រកបឹងត្រកួនមួយចំនួនផងដែរ ដោយមានការសហការពីអង្គការA21។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- បានដាក់ចេញនូវវិធានការគ្រប់គ្រងស្ថានភាព ការទទួល ការបញ្ជូនពលករតាមបណ្តាច្រកព្រំដែន និងការធ្វើសមាហរណកម្មតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ដោយរក្សាសុវត្ថិភាពសុខភាព តាំងពីដំណាក់កាលដំបូង នៃការប្រកាសបិទព្រំដែនរបស់ថៃ។
- បានសហការជាមួយអង្គការការីតាស់ស្វីស បង្កើតមណ្ឌលទទួលពលករកំរៀង ក្នុងខេត្តបាត់ដំបង ដើម្បីដោះស្រាយបញ្ហាពលករដែលឆ្លងកាត់ព្រំដែន។

▪ **អង្គការដៃគូ៖ អង្គការរតនៈអ៊ីនធឺណេសិនណល** បានសហការជាមួយមន្ទីរ ស.អ.យ រាជធានី-ខេត្ត ធ្វើការត្រួតពិនិត្យ តាមដាន និងសួរសុខទុក្ខជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន **៨០**នាក់(ស្ត្រី **៦៥**នាក់) មានដូចជា៖ រាជធានីភ្នំពេញ ខេត្តឧត្តរមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ធំ កំពង់ស្ពឺ កណ្តាល តាកែវ ព្រៃវែង និងខេត្តរតនៈគិរី។

• **ថ្នាក់ក្រោមជាតិ៖**

▪ **លេខាធិការដ្ឋាននាជធានី ខេត្ត** បានធ្វើសេចក្តីរាយការណ៍ជាប្រចាំអំពីពលករ និងពលរដ្ឋ ដែលវិលត្រឡប់ពីបរទេស ដើម្បីតាមដានស្ថានភាពសុខភាព ជីវភាព និងធ្វើការអប់រំបង្ការទប់ស្កាត់ ការវិលត្រឡប់ទៅប្រទេសគោលដៅដោយប្រថុយប្រថាន តាមការញុះញង់ពីមេខ្យល់ និងសហការជាមួយអង្គការដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីភាពប្រឈម និងសេចក្តីត្រូវការ ក្នុងពេលធ្វើសមាហរណកម្ម និងបានសហការជាមួយអង្គការដៃគូ សប្បុរសជនផ្តល់ការឧបត្ថម្ភគាំទ្រផ្នែកសុខភាព និងជីវភាព។

ខ.២.៤. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

ឆ្នាំ២០២១នេះ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប **៣.២៨១**នាក់(ស្រី **១.០៨១**នាក់) ក្នុងនោះមាន៖

- សាធារណរដ្ឋកូរ៉េ	ចំនួន **២.៥៧៧**នាក់	ស្រី **៧០១**នាក់
- ប្រទេសជប៉ុន	ចំនួន **៦៣១**នាក់	ស្រី **៣០៨**នាក់
- ប្រទេសសិង្ហបុរី	ចំនួន **០៣**នាក់	ស្រី **០២**នាក់

- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន **៧០**នាក់ ស្រី **៧០**នាក់។

▪**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

១-ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដាន ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ រហូតដល់ពលករវិលត្រឡប់មកមាតុប្រទេសវិញ។

២-បានរៀបចំ និងពង្រឹងប្រព័ន្ធ OCWC (Oversea Cambodian Working Card) ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូល ក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។

៣-បានពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

▪**អគ្គស្នងការដ្ឋាននគរបាលជាតិ** ស្នងការដ្ឋាននគរបាលទាំង ២៥រាជធានី-ខេត្ត៖

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករទៅធ្វើចំណាកស្រុកទាំងស្របច្បាប់ និងមិនស្របច្បាប់សរុបចំនួន **២៤៣.៥២០**នាក់(ស្រី **១០៧.៩៥១**នាក់) អនីតិជន **៣.៨៤៥**នាក់(ស្រី **១.៦០០**នាក់) ក្នុងនោះមាន៖
  - ○ពលករចេញទៅក្រៅប្រទេសដោយស្របច្បាប់ចំនួន **១៦៦.១៧៤**នាក់(ស្រី **៧៤.៨៣៨**នាក់) អនីតិជន **១.៣៤៥**នាក់(ស្រី **៥៩១**នាក់)។
  - ○ពលករចេញទៅក្រៅប្រទេសដោយមិនស្របច្បាប់សរុបចំនួន **៧៧.៣៤៦**នាក់(ស្រី **៣៣.១១៣**នាក់) អនីតិជន **២.៥០០**នាក់(ស្រី **១.០០៩**នាក់)។
- ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុក ត្រឡប់ពីក្រៅប្រទេសដោយខ្លួនឯង ទាំងស្របច្បាប់ និងមិនស្របច្បាប់ ពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សរុបចំនួន **១៧៣.៩២៦**នាក់(ស្រី **៧៦.៥៣៩**នាក់) អនីតិជនចំនួន **២.២៥១**នាក់(ស្រី **១.០១៨**នាក់)។

▪**រដ្ឋបាលរាជធានី ខេត្ត** ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ បានប្រមូលទិន្នន័យជាប្រចាំនូវចំនួនពលកររវិលត្រឡប់ជារៀងរាល់ថ្ងៃ សរុបប្រមាណ **២៣៦,៨៥៥**នាក់ មានស្ត្រីប្រមាណ **៩៨,៦០៣**នាក់ (**៤១.៦៣%**) ដែលភាគច្រើន មិនមានសេសសល់ប្រាក់ចំណូលសម្រាប់ការផ្គត់ផ្គង់ខ្លួន ឬគ្រួសារនៅឯស្រុកទេ។

តារាងពលកររវិលត្រឡប់គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១

ល.រ	ខេត្ត	ចំនួនអ្នករវិលត្រឡប់សរុប	ស្ត្រី	ផ្សេងៗ
១	កណ្តាល	៨៥៨	៣៨២	
២	ព្រៃវែង	២១.៥២៩	៨.៤៤៩	
៣	ស្វាយរៀង	២.៤៦១	៨៣៣	
៤	កំពត	៤២៤	១៨៣	
៥	តាកែវ	២.៦៧៧	១.១៨៧	
៦	កែប	៦០	៣៩	
៧	កោះកុង	១៩៩	៦២	
៨	ព្រះសីហនុ	២	១	
៩	ក្រចេះ	២.៣៥១	៧១២	
១០	កំពង់ចាម	១.៣០៩	៥២២	
១១	ឧត្តរមានជ័យ	៦០.៥២០	២៦.៥៦៧	

១២	បន្ទាយមានជ័យ	៨០.៦៩២	៣១.៩៤៧	
១៣	ប៉ៃលិន	១២.០៨៥	៤.៩១៩	
១៤	បាត់ដំបង	១៥.៣២២	៦.៨០០	
១៥	ពោធិសាត់	៦៩៣	៤២១	
១៦	កំពង់ឆ្នាំង	២.២០៦	១.១០៩	
១៧	ព្រះវិហារ	៣៤៨	១៣២	
១៨	សៀមរាប	៣២.៩០២	១៤.២៥៣	
១៩	មណ្ឌលគីរី	១៤០	៦៥	
២០	រតនៈគីរី	៧៧	២០	
សរុប		**២៣៦.៨៥៥ នាក់**	**៩៨.៦០៣ នាក់**	



ខ.២.៤. ការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

-ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ល្បាតឃ្លាំមើលគោលដៅ សង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន **៦៨៤**លើក លើ**៨៨២**គោលដៅ នៃគោលដៅបម្រើសេវាកំសាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ជាវកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដែលមានមនុស្សសរុបចំនួន **៤.១៧៧**នាក់(ស្រី **៣.៥៥៦**នាក់) ដូចមានតារាងខាងក្រោម៖

តារាងល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត	ឆ្នាំ២០២១											
	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
	១១២លើក	១១២លើក	១០៨លើក	៩៦លើក	១០០លើក	១០លើក	០៨លើក	១០៨លើក	០៧លើក	០៩លើក	០៨លើក	០៦លើក
សរុប	៦៨៤លើក											

តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០២១

បរិយាយ	មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
ចំនួនគោលដៅ	៨៩	២០	១៨២	គ្មាន	គ្មាន	គ្មាន	គ្មាន	០៦	គ្មាន	៩២	៦៩	៨៨២
ចំនួនមនុស្ស	៣៦១	១៥៣	៧៣៥	គ្មាន	គ្មាន	គ្មាន	គ្មាន	០៦	គ្មាន	២១៦	១១៣	២.៥៩៩
ចំនួនស្ត្រី	២៤៨	១២៩	៦៥៩	គ្មាន	គ្មាន	គ្មាន	គ្មាន	០៦	គ្មាន	១៤៨	១០៨	២.០៨៤
សរុប	**៤.១៧៧នាក់(ស្រី ៣.៥៥៦នាក់)**											

ខ.២.៦. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈរូបភាព រឿបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃប្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យនិងសម្គាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ សរុបចំនួន **៥៣៩**នាក់ មាន **២២**សញ្ជាតិ ក្នុងនោះមាន ចិន ១៧៤នាក់(ស្រី០៣នាក់) កូរ៉េ ២០៥នាក់(ស្រី ៣៨នាក់) អាមេរិក ៨៤នាក់(ស្រី ០៥នាក់) បារាំង ២៦នាក់(ស្រី ០២នាក់) ដាណឺម៉ាក ០១នាក់ កាណាដា ០៩នាក់(ស្រី០២នាក់) អង់គ្លេស ១០នាក់ ថៃ ០២នាក់ ម៉ាឡេស៊ី ០៧នាក់ អេស្ប៉ាញ ០១នាក់ ក្រូអាត ០១នាក់ អូស្ត្រាលី ០២នាក់ អាឡឺម៉ង់ ០៤នាក់(ស្រី ០១នាក់) ជប៉ុន ០៣នាក់ សឹង្ហបុរី ០៣នាក់ ប៉ាគីស្ថាន ០១នាក់ ឥណ្ឌា ០១នាក់ ឥណ្ឌូណេស៊ី ០១នាក់ រុស្សី ០១នាក់ នីហ្សេរីយ៉ា ០១នាក់ ឆេក ០១នាក់ និងវៀតណាម ០១នាក់។

➢ **តែយើងបានធ្វើការសម្គាស និងវាយតំលៃបញ្ជូនឱ្យក្រុមការងារប្រកចេញចូលតែមួយ បានចំនួន ៣៧៦នាក់ ប៉ុណ្ណោះ។**

➢ បានទំនាក់ទំនងតាមទូរស័ព្ទ ទៅពលរដ្ឋខ្មែរដែលរស់នៅសាធារណរដ្ឋកូរ៉េខាងត្បូង ចំនួន **៤៦**នាក់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថា អាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

ខ.៣. កិច្ចការពារ និងការតាមដានពលករដែលចេញទៅធ្វើការនៅក្រៅប្រទេស

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ក្រុមការងាររបស់ក្រសួង បានបន្តសហការជាមួយស្ថានឯកអគ្គរាជទូត/អនុព័ន្ធការងារ/អគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសទទួល ក្នុងការគាំពារពលករ ការផ្តល់អត្ថប្រយោជន៍ និងការសម្របសម្រួលដោះស្រាយបញ្ហាជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសទទួល ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ៖

- **ប្រទេសថៃ** បានចុះ៖ **១**-ចែកស្បៀងអាហារជូនពលកររួបផលវិបាកកំឡុងពេលកូវីដ-១៩ ចំនួន **១.២៧០**នាក់។ **២**-សួរសុខទុក្ខពលកររគ្រោះថ្នាក់ការងារចំនួន ២ទីតាំង ដែលមានពលករចំនួន **៥៧**នាក់ ដោះស្រាយនិងប្រឹក្សាយោបល់តាមទូរស័ព្ទចំនួន **១.១០៩**ខ្សែ។ **៣**-ដោះស្រាយវិវាទជំនួញពលករជាមួយនិយោជក **០១**ករណី ដែលមានពលករ **០២**នាក់។
- **ប្រទេសកាតា** បានចុះ៖ **១**-ជួយសម្រួល និងប្រឹក្សាយោបល់ ដល់ពលករឆ្លងជំងឺកូវីដ-១៩ ដែលបានទំនាក់ទំនងមកកាន់ស្ថានទូត **១០**ករណី សរុបពលករ **៨៦**នាក់។ **២**-ដោះស្រាយវិវាទ និងបញ្ជូនពលករ តាមរយៈសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលគាំពារពលករបរទេស **១៨៦**លើក និងតាមទូរស័ព្ទ **១៨៦**ខ្សែ។ **៣**-ប្រឹក្សាតាមទូរស័ព្ទ និងតាមបណ្តាញសង្គមផ្សេងៗ អំពីច្បាប់ថ្មី

ក៏ដូចជាវិធានការរបស់រដ្ឋាភិបាលកូរ៉េ បញ្ហាការងារ ការស្នាក់នៅបម្រើការងារ និងព័ត៌មានក្នុងការធ្វើដំណើរវិលត្រឡប់មកកម្ពុជាវិញ **២៥០**លើក ក្នុង១ខែ។

- **ប្រទេសជប៉ុន** បានចុះ៖ **១**-ដោះស្រាយបញ្ហាការងាររបស់កម្មសិក្សាការី និងពលករជំនាញ ឱ្យបានការងារធ្វើ **៧៨**ករណី។ **២**-ប្រឹក្សាយោបល់ការងារតាមទូរស័ព្ទ និងPage ស្ថានទូត (ជាមធ្យម ០៣នាក់/១ថ្ងៃ) បាន **៧២០**លើក។
- **ប្រទេសម៉ាឡេស៊ី** បានជួយ៖ **១**-អន្តរាគមន៍ដល់ពលរដ្ឋជាប់ទោស ពលករ/ពលការិនី ឱ្យបានត្រឡប់ទៅកម្ពុជាវិញ ចំនួន **៣៧៦**នាក់(ស្ត្រី **១៦៥**នាក់) ក្នុងនោះកុមារ **៣៩**នាក់(កុមារី **១៧**នាក់)។ **២**-សម្របសម្រួលឯកសារ និងទាមទារប្រាក់ឧបត្ថម្ភពីថៅកែទុកនេសាទ ជូនក្រុមគ្រួសាររបស់សពពលករនេសាទ ដែលបានស្លាប់ដោយឧប្បទ្ទវហេតុក្នុងពេលធ្វើការ ០១ករណី។ **៣**-សម្របសម្រួលឯកសារធ្វើដំណើរជូនពលករកម្ពុជាដែលជាប់ឃុំ តាមមន្ទីរឃុំឃាំងនានា ឱ្យបានត្រឡប់ទៅកម្ពុជាវិញចំនួន **២២០**នាក់។ **៤**-សម្របសម្រួល និងសហការជាមួយអង្គការចាប់ដៃ IJM និងអង្គការ IOM ជួយឧបត្ថម្ភថ្លៃសំបុត្រយន្តហោះសម្រាប់ពលករជាប់ឃុំឱ្យបានត្រឡប់ទៅកម្ពុជាវិញ ចំនួន **២៥**នាក់ និងពលការិនីរងគ្រោះ **០៩**នាក់។ **៥**-សហការជាមួយអង្គការអឌ្ឍចន្ទក្រហមម៉ាឡេស៊ី និងអង្គការ Our Journey រៀបចំ និងសម្របសម្រួលការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនទី២ ដល់ពលរដ្ឋ ពលករ ពលការិនី ខ្មែរដែលពុំមានឯកសារស្នាក់នៅ និងធ្វើការស្របច្បាប់ចំនួន **១០០**នាក់ នៅរដ្ឋ Selangor។

▪ **ក្រសួងកិច្ចការនារី៖** ក្រុមការងារនាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី បានធ្វើការបញ្ជូន**០៣**ករណី និងសម្របសម្រួលដល់គ្រួសាររបស់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សនៅចិន ទៅដាក់ពាក្យប្តឹងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ និងសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងផ្តល់ការប្រឹក្សាដោយផ្ទាល់ដល់ស្ត្រីរងគ្រោះនៅចិនតាម Wechat, Telegram, Facebook រហូតធ្វើមាតុភូមិនិវត្តន៍មកដល់កម្ពុជាដោយសុវត្ថិភាព ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

▪ **ស្ថានអគ្គកុងស៊ុល** ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម សហការជាមួយអាជ្ញាធរវៀតណាម បញ្ជូននារីខ្មែរពពោះជំនួស ដែលបម្រុងឆ្លងទៅប្រទេសចិន **០២**នាក់ មកកម្ពុជាវិញ ដោយប្រគល់ជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង នៅច្រកទ្វារព្រំដែនអន្តរជាតិបាវិត-ម៉ុកបាយ។

ខ.៨. ការគ្រប់គ្រងពលករបរទេសដែលចូលមកធ្វើការនៅកម្ពុជា

ចំពោះការងារគ្រប់គ្រងការប្រកបមុខរបររបស់ជនបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១នេះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានសហការជាមួយអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះធ្វើអធិការកិច្ចពលកម្មនៃជនបរទេស នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាសនានា បានចំនួន **២.៩៦៦**គោលដៅ មានជនបរទេស **២៨.៨៦៣**នាក់ រកឃើញករណី ពុំមានប័ណ្ណអនុញ្ញាតការងារ ចំនួន **៤៦៦**នាក់ និងបានធ្វើការផាកពិន័យតាមនីតិវិធីច្បាប់ សរុបជាទឹកប្រាក់ **២៣៣.០០០.០០០**រៀល។

ធៀបទៅនឹងឆ្នាំ២០២០ ទិន្នន័យពលករបរទេសមកធ្វើបណ្ណាការងារ នៅអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួន **១០០.៦៩៨**នាក់ ថយចុះ **២៣៨**នាក់ ស្មើនឹង **0,២៣%**។

ខ.៩. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

ក. ជាក់ជាតិ៖

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានយកចិត្តទុកដាក់ខិតខំអនុវត្តលើការងារកុមារដោយផ្អែកលើគោលការណ៍ចម្បងបីគឺ (**១**)ដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឱ្យកុមារទទួលបានការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ (**២**)កិច្ចសហការជាមួយអង្គការសង្គមស៊ីវិលមានានា ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរស្ត្រី និងកុមារ (**៣**)ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពការងារកុមារ។ ទន្ទឹមនឹងនេះ ក្រសួងបាន៖

- ចុះធ្វើអធិការកិច្ចការងារសាមញ្ញតាមបណ្តាសិប្បកម្មផលិតឥដ្ឋចំនួន **៤៥**លើក ក្នុងនោះមាន រាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ សៀមរាប និងខេត្តកណ្តាល ដោយពិនិត្យឃើញថាពុំមានការប្រើប្រាស់ពលកម្មកុមារ ការងារដោយបង្ខំ និងទេសភាពបំណុលទេ។
- រៀបចំកែសម្រួលកម្រងសំនួរក្នុងបញ្ជីត្រួតពិនិត្យតាមដានពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងចម្ការដំឡូងមី។
- រៀបចំគោលការណ៍ប្រតិបត្តិ សម្រាប់កម្មការវ័យក្មេងទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មសាធារណៈចំនួន ០២គឺ៖ បញ្ជីប្រភេទការងារសម្រាប់កម្មការ និយោជិតវ័យក្មេង អាយុពី ១២ឆ្នាំ ដល់ក្រោម ១៥ឆ្នាំ និង បញ្ជីប្រភេទការងារប្រកបដោយគ្រោះថ្នាក់ សម្រាប់កម្មករ និយោជិតវ័យក្មេង អាយុពី ១៥ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។
- ចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ចម្ការដំឡូងមី និងចម្ការអំពៅ ចំនួន **១៧០**លើក។
- អនុវត្តកិច្ចអន្តរាគមន៍ស្នូលទប់ស្កាត់ពលកម្មកុមារបានចំនួន **៣៥០**ករណី ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ចម្ការដំឡូងមី លើខេត្តចំនួន៥ រួមមានខេត្តកំពង់ចាម ត្បូងឃ្មុំ សៀមរាប ពោធិ៍សាត់ បាត់ដំបង។

• **ថ្នាក់ក្រោមជាតិ៖**

▪ **រាជធានីភ្នំពេញ៖** មន្ទីរទេសចរណ៍ បានបញ្ជ្រាប និងផ្សព្វផ្សាយពីការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានលើស្ត្រី និងកុមារ ក្នុងវិស័យទេសចណ៍ តាមរយៈការចុះត្រួតពិនិត្យ និងវាយតម្លៃបច្ចុប្បន្នភាព វិធានការសុវត្ថិភាពទេសចរណ៍ ស្របតាមនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) នៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ដូចជា ភោជនីយដ្ឋាន អាហារដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ អាផាតមិន ជាពិសេសមណ្ឌលកម្សាន្តមនុស្សពេញវ័យ ឌីស្កូតែក មុននឹងអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ ចំនួន **៣៦៥**ទីតាំង។

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ដោយដកហូតកុមារ ចំនួន **០៦**នាក់(ស្រី **០៤**នាក់) និងទប់ស្កាត់កុមារ ចំនួន **១២៤**នាក់(ស្រី **៦៩**នាក់)។

▪ **ខេត្តត្បូងឃ្មុំ**៖ មន្ទីការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ចុះអប់រំ ធ្វើកិច្ចសន្យា និងដាក់ស្លាកសញ្ញាហាមក្មេងចូលបរិវេណឡឥដ្ឋ ដោយបានបិទផ្សាយសេចក្តីណែនាំលេខ០៥៦ នៅកន្លែងសិប្បកម្ម ចំនួន **០២**លើក បាន **២៣**សិប្បកម្ម។

▪ **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ ចំនួន **១.១៣៣**នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

▪ **ខេត្តតាកែវ៖** មន្ទីរទេសចរណ៍ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះបញ្ជ្រាបការផ្សព្វផ្សាយច្បាប់បង្ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងការជួញដូរផ្លូវភេទលើស្ត្រី និងកុមារ ផលប៉ះពាល់នៃការធ្វើចំណាក ស្រុកខុសច្បាប់ ក្នុងវិស័យទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មនានា និងសេវាកម្ម ទេសចរណ៍ បានចំនួន **៣៨**កន្លែង និងនៅតាមបណ្តាលរោងចក្រ សហគ្រាស និងសិប្បកម្មសរុបចំនួន **៤៩**លើក មានអ្នកចូលរួមចំនួន **៣៤៨**នាក់(ស្រី **២២០**នាក់)។

▪ **ខេត្តមន្ទាយមានជ័យ៖** បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការទប់ស្កាត់ការជួញដូរ និងរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈការត្រួតពិនិត្យវិធានសុវត្ថិភាពទេសចរណ៍ នៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ ក្នុងខេត្តបានចំនួន **២៨៤**កន្លែង។

▪ **ខេត្តបាត់ដំបង៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់ទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសិប្បកម្មឡឥដ្ឋចំនួន ០៨កន្លែង ដែលមានកម្មករនិយោជិតសរុបចំនួន **១០៥**នាក់(ស្រី **៦២**នាក់)

ក្នុងនោះមានកម្មករចំនួន ៣០គ្រួសារ រួមទាំងមានកុមារដែលស្នាក់នៅក្នុងបន្ទុកគ្រួសារចំនួន **៤៥**នាក់(ស្រី **២០**នាក់) (មានអាយុចាប់ពី ០៣ឆ្នាំ ដល់ ១៣ឆ្នាំ)។

▪ **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡ្ង កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន **៨០**កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំង ពលកម្មកុមារទេ។

▪ **ខេត្តក្រចេះ៖** **១.**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន **២៤**លើក។ **២.**មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយអំពីខ្លឹមសារ ការកេងប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ(ពិសេសកុមារ) តាមបណ្តាសិប្បកម្មស្រាល នៅស្រុកព្រែកប្រសព្វ បានចំនួន **២៩**មូលដ្ឋាន មានបុគ្គលិកចំនួន **១២០**នាក់(ស្រី **៥០**នាក់)។

▪ **ខេត្តរតនគិរី៖** ក្រុមការងាររលេខាធិការដ្ឋានខេត្ត មានមន្ទីរនានាដែលពាក់ព័ន្ធ បានចុះធ្វើអធិការកិច្ចដើម្បីផ្សព្វផ្សាយស្តីពី ច្បាប់ការងារ និងការបង្ការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ដល់បណ្តាក្រុមហ៊ុន និងសហគ្រាសនានា ត្រូវអនុវត្តលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ និងមិនត្រូវប្រើប្រាស់ពលកម្មកុមារ។

▪ **ខេត្តមណ្ឌលគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ច ដើម្បីផ្សព្វផ្សាយស្តីពី ច្បាប់ការងារ និងការបង្ការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ដល់បណ្តាលក្រុមហ៊ុន សហគ្រាស បានចំនួន **០៧**សហគ្រាស។

▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះ៖ **១-**ណែនាំផ្សព្វផ្សាយករណីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅតាមឡឥដ្ឋ ក្នុងនោះមានកុមារចំនួន **២០០**នាក់ ហើយមន្ទីរ បានឱ្យថៅកែធ្វើកិច្ចសន្យាលើការប្រើពលកម្មកុមារនេះ។ **២-**តាមរោងចក្រសហគ្រាសចំនួន **១៨** កន្លែង ក្នុងនោះបានរកឃើញ ០១ករណី ដែលជាអនីតិជន ។ **៣-**ធ្វើការផ្សព្វផ្សាយដល់កម្មករសំណង់ចំនួន **៣**លើក កន្លែងលាងឡាន និងកន្លែងកំសាន្តមួយចំនួន ដើម្បីទប់ស្កាត់នូវពលកម្មកុមារ។ **៤-**ផ្សព្វផ្សាយដល់សហគមន៍ស្តីអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដានការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ០ ដល់៣ឆ្នាំ តាមភូមិគោលដៅចំនួន៤ ក្នុងឃុំអំពិល ក្នុងស្រុកកំពង់សៀម មានអ្នកចូលរួមសរុប **១១៦** នាក់(ស្រី **៨៥**នាក់)។

▪ **ខេត្តកំពង់ឆ្នាំង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះផ្សព្វផ្សាយ និងតាមដានការអនុវត្តន៍សេចក្តីណែនាំលេខ១៤៧/២១ ស ណ ន របស់រដ្ឋបាលខេត្ត ស្តីពីការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងបានផ្សព្វផ្សាយស្តីពី ច្បាប់ការងារ និងការបង្ការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ការជួញដូរ ការកេងប្រវ័ញ្ចកំលាំងពលកម្មស្ត្រី និងកុមារ នៅតាមរោងចក្រសហគ្រាស បានចំនួន **១១**លើក ស្មើនឹង **១៤**រោងចក្រ សហគ្រាស ដោយមានការចូលរួម **១៥៦**នាក់(ស្រី **៧៦**នាក់)។

ខ.៦. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

ជាយន្តការសម្រាប់គ្រប់គ្រងពលករខ្មែរដែលចេញទៅធ្វើការនៅក្រៅប្រទេស ក្រសួងពាក់ព័ន្ធសំខាន់ចំនួន០៣ គឺ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចទទួលខុសត្រូវចំពោះសុវត្ថិភាព ផលប្រយោជន៍ និងការគោរពសិទ្ធិពលករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យ លេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងប្រកាសចំនួន ០៨ ដើម្បីកំណត់តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករ និងយន្តការនៃការដោះស្រាយបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍។

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើបច្ចុប្បន្នភាពទីភ្នាក់ងារជ្រើសរើសពលករជាប្រចាំ និងបានផ្សព្វផ្សាយទូលំទូលាយតាមប្រព័ន្ធឌីជីថល(វិបសាយ និងហ្វេសប៊ុក) ថែមទៀត។ ជាការកត់សម្គាល់ចំនួនទីភ្នាក់ងារជ្រើសរើសឯកជន មាន១២៦ និងបានធ្វើសកម្មភាពដោយផ្តោតការយកចិត្តទុកដាក់លើការ

ដោះស្រាយបញ្ហាដែលពលករកំពុងប្រឈមក្នុងប្រទេសគោលដៅជាជាងការជ្រើសរើសពលករថ្មី ដើម្បីបញ្ជូនទៅក្នុងអំឡុងពេលរឹតបន្តឹងដោយវិបត្តិកូវីដ-១៩ និងមានវិធានការដូចជា៖

-ក្នុងចំណោមទីភ្នាក់ងារទាំង ១២៦ ត្រូវបានចងក្រងជាសមាគមចំនួនពីរ គឺ (១).សមាគមទីភ្នាក់ងារជ្រើសរើសពលករ(ACRA) (២).សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងផ្សព្វផ្សាយអំពីគោលការណ៍ផ្សេងៗ។

-ក្រសួងបានជួបប្រជុំផ្សព្វផ្សាយដល់ទីភ្នាក់ងារជ្រើសរើសឯកជនចំនួន៧៥ អំពីគោលការណ៍ជ្រើសរើសប្រកបដោយក្រមសីលធម៌(IRIS Ethical Recruitment) ដែលផ្តោតសំខាន់លើការមិនយកថ្លៃឈ្នួលពីពលករ នៅក្នុងដំណាក់កាលជ្រើសរើស និងក្នុងដំណាក់កាលដាក់ឱ្យធ្វើការងារ ដែលថ្លៃឈ្នួលទាំងនោះនឹងត្រូវចេញជំនួសដោយនិយោជក។

-ដោយមានកិច្ចសហការពីអង្គការពលកម្មអន្តរជាតិ (ILO) បានជំរុញឱ្យទីភ្នាក់ងារជ្រើសរើសពលកររបង្កើតនូវក្រមសីលធម៌របស់ទីភ្នាក់ងារ ដើម្បីធានានូវគុណភាព និងសុវត្ថិភាពពលករក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍ការងារ។

-ក្រសួងមានប្រព័ន្ធទិន្នន័យសម្រាប់ការចុះបញ្ជីរបស់ទីភ្នាក់ងារ និងរបស់ពលកររដែលត្រូវបានជ្រើសរើសដោយទីភ្នាក់ងារ និងស្ថានភាពការងារក្នុងប្រទេសគោលដៅ ដែលទីភ្នាក់ងារត្រូវផ្តល់របាយការណ៍ជាប្រចាំដល់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម។

-នៅតាមបណ្តាស្ថានទូតនៃបណ្តាប្រទេសគោលដៅ ដែលមានពលករកម្ពុជាបាននិងកំពុងស្នាក់នៅ និងធ្វើការច្រើន ក្នុងនោះមាន ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ប្រទេសជប៉ុន និងប្រទេសម៉ាឡេស៊ី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់បញ្ជូនទីប្រឹក្សាអមស្ថានទូតទទួលបន្ទុកការងារដើម្បីដោះស្រាយបញ្ហាពលករដែលនៅទីនោះ។

-បានដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលកររទៅធ្វើការនៅបរទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដានការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលកររហូតដល់វិលត្រឡប់មកមាតុប្រទេសវិញ។

ខ.៧. ការលើកកម្ពស់ជីវនាព

- **ក្រសួងអភិវឌ្ឍន៍ជនបទ**

គ. ប្រព័ន្ធយុត្តិធម៌ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

គ.១. ការងារអនុវត្តច្បាប់

ក.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប **៣៥៩**ករណី/**១៥៥**ករណី(ប្រៀបធៀបឆ្នាំ២០២០ កើនឡើង **២០៤**ករណី ស្មើនឹង **១៣១,៦០%**)។

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៥៣៨**នាក់/**១៩៣**នាក់(ស្រី **៥២**នាក់)ក្នុងនោះជនសង្ស័យជាអនីតិជន **៤៦**នាក់ និងជនបរទេស **១៤**នាក់ មានជនជាតិ(អាមេរិក ០១នាក់ បារាំង ០១នាក់ ចិន ០៦នាក់ វៀតណាម ០៣នាក់ បែលហ្សិក ០១នាក់ និងបង់ក្លាដែស ០២នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **១.៥៧៧**នាក់/**៤៦៧**នាក់ (ស្ត្រី **៧៦៩**នាក់) អនីតិជន **៣៥៩**នាក់(ស្រី **២៤២**នាក់)ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ **២១១**នាក់ អាយុ១៥-១៧ឆ្នាំ **១៤៨**នាក់ និងអាយុ១៨ឆ្នាំឡើង **១.២១៨**នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **៣២**នាក់ និងប្រគល់ឱ្យគ្រួសារ **១.៥៤៥**នាក់) ក្នុងនោះមានចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **២៣៥**ករណី/**៤៤**ករណី(កើនឡើង **១៩១**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **៤០០**នាក់ (ស្រី **៣៩**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន **១៤**នាក់ និងជនបរទេស ០៨នាក់ មានជនជាតិអាមេរិក ០១នាក់ ចិន ០៤នាក់ វៀតណាម ០២នាក់ និងបែលហ្សិក ០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **១.៣៩០**នាក់(ស្រី **៥៩៥**នាក់)មានអាយុក្រោម១៥ឆ្នាំ **៩៥**នាក់ អាយុ១៥-១៧ឆ្នាំ **១០៥**នាក់ និងអាយុ១៨ឆ្នាំឡើង **១.១៩០**នាក់(ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៣នាក់ និងប្រគល់ឱ្យគ្រួសារ **១.៣៨៧**នាក់)។

តារាងស្ថិតិបទល្មើសជួញដូរមនុស្ស

បទល្មើស	ករណី	ជនរងគ្រោះ	ជនសង្ស័យ	ជនបរទេស
-ការនាំអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់	០៣	០៤	០៥ (អនីតិជន០២នាក់)	
-ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	០២	០៣	០៣	វៀតណាម០១នាក់
-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន	១៩៥	១.១៨៣	៣៣២ (អនីតិជន១០នាក់)	វៀតណាម០១នាក់ ចិន០៣នាក់
-អំពើលក់ដូរមនុស្ស	០៦	០៩	០៨	ចិន០១នាក់
-ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស	២០	១៤៥	៣៣ (អនីតិជន០២នាក់)	
-អំពើលក់ដូរមនុស្សដោយមានគោលដៅ	០២	៣០	០៨	
-អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន	០១	០	០២	
-ការជឹកជញ្ជូនដោយមានគោលដៅ	០១	០៤	០២	
-ការទិញលក់ទារកកុមារ	០៥	១២	០៧	បែលហ្សិក០១នាក់ អាមេរិក ០១នាក់
សរុប	*២៣៥ ករណី*	*១.៣៩០នាក់*	*៤០០នាក់ (អនីតិជន១៤នាក់)*	*០៨នាក់*

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **១២៤**ករណី/**១១១**ករណី(កើន **១៣**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៣៨**នាក់ (ស្រី **១៣**នាក់)ក្នុងនោះជនសង្ស័យជាអនីតិជន **៣២**នាក់ ជនបរទេស **០៦**នាក់ មានជនជាតិបារាំង **០១**នាក់ វៀតណាម **០១**នាក់ ចិន **០២**នាក់ បង់ក្លាដេស **០២**នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **១៨៧**នាក់(ស្រី **១៧៤**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **១១៦**នាក់ អាយុ ១៥-១៧ឆ្នាំ **៤៣**នាក់ និងអាយុ១៨ឆ្នាំឡើង **២៨**នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច **២៩**នាក់ និងប្រគល់ឱ្យគ្រួសារ **១៥៨**នាក់)។

តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ

បទល្មើស	ករណី	ជនរងគ្រោះ	ជនសង្ស័យ	ជនបរទេស
-ការចាប់ពង្រាត់ ការឃុំឃាំង ឬបង្ខាំង	០១	០២	០៤	ចិន ០២ បង់ក្លាដេស ០២
-សញ្ជារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ)	១១	៥៥	១៣ (ជាអនីតិជន ០២នាក់)	វៀតណាម ០១នាក់
-សញ្ជារកម្ម(មានអនីតិជន)	០២	០៩	០៣	
-សញ្ជារកម្ម	០១	០	០១	
-ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ	០១	០៣	០១	
-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ	៨៦	៩៣	៩២ (ជាអនីតិជន ២៥នាក់)	បារាំង ០១នាក់
-រូបភាព និងសម្ភារអាសអាភាសនៃកុមារ	០១	០១	០៣ (ជាអនីតិជន ០៣នាក់)	
-រូបភាព និងសម្ភារអាសអាភាស	០៤	០៤	០៤	
-អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ	១៧	២០	១៧ (ជាអនីតិជន ០២នាក់)	
សរុប	*១២៤ករណី*	*១៨៧នាក់*	*១៣៨នាក់ (អនីតិជន៣២)*	*០៦នាក់*

➢ (សូមពិនិត្យតារាងលំអិតនៅ ឧបសម្ព័ន្ធទី១)

ក.១.២. ការបង្ក្រាបករណីនាំទារកឆ្លងដែនខុសច្បាប់

▪ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបង្ក្រាបករណីនាំយកទារកឆ្លងដែនដោយមិនស្របច្បាប់បាន **០១**ករណី មានទារកចំនួន **០៣**នាក់ ដើម្បីនាំចេញទៅប្រទេសចិន និងបានឃាត់ខ្លួនជនសង្ស័យជាជនជាតិចិនចំនួន **០៣**នាក់(ស្រី) នៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ និងបានកសាងសំណុំរឿង និងជនសង្ស័យបញ្ជូនទៅតុលាការ។

ក.២. កិច្ចការយុត្តិធម៌

ក.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម ផ្លូវភេទ។ ផ្អែកលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

១. <u>ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុបមានចំនួន **៥៣២**ករណី(ក្នុងនោះមានសំណុំរឿងសល់ពីមុន**១៥**ករណី) ជនរងគ្រោះចំនួន **៦១៩**នាក់ (ស្រី **២៦៧**នាក់) ក្នុងនោះមានអនីតិជន **២០៤**នាក់(ស្រី **១៨៦**នាក់) និងអញ្ញាតជន **៣៣**នាក់ ជនល្មើសមានចំនួន **៨១៥**នាក់(ស្រី **១២៥**នាក់) ក្នុងនោះមានអនីតិជន **៣៨**នាក់(ស្រី **០៦**នាក់) និងអញ្ញាតជន **០៣**នាក់ ហើយបានចំណាត់ការដោយបញ្ជូនទៅស៊ើបសួរចំនួន **៤២៥**ករណី បញ្ជូនរឿងទៅជម្រះផ្ទាល់**០១**ករណី នីតិវិធីបង្ហាញខ្លួនភ្លាម **០១**ករណី តម្កល់ទុកឥតចាត់ការ **១៩**ករណី និងកំពុងចាត់ការចំនួន **៨៦**ករណី។

២. <u>ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុបមានចំនួន **៥២៣**ករណី(សំណុំរឿងសល់ពីមុន **៥៥**ករណី) ជនរងគ្រោះចំនួន **៥៣០**នាក់ (ស្រី **២២៤**នាក់) ក្នុងនោះមានអនីតិជន **២១០**នាក់(ស្រី **១៧៤**នាក់) និងអញ្ញាតជន **០៣**នាក់ ជនត្រូវចោទមានចំនួន **៨៦៥**នាក់(ស្រី **១៤០**នាក់) ក្នុងនោះមានអនីតិជន **៥៧**នាក់(ស្រី **១៣**នាក់) និងអញ្ញាតជន **០៤**នាក់ ស្ថិតក្រោមការត្រួតពិនិត្យផ្លូវតុលាការចំនួន **០៦**នាក់(ស្រី **០១**នាក់) ក្នុងនោះបានចំណាត់ការបញ្ជូនទៅជម្រះចំនួន **២៥៩**ករណី លើកលែងចោទ **០៥**ករណី និងកំពុងចាត់ការចំនួន **២៥៩**ករណី។

៣. <u>ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត</u>៖

សរុបមានចំនួន **៤៣៤**ករណី(សំណុំរឿងសល់ពីមុន **៥០ករណី**) ជនរងគ្រោះចំនួន **៤២០**នាក់(ស្រី **១៩៣**នាក់) ក្នុងនោះមានអនីតិជន **១៦៩**នាក់(ស្រី**១៥១**នាក់) និងអញ្ញាតជន **០២**នាក់ ជនជាប់ចោទសរុប **៧១៦**នាក់(ស្រី **៨២**នាក់) ក្នុងនោះមានអនីតិជន **២៣**នាក់(ស្រី **០១**នាក់) បានជម្រះ **២០០**ករណី ផ្ទេរសមត្ថកិច្ច **០៣**ករណី និងប្រភេទចំណាត់ការ(លើកលែងចោទសំណុំរឿង **០៦**ករណី ចំនួនមនុស្ស **០៨**នាក់ ពិន័យជាប្រាក់ **១០**ករណី ផ្តន្ទាទោសដាក់ពន្ធនាគារ **១៧០**ករណី(ចំនួនមនុស្ស **៥៩**នាក់) ព្យួរទោសសាកល្បង **០៣**នាក់ ព្យួរទោសធម្មតា **២១**ករណី ចំនួនមនុស្ស **២២**នាក់ សរុបចាត់ការរួច **២០៣**ករណី និងកំពុងចាត់ការ **២៣១**ករណី បណ្តឹងឧទ្ធរណ៍ **០១**ករណី)។

- **(តារាងលំអិតដំណាក់កាលទាំង៣ មានក្នុងឧបសម្ព័ន្ធទី ២)**

ក.២.២. ការងារដំណោះស្រាយវិវាទការងារអាងពលករទៅធ្វើការនៅក្រៅប្រទេស និងក្រុមហ៊ុនជ្រើសរើសពលករ

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម** បានដោះស្រាយតាមពាក្យបណ្តឹងរបស់ពលករចំនួន **០៤**នាក់ ក្នុងករណីដែលពួកគាត់បានបង់ប្រាក់ទៅអោយក្រុមហ៊ុន CPS Best Team Service ដើម្បីបញ្ជូនពួកគាត់ទៅធ្វើការនៅប្រទេសថៃ តែក្រុមហ៊ុនមិនបានធ្វើតាមកិច្ចសន្យា ដូច្នេះត្រូវបានដោះស្រាយឱ្យពួកគាត់បានទទួលសំណងប្រាក់មកវិញគ្រប់ចំនួន និងសុំដកពាក្យបណ្តឹង។
  - **នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម** បានជួយសម្រួលដោះស្រាយវិវាទការងារ បានចំនួន **០៥**ករណី ដែលមានពលករចំនួន **១៦**នាក់(ស្រី **០៦**នាក់)។
  - **ក្រុមអនុព័ន្ធការងារ** បានជួយសម្របសម្រួល៖ **១**-ដោះស្រាយវិវាទការងារជូនពលករ និងនិយោជកចំនួន**២**នាក់ដែលធ្វើការនៅប្រទេសថៃ **០១**ករណី។ **២**-អន្តរាគមន៍ដល់ពលករ ពលការិនី នៅប្រទេសម៉ាឡេស៊ី ឱ្យបានត្រឡប់ទៅកម្ពុជាវិញសរុបចំនួន **៣៦៦**នាក់(ស្ត្រី**១៦០**នាក់) ក្នុងនោះកុមារចំនួន**៣៨**នាក់(កុមារី**១៦**នាក់) និងជួយសម្រួលធ្វើឯកសារដល់ពលករដែលជាប់ទោសនៅតាមមន្ទីរឃុំឃាំងនានាចំនួន **២២០**នាក់។ **៣**-សម្របសម្រួលឯកសារទាមទារប្រាក់ឧបត្ថម្ភពីថៅកែទូក

នេសាទ(ប្រទេសម៉ាឡេស៊ី) ជូនក្រុមគ្រួសាររបស់សពពលករនេសាទ ដែលបានស្លាប់ដោយឧប្បទ្ទវហេតុក្នុងអំឡុងពេលធ្វើការ ០១ករណី។

ឃ .កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១. ការទទួល និងសម្គាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

ឃ.១.១. ការទទួល និងសម្គាសន៍ពលករបញ្ជូនត្រឡប់

▪ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះ ឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋមរកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថា សង្ស័យជាករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ សរុបចំនួន **៨.៣៧០**នាក់(ស្រី **៣.៦០៦**នាក់) ក្នុងនោះសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស **៣៦៤**នាក់(ស្រី **៣៦៣**នាក់) ដូចមានក្នុងតារាងខាងក្រោម៖

ល.រ.	ប្រទេសគោលដៅ	មូលហេតុនៃការវិលត្រឡប់	សរុប	ស្រី
១	ម៉ាឡេស៊ី	ពលករខុសច្បាប់	៤៤៣	២២០
២	ចិន	សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់	៣៦៤	៣៦៣
៣	សឹង្ហបុរី	ទ្រាំការងារមិនបាន	០៩	០៩
៤	វៀតណាម	ឆ្លងដែនខុសច្បាប់	៣៩៤	១៩១
៥	ថៃ	ពលករខុសច្បាប់	៦.៩៥១	២.៧១៤
៦	ឡាវ	ឆ្លងដែនខុសច្បាប់	៥១	១៩
៧	ឥណ្ឌា	ឆ្លងដែនខុសច្បាប់	១៤៦	៨២
៨	ឥណ្ឌូណេស៊ី	ឆ្លងដែនខុសច្បាប់	០១	០១
៩	មីយ៉ាន់ម៉ា	ឆ្លងដែនខុសច្បាប់	០៤	០២
សរុប			**៨.៣៧០ នាក់**	**៣.៦០៦ នាក់**



▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

▪ **ក្រុមការងារការពារជនរងគ្រោះ** ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ និងទទួលពីប្រទេសនានា សរុបចំនួន **៤០៤**នាក់(ស្ត្រី **៣១៦**នាក់ កុមារា **០៧**នាក់ កុមារី **៤៤**នាក់) មកពីប្រទេស៖ ចិន **៣១៧**នាក់ វៀតណាម(ឆ្លងទៅចិន) **១៤**នាក់ ថៃ **៣៤**នាក់ ឥណ្ឌូនេស៊ី **០១**នាក់ ម៉ាឡេស៊ី **៣៤**នាក់ និងសឹង្ហបូរី **០៤**នាក់ ក្នុងនោះមានករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម **៣០**នាក់ ជួញដូរ

កម្លាំងពលកម្ម **៣៨**នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ **៣០៤**នាក់ និងករណីសង្ស័យថាជាងគ្រោះ **៣២**នាក់) បន្ទាប់ពីសម្ភាសន៍រួចបានបញ្ជូនទៅទទួលសេវានៅអង្គការដៃគូ និងបញ្ជូនទៅសហគមន៍វិញ។

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលបានទទួលពីនគរបាលមានសមត្ថកិច្ចនៅក្នុងស្រុក សរុបចំនួន **០៨**នាក់(ស្ត្រី **០៣**នាក់ កុមារា **០៣**នាក់) ក្នុងនោះមានជនជាតិភូមា **០២**នាក់ (ករណីសង្ស័យថាជាងគ្រោះ) ជនជាតិវៀតណាម **០៣**នាក់ កុមារា **០៣**នាក់ (ករណីជួញដូរមនុស្ស) បានបញ្ជូនបន្តទៅទទួលសេវាបណ្តោះអាសន្ននៅអង្គការ IJM, Caritas Cambodia, AIM មុនពេលធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសកំណើតវិញ។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**

ដោយឡែក តាមច្រកទ្វារអន្តរជាតិ និងច្រកទ្វារព្រំដែនអន្តរជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរនៃប្រទេស ចំនួន០៨ បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **១៧.៦២៧**នាក់ ក្នុងនោះមកពីប្រទេសថៃ **១៧.១៧១**នាក់ ចិន **២៧២**នាក់ វៀតណាម **៩៨**នាក់ ម៉ាឡេស៊ី **៤៩**នាក់ ឡាវ **២៥**នាក់ កូរ៉េខាងត្បូង **០៧**នាក់ អាមេរិក **០៤**នាក់ និងចិនតៃវ៉ាន់ **០១**នាក់។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ ៖**

នាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួល និងសម្ភាសជនរងគ្រោះ និងជនទេសន្តរប្រវេសន៍ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ **ចំនួន ២៩៦**នាក់(**ស្រី ២៧៦**នាក់) អនីតិជន **០៨**នាក់(ស្រី**០៤**នាក់) ក្នុងនោះមកពី៖

- ប្រទេសចិនចំនួន **២៧៣**នាក់(ស្រី **២៧៦**នាក់) (រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ **២៧៦**នាក់ និងអនីតិជនទៅតាមម្តាយ **០១**នាក់)។
- ប្រទេសម៉ាឡេស៊ីចំនួន **១៣**នាក់(ស្រី **០២**នាក់) (រងគ្រោះដោយវិទាការងារ **០២**នាក់ និងស្នាក់នៅខុសច្បាប់ **១១**នាក់)។
- សឹង្ហបូរី **០១**នាក់(ស្នាក់នៅខុសច្បាប់) ឥណ្ឌូណេស៊ី **០១**នាក់(ស្នាក់នៅខុសច្បាប់) និងបង់ក្លាដេស **០៤**នាក់(រងគ្រោះដោយវិទាការងារ)

លទ្ធផលបំភ្លឺជនរងគ្រោះទាំងនោះ ទៅតាមរយៈមេខ្យល់ផ្សេងៗគ្នា ដែលមិនស្គាល់អត្តសញ្ញាណបច្ចុប្បន្នជនរងគ្រោះប្រគល់ឲ្យមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា។

ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់

- **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានទទួលសពពលរដ្ឋមកពីប្រទេសថៃ តាមច្រកប៉ោយប៉ែតបានចំនួន **២១**សព(ស្រី**០៦**សព) និងបញ្ជូនសពជនជាតិថៃទៅប្រទេសខ្លួនវិញ ចំនួន **០២**សព(ស្រី **០១**សព)។

ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស



▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) ក្រុមការងារការពារជនរងគ្រោះ** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **១.៨០៨**នាក់ (ស្ត្រី **៣១៣**នាក់ កុមារា **៧៥៨**នាក់ កុមារី **៧២២**នាក់) ជាករណី(**សង្ស័យថារងគ្រោះ ១.១០៣នាក់**) ក្នុងនោះមាន មន្ទីរស.អ.យ រាជធានី ខេត្ត **១០៦**នាក់ និងអង្គការដៃគូ **១.៧០២**នាក់។

យ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ នឹងជនសង្ស័យថារងគ្រោះ

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន **៣១៧**នាក់ (ស្ត្រី **២៤៣**នាក់ កុមារី **៤៩**នាក់) ក្នុងនោះជាករណី (**ជួញដូរកម្លាំងពលកម្ម ៤៣នាក់ អាពាហ៍ពិពាហ៍ ផ្ទុយពីធន្ទះ/បង្ខំ ២៧០នាក់ និងជួញដូរផ្លូវភេទ ០៤នាក់**)។
- ក្រុមការងារ ស.អ.យ ក៏បានសហការជាមួយមន្ត្រីជំនាញរបស់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ អង្គការក្តីសង្ឃឹមនិងយុត្តិធម៌ និងអង្គការមេត្រីអន្តរជាតិ(AIM) បានធ្វើសមាហរណកម្មស្ត្រីជនជាតិវៀតណាម មាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ ចំនួន**០៥**នាក់(ស្ត្រី)។
- បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន **៨០**នាក់(ស្ត្រី **៤៧**នាក់) ក្នុងនោះនៅអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា **០២**នាក់ អង្គការក្តីសង្ឃឹម និងយុត្តិធម៌ **១៦**នាក់ អង្គការរតនៈអ៊ីនធើណេសិនណល **៤៩**នាក់ និងអង្គការសម្ព័ន្ធចាប់ដៃ **១៣**នាក់។ ដោយឡែក គិតដល់ចុងឆ្នាំ២០២១ នេះ អង្គការសម្ព័ន្ធចាប់ដៃ បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន **៩១**នាក់បន្ថែមទៀត។ ដូច្នេះសរុបមកមាន **១៧១**ករណី ដែលបានបិទរួចហើយ។

▪ **ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៃគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ** បានធ្វើសមាហរណកម្មជនជាតិថៃចំនួន **១៤៣**នាក់(ស្រី **៥៦**នាក់) និងជនជាតិវៀតណាមចំនួន **០៤**នាក់(ស្រី **០២**នាក់) មាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ។

III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

ក. ការចារបណ្តុះបណ្តាល និងសិក្ខាសាលា

ក.១. ការងារបណ្តុះបណ្តាល

ក.១.១. ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន **១៧៩**វគ្គ មានសិក្ខាកាមចូលរួមចំនួន **៦.៩៦៩**នាក់ ក្នុងនោះមានស្ត្រី **២.២១២**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

តារាងវគ្គបណ្តុះបណ្តាល

ថ្នាក់ជាតិមាន ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិមាន រាជធានី-ខេត្ត (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូមាន អង្គការ ILO, អង្គការជំនួយផ្លូវច្បាប់ដល់កុមារ (LSCW), អង្គការសម្ព័នចាប់ដៃ, អង្គការសកម្មភាពដើម្បីកុមារ(APLE), អង្គការ IOM, អង្គការមូលនិធិអេ២១, អង្គការវិវើល/ជីវីស៊ី, អង្គការមូលនិធិហាការអន្តរជាតិ, អង្គការASEAN-ACT និងអង្គការបេសកកម្មុយត្តិធម៌(IJM), អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា, អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី(LSWCW), អង្គការម៉ារីតាន់ភឹស, អង្គការ AICHR- ASEAN, អង្គការ Legal Aids អង្គការបន្ទាយស្រី និងអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បានរៀបចំបើកវគ្គបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្ត ស្តីពី៖

-១/ប្រព័ន្ធអន្តរជាតិ នៃការជ្រើសរើសពលករដោយសុចរិត (IRIS) ដល់ទីភ្នាក់ងារជ្រើសរើសពលករ។ ២/"ការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើ"។ ៣/ប្រព័ន្ធស្វ័យប្រវត្តិកម្មអធិការកិច្ចពលកម្មកុមារ។

-ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សាលើស្ត្រី និងកុមារ ការកេងកម្លាំងពលកម្ម ការធ្វើចំណាកស្រុកខុសច្បាប់ និងកិច្ចការពារកុមារ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទាំងប្រទេស។

-ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នីតិវិធីអនីតិជនទំនាក់នឹងច្បាប់ និងការសម្ភាសបែបកុមារមេត្រី។

-កិច្ចការពារជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រី ស.អ.យ ក្រុង/ស្រុក/ខេត្ត ។

-ការពិគ្រោះយោបល់តាមបែបដោះស្រាយបញ្ហា ជាលើកទី ៤ ក្នុងគោលបំណងផ្តល់ចំណេះដឹង និងជំនាញវិជ្ជាជីវៈច្បាស់លាស់ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងផ្តល់សេវាចាំបាច់ ឆ្លើយតបសម្រាប់ស្ត្រីពលករចំណាកស្រុក ដើម្បីរកការងារធ្វើនៅប្រទេសគោលដៅ និងប្រទេសកំណើតដែលជួបប្រទះបញ្ហាអំពើហិង្សាលើស្ត្រី អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ល។ ស្តីពីរបៀបធ្វើផែនការឆ្លើយតបដល់គ្រួសារងាយរងគ្រោះ និងគ្រួសារដែលទើបវិលត្រឡប់មកពីប្រទេសថៃ។

-"ការយកចិត្តទុកដាក់ចំពោះយេនឌ័រ នៅពេលធ្វើការជាមួយស្ត្រីជាជនរងគ្រោះដោយសារការជួញដូរមនុស្ស"។ "ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ"។ និង"ការសម្ភាសន៍កុមាររងគ្រោះបែបកោសល្យវិច័យដល់អង្គការដៃគូ"។

-ការគ្រប់គ្រងទិន្នន័យពលករចំណាកស្រុកក្រៅប្រទេស និងការរៀបចំរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

-របៀបធ្វើផែនការឆ្លើយតបដល់គ្រួសារងាយរងគ្រោះ និងគ្រួសារដែលទើបវិលត្រឡប់មកពីប្រទេសថៃ។

-ទេសន្តរប្រវេសន៍ និងការជ្រើសរើសពលករប្រកបដោយក្រមសិលធម៌ ដល់អាជ្ញាធរមូលដ្ឋាន និងតំណាងទីភ្នាក់ងារជ្រើសរើសពលករ។

-បំណិនជីវិត និងច្បាប់ ស្តីពីការងារ សុខភាព ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួយសង្គ្រោះ។

-ការគ្រប់គ្រង និងការបញ្ជូនករណីរងគ្រោះដោយអំពើជួញដូរមនុស្ស។ និងនីតិវិធីស៊ើបអង្កេតករណីអំពើជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ។

ល.រ	សកម្មភាពរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ	ចំនួនវគ្ត	សិក្ខាកាមសរុប	សិក្ខាកាមនារី
១	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	២៤	៥៨៧	៣៥
២	ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	០៨	៣២៤	៨៦
៣	ក្រសួងកិច្ចការនារី	០២	១៦៦	១០៩
៤	អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ	០៦	៥៩៦	២៣៣
៥	ខេត្តព្រះវិហារ	០៤	១២០	២៨
៦	ខេត្តឧត្តរមានជ័យ	០២	៨២	៣៣
៧	ខេត្តបាត់ដំបង	០១	៤៤	០
៨	ខេត្តកំពង់ឆ្នាំង	០៥	១២១	៧៤
៩	ខេត្តកំពង់ធំ	០១	១១	០៤
១០	ខេត្តសៀមរាប	០៨	៤២៥	៦០
១១	ខេត្តព្រះសីហនុ	០១	៨១	០៤
១២	ខេត្តកំពត	០៦	២៨១	៩៨
១៣	ខេត្តតាកែវ	០៣	២៧៧	២០៨
១៤	ខេត្តស្វាយរៀង	៤៩	៩២១	៥១៨
១៥	ខេត្តព្រៃវែង	១៣	៦៥៧	៥០៩
១៦	ខេត្តក្រចេះ	០១	៣៥	១៤
១៧	ខេត្តកំពង់ចាម	២០	៦៥៦	៣៦០
១៨	ខេត្តត្រដុយំ	០៤	១១០	២០
១៩	ខេត្តរតនៈគិរី	០១	២៤០	៣៥
	សរុប	**១៦០**	**៥.៧៣៤**	**១.៧៤៩**
ល.រ	**សកម្មភាពរបស់អង្គការដៃគូ**	**ចំនួនវគ្ត**	**សិក្ខាកាមសរុប**	**សិក្ខាកាមនារី**
១	អង្គការបណ្ណាពុទ្ធសេ្ពជំនួយកុមារកម្មជា	០១	២៦	

២	អង្គការ AICHR- ASEAN	០១	១៨៨	
៣	អង្គការម៉ារីតាន់ក៏ស (ខេត្តបាត់ដំបង)	០៣	៣២	២៣
៤	អង្គការ APLE (ខេត្តសៀមរាប)	០១	២៧	១៦
៥	អង្គការមូលនិធិ A២១ សហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប	០៥	៥៣៣	២១៨
៦	អង្គការ IOM (ខេត្តសៀមរាប)	០១	៤៧	២១
៧	អង្គការសម្ព័ន្ធចាប់ដៃ (ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តព្រះវិហារ)	០៦	៣១៥	១៦៤
៨	អង្គការវីវើល/ជីវីសុី (ខេត្តសៀមរាប)	០១	៦៧	២១
	សរុប	**១៩**	**១.២៣៥**	**៤៦៣**
សរុបរួម		**១៧៩**	**៦.៩៦៩**	**២.២១២**

ក.២. សិក្ខាសាលា

ក.២.១. សិក្ខាសាលាក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គសិក្ខាសាលាចំនួន **១៨២**វគ្គ មានសិក្ខាកាមចូលរួមចំនួន **៩.០៩០**នាក់(ស្ត្រី**១.០១៨**នាក់) ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោម៖

តារាងសិក្ខាសាលា

សកម្មភាពរៀបចំសិក្ខាសាលា	ចំនួនវគ្គ	សិក្ខាកាមសរុប	សិក្ខាកាមជានារី
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលា៖			
-ពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី សូចនាករអភិបាលកិច្ចទេសន្តរប្រវេសន៍(MGI) របស់កម្ពុជា និងការអនុវត្តកតិកាសញ្ញាពិភពលោក សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់(GCM) នៅសណ្ឋាគារ Raffles ភ្នំពេញ។ និងសិក្ខាសាលា ស្តីពីការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិរយៈ៥ឆ្នាំ(២០១៩-២០២៣) ប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។	០២	៥៦	២០
-**សហការជាមួយអង្គការសេង់ត្រាល់** រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) "Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual)" តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧ.ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ។	០១	៥៧	០០
-**សហការជាមួយអង្គការកាតាសស្វីស** រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹងសៅសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ចំនួន ០៣លើក នៅខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្តប៉ៃលិន ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។	០៣	១០៩	៣៥
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលា៖			
-ស្តីពីផែនការអាជីព និងជ្រើសរើសជំនាញសិក្សា សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ។	១០៩	៥.០១៤	០០
-ការណែនាំអាជីពការងារ និងវិជ្ជាជីវៈសម្រាប់និស្សិត នៅគ្រឹស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យ។	០៨	៤០០	០០
-ស្តីពីការផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន។	១២	៦០០	០០
-សហការជាមួយ អង្គការអន្តរជាតិខាងការងារ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ និងកម្មវិធីអភិវឌ្ឍន៍សម្រាប់ជាតិ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ តាមប្រព័ន្ធអនឡាញ	០១	៦០	

ស្តីពី កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ដែលដឹកនាំដោយ ឯកឧត្តម **ហ៊ុ វុឌ្ឍី** រដ្ឋលេខាធិការ តំណាងឯកឧត្តមបណ្ឌិត **អិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។			
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ -រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងកែសម្រួលលើសៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការរតនៈអ៊ីនជើណេសិនណល និង UN-ACT។ **-សហការជាមួយគម្រោងកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) និង (ACWC)**រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពី "ការប្រតិបត្តិមណ្ឌលស្នាក់នៅដើម្បីការគាំទ្រចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងចំណោមអ្នកអនុវត្ត" នៅខេត្តមណ្ឌលគិរី។	០២	៨១	៤០
ក្រសួងអប់រំ យុវជន និងកីឡា៖ បានសហការជាមួយអង្គការក្លែន និងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំសិក្ខាសាលា៖			
-វគ្គបំប៉ន ស្តីពីការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ដល់លោកគ្រូ អ្នកគ្រូ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម។	០១	៨៦	២៣
-វគ្គបំប៉ន ស្តីពីការប្រើប្រាស់សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន តាមប្រព័ន្ធហ្សូម ដល់លោកគ្រូ អ្នកគ្រូ នៅខេត្តកំពង់ឆ្នាំង។	០១	៥៣	៣០
-សិក្ខាសាលាផ្សព្វផ្សាយនីតិវិធីបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។	០១	១៣	០៦
ក្រសួងប្រៃសណីយ៍ និងទូគមនាគមន៍ សហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** រៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្តីពី «កិច្ចការពារកុមារលើប្រព័ន្ធអនឡាញនៅកម្ពុជា»។	០១	២០០	០០
ក្រសួងទេសចរណ៍៖ រៀបចំសិក្ខាសាលា ស្តីពី "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ដល់មន្ត្រីរាជការ នគរបាល កងរាជអាវុធហត្ថ អាជ្ញាធរដែនដី(ស្រុក/ភូមិ/ឃុំ) មន្ទីរពាក់ព័ន្ធ យុវជន គ្រូបង្រៀន និងប្រតិបត្តិករទេសចរណ៍ នៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ នៅតាមបណ្តារាជធានី-ខេត្តទាំង២៥។	១៦	១.១៩៥	៥៧២
អង្គការ ASEAN-ACT បើកសិក្ខាសាលាពិគ្រោះយោបល់ តាមប្រព័ន្ធអនឡាញ ស្តីពី"ការពិគ្រោះយោបល់ វាយតម្លៃសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព" ក្រោមប្រធានបទដែលជាវិស័យអាទិភាពចំនួន០២ ជាមួយដៃគូវិស័យយុត្តិធម៌ និងវិស័យសង្គមកិច្ច ក្នុងការឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងការអនុវត្តអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារនៅកម្ពុជា។	០១	៣៦	
អង្គការសកម្មភាពដើម្បីកុមារ(APLE) បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការអនុវត្តតាមបែបកុមារមេត្រី ដើម្បីការពារសិទ្ធិរបស់កុមាររងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តសំណុំរឿងប្តឹងប្រតិបត្តិតាមនីតិវិធីតុលាការ និងការលើកកម្ពស់ការយល់ដឹងអំពី ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដល់មន្ត្រីរាជការ បុគ្គលិកអង្គការដៃគូ ក្រុមគោលដៅជាយុវជន និងកុមារ និងឪពុកម្តាយរបស់កុមាររងគ្រោះ ។	១០	២០០	១១៩
ខេត្តកំពង់ស្ពឺ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការយែកម្ពុជាអន្តរជាតិ រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារប្រចាំឆ្នាំ២០២០ នៃគម្រោងចំណាកស្រុក ដោយ	០១	៥០	៣៥

សុវត្ថិភាព ក្រោមអធិបតីភាព លោកជំទាវឧ.ទោ **វ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។			
9	ការជីកនាំគ្រឹះស្ថានពេស្យាចារ	មាត្រា៣១	២-៥																
10	ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ	មាត្រា៣២	២-៥	1	1	1			3	3			1	1	2	2	3		
11	បទល្មើសទាក់ទងនឹងពេស្យាចារកុមារ	មាត្រា៣៣	៧-១៥																
12	រូបភាព និងសម្ភារៈអាសអាភាស	មាត្រា៣៩	៧ថ្ងៃ-១ខែ/១ខែ-១ឆ្នាំ	4	4				4	4					4	4			4
13	រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ	មាត្រា៤១	២-៥/៥-១០/១០-២០	1	3	1			1	1	1	1							1
14	អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ	មាត្រា៤២	៥-១០	86	92		1		93	86	93	86							93
15	អំពើអាសប្រតាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ	មាត្រា៤៣	១-៣	17	17				20	16	20	16							20
សរុបរួម				359	538	52	14	6	1577	769	211	157	148	85	1218	527	32		1545

ឧបសម្ព័ន្ធ ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី
លេខ.....រសក/២២

ជំណាក់កាលអយ្យការ

ប្រចាំឆ្នាំ២០២១ ចាប់ពីថ្ងៃទី២៦ ខែឆ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែឆ្នូ ឆ្នាំ២០២១

ល.រ	បទល្មើសជូញជូរមនុស្ស	មាត្រា	សំណុំរឿង			ចំនួនជនរងគ្រោះ					ចំនួនជនល្មើស					សំណុំរឿងចំណាត់ការរួច							ឿងសល់ក្នុងចាត់ការ 24=6-23	ផ្សេងៗ
								អនីតិជន					អនីតិជន											
			សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សរុប 6=4+5	សរុប	ស្រី	ប្រុស	ស្រី	អញ្ញាតជន	សរុប	ស្រី	ប្រុស	ស្រី	អញ្ញាតជន	បញ្ជូនរឿងទៅស៊ើបស្វរ(RI)	បញ្ជូនរឿងទៅជម្រះ(CD)	នីតិវិធីបង្ហាញខ្លួនឆ្លាម(CI)	តម្កល់រឿងទុកតាចាត់ការ	បញ្ជូលសំណុំរឿង	ផ្ទេរសមត្ថកិច្ច	សរុប 23=17+...+22		
	2	3	4	5	6	7	8	9	10	11	12	13	14	15	16	17	18	19	20	21	22	23	24	25
1	ការនាំយកចេញដោយមិនស្របច្បាប់	8	2	21	23	88	52	3	2	0	34	6	0	0	0	22	0	0	0	0	0	22	1	
2	ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	10	0	13	13	49	14	0	6	0	24	6	0	0	0	11	0	0	0	0	0	11	2	
3	ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេញប្រវ័ញ្ជន៍	12	1	0	1	1	0	0	0	0	1	0	0	0	0	0	0	0	1	0	0	1	0	
4	ផលិតរូបភាព និងសម្ភារអាសអាភាស	12	3	11	14	19	13	0	6	0	16	1	2	0	0	8	0	0	3	0	0	11	3	
5	អំពើលក់-ដូរមនុស្ស	13	0	12	12	10	2	0	0	0	21	7	0	0	0	11	0	0	1	0	0	12	0	
6	អំពើលក់-ដូរមនុស្សដោយមានគោលដៅ	15	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
7	ការជឹកជញ្ជូនដោយមានគោលដៅ	17	0	3	3	8	2	0	0	0	9	3	0	0	3	3	0	0	0	0	0	3	0	
8	ការទទួលយកមនុស្សដោយមានគោលដៅ	19	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
9	សញ្ជាកម្មទាក់ទងនឹងពេស្យាចារកុមារ	28	0	2	2	4	0	0	4	0	2	1	0	0	0	2	0	0	0	0	0	2	0	
10	ការទិញពេស្យាចារកុមារ	33	0	1	1	3	3	0	2	0	1	1	0	0	0	1	0	0	0	0	0	1	0	
11	ការទិញពេស្យាចារកុមារក្រោមអាយុ ១៥ឆ្នាំ(អនីតិជន)	34	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
12	ការអូសទាញពេស្យាចារកុមារ	35	0	1	1	1	0	0	1	0	1	1	0	0	0	0	0	0	0	0	0	0	1	
13	ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងនឹងអំពើពេស្យាចារកុមារ	36	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
14	កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ	45	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
15	ចាប់បង្ខាំងមនុស្សដោយខុសច្បាប់		1	9	10	11	9	0	1	0	21	8	1	0	0	4	0	0	5	0	0	9	1	
16	ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ		0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
17	ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន	10	3	94	97	69	32	3	8	0	165	19	7	0	0	95	0	0	0	0	0	95	2	
18	អំពើលក់-ដូរមនុស្សសម្រាប់ឆ្លងដែន	16	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
19	រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ	42	5	65	70	52	28	3	63	0	71	12	4	3	0	61	1	0	2	0	0	64	6	
20	ផ្សេងៗ		0	285	285	304	112	9	93	33	449	60	18	3	0	207	0	1	7	0	0	215	70	
សរុប			15	517	532	619	267	18	186	33	815	125	32	6	3	425	1	1	19	0	0	446	86	

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
ប្រធាននាយកដ្ឋាន

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
អ្នកធ្វើតារាង

ឧបសម្ព័ន្ធ ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាជម្រះក្តី
លេខ.....រសក/២២

ដំណាក់កាលស៊ើបសួរ
ប្រចាំឆ្នាំ២០២១ ចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១

ល.រ	បទល្មើសជួញដូរមនុស្ស	មាត្រា	សំណុំរឿង			ចំនួនជនរងគ្រោះ					ចំនួនជនល្មើស					ស្ថិតក្រោមការត្រួតពិនិត្យផ្លូវតុលាការ			សំណុំរឿងចំណាត់ការរួច					ឆ្នឿងស់កំពុងចាត់ការ	ផ្សេងៗ
			សំណុំរឿងសល់ពីមុន	សំណុំរឿងចូលថ្មី	សរុប 6=4+5	សរុប	ស្រី	អនីតិជន ប្រុស	អនីតិជន ស្រី	អញ្ញាតជន	សរុប	ស្រី	អនីតិជន ប្រុស	អនីតិជន ស្រី	អញ្ញាតជន	សរុប 17=18+19	ប្រុស	ស្រី	បញ្ចូនរឿងទៅជំនុំជម្រះ	លើកលែងចោទប្រកាន់	បញ្ចូលរឿង	ផ្ទេរសមត្ថកិច្ច	សរុប 24=20+...+23	25=6-24	
	2	3	4	5	6	7	8	9	10	11	12	13	14	15	16	17	18	19	20	21	22	23	24	25	26
1	ការនាំយកចេញដោយមិនស្របច្បាប់	8	12	25	37	66	40	5	3	0	51	12	2	0	3	0	0	0	28	2	0	0	30	7	
2	ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	10	7	14	21	23	15	0	3	1	17	10	1	3	0	0	0	0	11	1	0	0	12	9	
3	ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេញប្រវ័ញ្ចន៍	12	2	3	5	5	5	0	2	0	4	3	0	0	0	0	0	0	3	0	0	0	3	2	
4	ផលិតរូបភាព និងសម្ភារអាសអាភាស	12	4	2	6	11	8	0	3	0	7	0	2	1	0	0	0	0	5	0	0	0	5	1	
5	អំពើលក់-ដូរមនុស្ស	13	0	10	10	8	1	0	0	0	22	3	0	0	0	0	0	0	6	1	0	0	7	3	
6	អំពើលក់-ដូរមនុស្សដោយមានគោលដៅ	15	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
7	ការជឹកជញ្ជូនដោយមានគោលដៅ	17	2	2	4	0	0	0	0	0	4	4	0	0	0	0	0	0	4	0	0	0	4	0	
8	ការទទួលយកមនុស្សដោយមានគោលដៅ	19	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
9	សញ្ជាកម្មទាក់ទងនឹងពេស្យាចារកុមារ	28	2	4	6	6	2	0	5	0	8	8	0	5	0	0	0	0	2	0	0	0	2	4	
10	ការទិញពេស្យាចារកុមារ	33	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
11	ការទិញពេស្យាចារកុមារក្រោមអាយុ ១៥ឆ្នាំ(អនីតិជន)	34	2	1	3	1	0	0	0	2	0	3	1	0	0	0	0	0	2	0	0	0	2	1	
12	ការអូសទាញពេស្យាចារកុមារ	35	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
13	ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងនឹងអំពើពេស្យាចារកុមារ	36	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
14	កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ	45	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
15	ចាប់បង្ខាំងមនុស្សដោយខុសច្បាប់		1	1	2	2	1	0	1	0	2	0	1	0	0	0	0	0	1	0	0	0	1	1	
16	ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ		0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
17	រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ឆ្នាំ	42	16	57	73	57	24	6	52	0	64	9	10	1	0	1	1	0	54	0	0	0	54	19	
18	លក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន	16	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
19	នាំយកចេញឆ្លងដែន	11	5	89	94	126	63	7	18	0	212	31	8	0	0	3	3	0	75	0	0	0	75	19	
20	ផ្សេងៗ		2	260	262	225	65	18	87	0	474	57	19	3	1	2	1	1	68	1	0	0	69	193	
	សរុប		55	468	523	530	224	36	174	3	865	140	44	13	4	6	5	1	259	5	0	0	264	259	

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
ប្រធាននាយកដ្ឋាន

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
អ្នកធ្វើតារាង

ឧបសម្ព័ន្ធ ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានកិច្ចការរដ្ឋបាលនៃសាលាដំបូងរាជធានី
លេខ................សតក/២២

ដំណាក់កាលជំនុំជម្រះ

ប្រចាំឆ្នាំ២០២១ ចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១

ល.រ	បទល្មើសជួញដូរមនុស្ស	មាត្រា	សំណុំរឿង: រឿងសល់ពីមុន	សំណុំរឿង: រឿងចូលថ្មី	សំណុំរឿង: សរុប 6=4+5	ចំនួនជនរងគ្រោះ: សរុប	ចំនួនជនរងគ្រោះ: ស្រី	ចំនួនជនរងគ្រោះ: អនីតិជន ប្រុស	ចំនួនជនរងគ្រោះ: អនីតិជន ស្រី	ចំនួនជនរងគ្រោះ: អញ្ញាតជន	ចំនួនជនជាប់ចោទ: សរុប	ចំនួនជនជាប់ចោទ: ស្រី	ចំនួនជនជាប់ចោទ: អនីតិជន ប្រុស	ចំនួនជនជាប់ចោទ: អនីតិជន ស្រី	ចំនួនជនជាប់ចោទ: អញ្ញាតជន	សំណុំរឿងចំណាត់ការរួច: បានជំនុំជម្រះ	ផ្ទេរសមត្ថកិច្ច	ប្រកាសសាលក្រម: លើកលែងចោទ: សំណុំរឿង	លើកលែងចោទ: ចំនួនមនុស្ស	ផ្តន្ទាទោស: ពិន័យជាប្រាក់	ផ្តន្ទាទោស: ដាក់ពន្ធនាគារ	ផ្តន្ទាទោស: សរុបចំនួនមនុស្ស	ទោសព្យួរ: ព្យួរទោសសាកល្បង	ទោសព្យួរ: ព្យួរទោសធម្មតា	ទោសព្យួរ: សរុបចំនួនមនុស្ស	សរុបចាត់ការរួច 27=17+18	សល់អំពុងចាត់ការ 26=6-25	បណ្តឹងឧបាស្រ័យ: បណ្តឹងទាស់	បណ្តឹងឧបាស្រ័យ: បណ្តឹងឧទ្ធរណ៍	ផ្សេងៗ
1	2	3	4	5	6	7	8	9	10	11	12	13	14	15	16	17	18	19	20	21	22	23	24	25	26	27	28	29	30	31
1	ការនាំយកចេញដោយមិនស្របច្បាប់	8	11	32	43	60	36	5	6	0	63	27	0	0	0	27	0	6	8	0	18	17	0	9	10	27	16	0	1	
2	ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	10	7	12	19	19	14	0	2	0	24	17	0	0	0	15	0	0	0	0	4	1	3	2	2	15	4	0	0	
3	ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេញប្រវ័ញ្ច	12	0	2	2	2	1	0	0	0	2	0	0	0	0	1	0	0	0	0	0	0	0	0	0	1	1	0	0	
4	ផលិតរូបភាព និងសម្ភារអាសអាភាស	12	1	3	4	7	5	0	2	0	6	0	2	1	0	3	0	0	0	0	1	1	0	1	1	3	1	0	0	
5	អំពើលក់-ដូរមនុស្ស	13	0	4	4	5	1	0	0	0	13	0	0	0	0	1	0	0	0	0	3	0	0	0	0	1	3	0	0	
6	អំពើលក់-ដូរមនុស្សដោយមានគោលដៅ	15	0	1	1	0	0	0	0	0	7	0	0	0	0	0	0	0	0	0	0	0	0	0	0	0	1	0	0	
7	ការដឹកជញ្ជូនដោយមានគោលដៅ	17	0	1	1	1	1	0	0	0	0	0	0	0	0	1	0	0	0	0	1	1	0	0	0	1	0	0	0	
8	ការទទួលយកមនុស្សដោយមានគោលដៅ	19	1	0	1	6	3	0	4	0	2	1	0	0	0	1	0	0	0	0	2	2	0	1	2	1	0	0	0	
9	សញ្ញាកម្មទាក់ទងនឹងពេស្យាចារកុមារ	28	0	3	3	8	4	0	8	0	6	2	1	0	0	2	0	0	0	0	1	1	0	0	0	2	1	0	0	
10	ការទិញពេស្យាចារកុមារ	33	0	2	2	3	1	0	3	0	1	0	0	0	0	2	0	0	0	0	0	0	0	0	0	2	0	0	0	
11	ការទិញពេស្យាចារកុមារក្រោមអាយុ ១៥ឆ្នាំ(អនីតិជន)	34	0	3	3	4	0	0	4	0	4	0	0	0	0	2	0	0	0	0	2	0	0	0	0	2	1	0	0	
12	ការអូសទាញពេស្យាចារកុមារ	35	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
13	ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងនឹងអំពើពេស្យាចារកុមារ	36	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
14	កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ	45	0	1	1	1	0	0	1	0	1	0	1	0	0	0	0	0	0	0	0	0	0	0	0	0	1	0	0	
15	ចាប់បង្ខាំងមនុស្សដោយខុសច្បាប់		1	0	1	2	0	0	0	0	1	0	0	0	0	1	0	0	0	0	0	0	0	0	0	1	0	0	0	
16	ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ		0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	
17	រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ឆ្នាំ	42	25	59	84	67	42	5	54	2	84	0	15	0	0	60	0	0	0	0	14	14	0	8	7	60	24	0	0	
18	ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំយកឆ្លងដែន	11	2	62	64	60	30	4	7	0	110	15	0	0	0	51	0	0	0	0	2	0	0	0	0	51	13	0	0	
19	ផ្សេងៗ		2	199	201	175	55	4	60	0	392	20	3	0	0	33	3	0	0	10	122	22	0	0	0	36	165	0	0	
	សរុប		50	384	434	420	193	18	151	2	716	82	22	1	0	200	3	6	8	10	170	59	3	21	22	203	231	0	1	0

សំគាល់៖
១. ពិន័យជាប្រាក់ចំនួន រឿង
២. រួចផុតពីបទចោទចំនួន រឿង
៣. រំលត់បណ្តឹងអាជ្ញាចំនួន រឿង

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
ប្រធាននាយកដ្ឋាន

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ថ្ងៃទី ខែ ឆ្នាំ២០២២
អ្នកធ្វើតារាង

ឧបសម្ព័ន្ធទី៣
ការចាត់រៀបចំ ដឹកនាំកិច្ចប្រជុំ

អន្តរក្រសួង ស្ថាប័ន លេខាធិការដ្ឋានរាជធានី ខេត្ត សហការ និងរៀបចំ ដឹកនាំកិច្ចប្រជុំ បានចំនួន ៤៨៧លើក មានមនុស្សសរុបចំនួន ១០.០៩០នាក់ ស្រី ៤.៦០៥នាក់

ស្ថាប័ន	សកម្មភាព
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)	▪ **បានរៀបចំ ដឹកនាំកិច្ចប្រជុំ បានចំនួន ៧៦លើក ដែលមានមនុស្សចូលរួមសុបចំនួន ១.១៧២នាក់ ស្រី ២៧៤នាក់ រួមមាន៖** **សម្តេចក្រឡាហោម** ស ខេង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកកិច្ចប្រជុំ៖ **១-**បូកសរុបលទ្ធផលការងារប្រឆាំងការជួញដូរមនុស្ស ឆមាសទី១របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ដែលមានសភាពចូលរួមមាន ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និង ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ ជាអនុប្រធាន និងជាប្រធានដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័ន ទាំង ០៦ នៃ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង តំណាងក្រសួង ស្ថាប័ន និងអង្គភាពជាសមាជិក សរុប ៧៣នាក់(ស្រី ២៥)។ **២-** ជាមួយក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធវីដេអូអនឡាញ មានការអញ្ជើញចូលរួមពីតំណាងក្រសួង ជាអនុប្រធាន នៃ គ.ជ.ប.ជ ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ឯកឧត្តម**កើតរិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, លោកជំទាវ**អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី, លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ, លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ, ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ, ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍, ឯកឧត្តម ឧត្តមសេនីយ៍ឯក **សៀក សុជាតិ** នាយកទីចាត់ការព្រំដែននៃក្រសួងការពារជាតិ, ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិកនៃ គ.ជ.ប.ជ មានក្រសួងការពារជាតិ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងធម្មការសាសនា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការរងនគរបាលជាតិ តំណាងពីអគ្គនាយកដ្ឋាន អគ្គសញ្ញាណកម្ម តំណាងពីក្រសួងការបរទេស សហប្រតិបត្តិការអន្តរជាតិ ស្ថាប័នតុលាការ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ ប្រធាន-អនុប្រធាននាយកដ្ឋានជំនាញ និងតំណាងពីអង្គភាពមានសមត្ថកិច្ចជាសមាជិក នៃគ.ជ.ប.ជ ប្រមាណ ៧៣នាក់ (ស្រី ២៥នាក់)។ **៣-**ជាមួយក្រុមការងារអន្តរក្រសួងស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំជាន់ខ្ពស់ដ៏ទៃទៀត ពីស្ថាប័នជំនាញ ជាអនុប្រធាន និងសមាជិករបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រមាណ ៥០នាក់(ស្រី ២២នាក់) ។ - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សា៖

	១-ទេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ "កិច្ចប្រជុំបានពិភាក្សាលើចំណុចដែលនៅសេសសល់ក្នុងសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ" នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម ២៩នាក់(ស្រី ០៦នាក់)។ **២**-SOP ទេភាគីកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ ស្តីពី"ស្តង់ដានីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" នៅសណ្ឋាគារកាំបូឌីយ៉ាណា អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ០៨នាក់)។ **៣**-កែសម្រួលជាភាសាបរទេស លើគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ជាមួយលោកស្រី **គ្រីស្ទីន ផាកូ** ប្រធានអង្គការអាយអូអឹម IOM នៅសាលប្រជុំ គ.ជ.ប.ជ។ **៤**-ស្តីពី **"ការកែសម្រួលរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.ជ.ប.ជ ឆ្នាំ២០២០ និងលើកទិសដៅការងារ ឆ្នាំ២០២១"** ចំនួន ០៣លើក អ្នកចូលរួមចំនួន ២៨នាក់ (ស្រី ០៥នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។ **៥**-ជាអធិបតីភាព ក្នុងកិច្ចប្រជុំស្ថាប័នមិនមែនរដ្ឋាភិបាល ប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា បញ្ហាប្រឈម និងទិសដៅអនាគត ដែលរៀបចំ និងសម្របសម្រួលពីអង្គការ USAID ដោយមានការអញ្ជើញចូលរួម ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីបណ្តាអង្គការដៃគូពាក់ព័ន្ធនានា មានដូចជា Caritas swiss, IJM, IOM,A21, Cambodia Act, Hope for justice, Care, Ratanak, USAID, LSCW, We world-GVC ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេវាគាំទ្រដល់ជនរងគ្រោះជាពលករទេសន្តរប្រវេសន៍ និងនៅក្នុងប្រទេស មានអ្នកចូលរួមចំនួន ៥៨នាក់ (ស្រី ២៥នាក់) នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ **៦**-ជាមួយថ្នាក់ដឹកនាំនៃរដ្ឋបាល ខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងគម្រោងការផ្តល់សេវាគាំទ្រទៅកាន់ពលករដែលវិលត្រឡប់ មានស្ត្រី និងកុមារដែលងាយរងគ្រោះ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។ **៧**-តាមរយៈ Video Conference ស្តីពី "REGIONAL PEER LEANING BUILDING ON COMMITMENTS TO COMBAT IUU FISHING AND TO PROVIDE HUMAN RIGHTS PROTECTION IN THE CAPTURE FISHERY SECTOR in SOUTH-EAST ASIA" ដែលរៀបចំដោយ The Coordinating Ministry for Maritime and Investment Affairs of Republic of Indonesia in collaboration with Foundation for International Human Rights Reporting Standards (FIHRRST) អ្នកចូលរួមចំនួន ២៩នាក់ (ស្រី ១២នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។ **៨**-ស្តីពីការបង្កើតទស្សនាវដ្តីសម្រាប់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ១២នាក់ (ស្រី ៧នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។ **៩**-តាមប្រព័ន្ធអនឡាញជាមួយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងបណ្តាញអង្គការសហប្រជាជាតិ ស្តីពី<<ទេសន្តរប្រវេសន៍ (UNNetworkMigration)>> ស្តីពី<<ការដាក់បញ្ចូលកម្ពុជា ទៅក្នុងបញ្ជីប្រទេសជ័យលាភី នៃការអនុវត្តកតិកាសញ្ញាពិភពលោក>> ស្តីពី<<ទេសន្តរប្រវេសន៍ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់>> នៅសាលប្រជុំ គ.ជ.ប.ជ។ **១០**-តាមប្រព័ន្ធអនឡាញ ស្តីពី<<កិច្ចពិគ្រោះយោបល់លើការស្វែងរកការស្រាវជ្រាវ និងអនុសាសន៍>> ស្តីពី<<ការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស>> រៀបចំសម្របសម្រួលដោយអង្គការវីនរ៉ក់ Winrock នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការសហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមការងារ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការយូសេដ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍។ កិច្ចប្រជុំពិភាក្សានេះ ធ្វើឡើងក្នុងគោលបំណងយល់ដឹងពីទស្សនៈ ផ្នត់គំនិតរបស់ជនរងគ្រោះ និងផ្តល់សេវាឲ្យចំគោលដៅ ជាតម្រូវការចាំបាច់របស់ជនទេសន្តរប្រវេសន៍។ និងស្វែងយល់ចែករំលែកបទពិសោធន៍ការងារពីប្រទេសសាមីពាក់ព័ន្ធ ដោយមានគាំទ្រពីគម្រោងអភិវឌ្ឍន៍របស់ USAID ក្នុងការអនុវត្តការងារនេះ។ គម្រោងស្រាវជ្រាវនេះ ក៏អាចឲ្យយើងសិក្សាយល់ដឹងបន្ថែមពីទម្រង់ផ្សេងៗ បរិបទសម័យថ្មីអំពីបទល្មើសជួញដូរមនុស្ស និងអាចប្រើប្រាស់ជាកស្តុតាងចង្អុលផ្លូវក្នុងការអនុវត្តការងារជួយជនរងគ្រោះទេសន្តរប្រវេសន៍ពីអំពើជួញដូរមនុស្ស។ **១១**-ការងារជាមួយតំណាងអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការ លើកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ ទី

	ប្រឹក្សា និងប្រធានលេខាធិការដ្ឋាន នៅសាលប្រជុំអគ្គលេខាធិការការដ្ឋាន គ.ជ.ប.ជ ។ **១២**-តាមប្រព័ន្ធវីដេអូអនឡាញ កែសម្រួលលើរបៀបមួយចំនួន ត្រៀមមុនកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN-ACT ស្តីពីការឆ្លើយតបយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មីសិក្ខាសាលាទី ៦ ក្រោមប្រធានបទវិធីសាស្ត្ររបស់ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការ ឆ្លើយតបការជួញដូរមនុស្ស មានការចូលរួមលោកជំទាវអគ្គលេខាធិការ ទីប្រឹក្សា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការរង សហប្រតិបត្តិការជាតិ អន្តរជាតិ អគ្គលេខាធិការរង នៃក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ តំណាងពីក្រសួងយុត្តិធម៌ តំណាងអង្គការដៃគូពាក់ព័ន្ធ មាន ASEAN -ACT និង ពីអង្គការពីប្រទេសពាក់ព័ន្ធមួយចំនួន ដែលរៀបចំនិងសម្របសម្រួលដោយអង្គការ ASEAN-ACT ។ **១៣**-សកម្មភាពពិនិត្យ និង កែសម្រួលខ្លឹមសារសេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ របស់ក្រសួងសុខាភិបាល មានការចូលរួមក្នុងកិច្ចប្រជុំនេះ ដោយលោកជំទាវអគ្គលេខាធិការលេខាធិការ អគ្គលេខាធិការរង ទទួលបន្ទុកកិច្ចការងារសហប្រតិបត្តិការអន្តរជាតិ លោកទីប្រឹក្សា គ.ជ.ប.ជ លោកប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ និងលោកអនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១៤**-វាំងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការ ការពារជនរងគ្រោះ ដោយមានការអញ្ជើញចូលរួមពីលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ លោកទីប្រឹក្សា គ.ជ.ប.ជ លោក **ឌី នឿត** នាយកប្រចាំប្រទេសអង្គការសម្ព័ន្ធចាប់ដៃ លោក **ចាន់ សារ៉ុន** ប្រធានកម្មវិធីអង្គការសម្ព័ន្ធចាប់ដៃ លោក **សៀង វន្ថា** អនុប្រធានកម្មវិធីអង្គការសម្ព័ន្ធចាប់ដៃ សរុបចំនួន ០៧រូប ស្រី ០២រូប នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។ **១៥**-តាមប្រព័ន្ធអនឡាញ ស្តីពី"កិច្ចពិភាក្សាពិគ្រោះយោបល់លើការស្វែងរកការស្រាវជ្រាវ និងអនុសាសន៍" ស្តីពី"ការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស" ដែលរៀបចំសម្របសម្រួលដោយអង្គការវីនរ៉ក់ (Winrock)។ មានការអញ្ជើញចូលរួមពីអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការសហប្រតិបត្តិអន្តរជាតិ លោកប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការអន្តរជាតិ អ្នកតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការយូសេដ និង អង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ០៦នាក់) នៅបន្ទប់សាលប្រជុំ គ.ជ.ប.ជ។ **១៦**-តាមប្រព័ន្ធវីដេអូអនឡាញ កែសម្រួលលើរបៀបវារៈមួយចំនួន ត្រៀមមុនកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN -ACT ស្តីពី "ការឆ្លើយតប យុត្តិធម៌សម្រាប់ការជួញដូរមនុស្ស" តាមច្បាប់ថ្មីសិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្ត្ររបស់ ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់ បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស។ មានការចូលរួមក្នុងកម្មវិធីនេះ ដោយលោកជំទាវអគ្គលេខាធិការ លោកទីប្រឹក្សាអគ្គលេខា គ.ជ.ប.ជ លោកជំទាវអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ តំណាងពីក្រសួងយុត្តិធម៌ និងតំណាងអង្គការដៃគូពាក់ព័ន្ធមាន ASEAN -ACT និងពីអង្គការពីប្រទេសពាក់ព័ន្ធ អ្នកចូលរួមចំនួន ២៨នាក់ (ស្រី ១២នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។ **១៧**-តាមរយៈប្រព័ន្ធវីដេអូ ស្តីពី"វឌ្ឍនភាពនៃការអនុវត្តគម្រោងសាកល្បងវគ្គបណ្តុះបណ្តាលថ្នាក់បឋមសិក្សារ វាងកម្ពុជា និងថៃ" នៅខេត្តកោះកុង និងខេត្តត្រាត" លើកទី៤ ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងភាគីថៃ មានអ្នកចូលរួមសរុប ២៦នាក់។ **១៨**-ក្នុងអង្គសិក្ខាសាលាថ្នាក់តំបន់ ដើម្បីគាំទ្រការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ នៅក្នុងរដ្ឋជាសមាជិកអាស៊ាន ជាពិសេសនៅក្នុងកំឡុងពេលមានការរីករាលដាលមេរោគកូវីដ១៩ តាមរយៈប្រព័ន្ធវីដេអូ។ រៀបចំដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN ACT) សហការជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS)ប្រទេសថៃ, ស្ថាប័នទំនាក់ទំនងនៃកិច្ចប្រជុំឧត្តមមន្ត្រី ស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍(SOMSWD) តំណាងប្រទេសថៃសម្រាប់សិទ្ធិកុមារ នៅក្នុងគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និង

	កុមារ(ACWC) និងរដ្ឋាភិបាល នៃសាធារណរដ្ឋហ្វីលីពីន ជាអ្នកដឹកនាំស្ម័គ្រចិត្តលើការងារប្រឆាំងការជួញដូរមនុស្ស សម្រាប់ក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន (SOMTC) និងដោយមានការចូលរួមពីប្រទេសជាសមាជិក អាស៊ានអ្នកពាក់ព័ន្ធ សរុបចំនួន **២០០**រូប។ **១៩**-ស្តីពីសកម្មភាពការងារអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ **២០**-រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាព ប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ មានអ្នកចូលរួមសរុបចំនួន ២២នាក់(ស្រី ០៥នាក់)។ **២១**-រៀបចំទិសដៅឆ្នាំ២០២១របស់ គ.ជ.ប.ជ របៀបវារៈនៃអង្គប្រជុំមានចំនួន២គឺ៖ **១**.ឆ្លើយតបសំណើសុំផ្តល់ជាតុចូល ក្នុងរបាយការណ៍ ស្តីពីអនុសញ្ញាអន្តរជាតិ របស់អង្គការ ILO។ **២២**.បច្ចុប្បន្នភាពការងារ និងទិសដៅសម្រាប់ឆ្នាំ២០២១។ ជាកិច្ចបន្ត លោកជំទាវ **ជូ ប៊ុនអេង** បានផ្តល់ជាអនុសាសន៍ ដល់ក្រុមការងារទាំង៦ ពិនិត្យមើលផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដើម្បីជាទុនក្នុងការឆ្លើយតប និងដាក់ផែនការបន្តក្នុងឆ្នាំ២០២១។ **២៣**-ស្តីពី សកម្មភាពការងារអាទិភាពសំខាន់ៗ និងរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។ **២៤**-សម្រាប់ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ "ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្ម លើជនរងគ្រោះដោយអំពើជួញដូរ" មានការអញ្ជើញចូលរួមពី ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ឯកឧត្តម ទីប្រឹក្សា លោកប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធាន អនុប្រធានក្រុមការងារទាំង៦ និងក្រុមការងារ មន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។ **២៥**-តាមប្រព័ន្ធវីដេអូអនឡាញ(ZOOM) ស្តីពីការពិនិត្យអំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆមាសទី១ បញ្ហាប្រឈម និងដំណោះស្រាយ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១។ **២៦**-ពិនិត្យផែនការអភិវឌ្ឍន៍ មណ្ឌលទទួលពលករកំរៀង ជាមួយអង្គការការីតាសស្វីស តាមប្រព័ន្ធអនឡាញ នៅសាលប្រជុំ គ.ជ.ប.ជ ។ **២៧**-តាមប្រព័ន្ធអនឡាញ ស្តីពីការរៀបចំដំណើរការវាយតម្លៃ ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិប្រឆាំងការជួញដូរមនុស្សរយៈពេល៥ឆ្នាំ(២០១៩-២០២៣) និងសកម្មភាពអាទិភាពក្នុងពាក់កណ្តាលអាណត្តិ ជាមួយអង្គការដៃគូពាក់ព័ន្ធនានា ចំនួន០២លើក។ **២៨**-ជាមួយអង្គការ(Winrock)ស្តីពីរបាយការណ៍នៃកិច្ចប្រជុំពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ប្រធានអង្គការវីនរ៉ក់ និងសហការី អ្នកផ្តល់ប្រឹក្សាបច្ចេកទេស តំណាងអង្គការអាស៊ានអាក់ មានអ្នកចូលរួមសរុបចំនួន ១៦នាក់(ស្រី ០៧នាក់)។ **២៩**-ស្តីពីការត្រួតពិនិត្យរបាយការណ៍ និងឯកសារពាក់ព័ន្ធ ត្រៀមដាក់ជូន**សម្តេចក្រឡាហោម** ស ខេង សម្រាប់កិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ គ.ជ.ប.ជ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាមួយក្រុមការងារអន្តរក្រសួង-ស្ថាប័នទាំង៦ នាពេលខាងមុខនេះ មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុកការងារជំនាញទាំង៦ ប្រធាន និងអនុប្រធាន នៃក្រុមជំនួយកិច្ចការទាំង៦ លោកប្រធានលេខាធិការដ្ឋាននិងមន្ត្រីពាក់ព័ន្ធ ចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបចំនួន ១៨នាក់(ស្រី ០៦នាក់) ។ **៣០**-បន្ត ស្តីពីការត្រៀមរៀបចំកម្មវិធីអន្តរសាសនា លើកទី៤ ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូអនឡាញ ZOOM មានការអញ្ជើញចូលរួមពីតំណាងភាគីពាក់ព័ន្ធ ក្រោមអធិបតីភាពលោកជំទាវ**ជូ ប៊ុនអេង**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ , ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ គណៈដឹកនាំជាន់ខ្ពស់នៃឥស្លាមសាសនា គ្រិស្តបរិស័ទកាតូលិក ប៉ូតេស្តង់ និងនិកាយសាសនា

	ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា តំណាងព្រះសហគមន៍កាតីលិកកម្ពុជា តំណាងអង្គការដៃគូអភិវឌ្ឍន៍ តំណាងស្ថានីយ៍ទូរទស្សន៍បាយ័ន មានអ្នកចូលរួមសរុបចំនួន ២០នាក់(ស្រី ១១នាក់)។ **៣១**-ជាមួយតំណាងអង្គការដៃគូ មាន IOM, UNDP, ILO រួមនិងសហការី បានជួបប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ស្តីពីគម្រោង(Ship to Shore) ពាក់ព័ន្ធកិច្ចការពារពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទ មានការចូលរួមពីលោកជំទាវអគ្គលេខាធិការ លោកជំទាវ អគ្គលេខាធិការរង និងអនុប្រធានក្រុមជំនួយកិច្ចការនៃក្រុមការងារសហប្រតិបត្តិការជាតិ-អន្តរជាតិ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបចំនួន ១៣នាក់(ស្រី ០៥នាក់)។ **៣២**-បន្ត ស្តីពីការផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (TIP) តាមសាលារៀន តាមប្រព័ន្ធវីដេអូពីចំងាយ(ហ្សូម) រវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ អគ្គលេខាធិការ និង អគ្គលេខាធិការរង ជាមួយក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយ លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ និងសហការី តំណាងអង្គការដៃគូពាក់ព័ន្ធ មានអ្នកចូលរួមសរុបចំនួន ១៥នាក់(ស្រី ០៦នាក់)។ **៣៤**-និងការធ្វើបទបង្ហាញ ស្តីពីលទ្ធផលនៃការសិក្សាពីផលប៉ះពាល់ដម្ងីកូវីដ-១៩ លើជីវភាពរស់នៅរបស់ស្ត្រី និងក្មេងស្រីចំណាកស្រុក ខេត្តត្បូងឃ្មុំ កំពង់ចាម រៀបចំដោយអង្គការ JICA តាមប្រព័ន្ធវីដេអូពីហ្សូម ZOOM មានការចូលរួមពីលោកជំទាវ អគ្គលេខាធិការ លោកជំទាវ អគ្គលេខាធិការរង នៃក្រុមការងារសហប្រតិបត្តិការជាតិ-អន្តរជាតិ គ.ជ.ប.ជ តំណាងអង្គការ JIKA អង្គការជួយស្ត្រីមានវិបត្តិ និងសហការី ។ **៣៥**-ជាមួយអង្គការអេស៊ានអាក់ រវាងថ្នាក់ដឹកនាំនៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយនឹងតំណាងអង្គការ អាស៊ានអាក់ (Asian Act) តាមប្រព័ន្ធវីដេអូអនឡាញ ។ **៣៦**-ពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ(ZOOM) បានអញ្ជើញចូលរួមពីលោកជំទាវ អគ្គលេខាធិការ ស្តីពី"ការរៀបចំផែនការឆ្លើយតបជំងឺកូវីដ-១៩ សម្រាប់ជនទេសន្តរប្រវេសន៍ និងពលរដ្ឋចល័តខេត្តឧត្តរមានជ័យ កិច្ចប្រជុំពិគ្រោះយោបល់នេះមានការអញ្ជើញចូលរួមរបស់ ឯកឧត្តម **ប៉ែន កុសល្យ** អភិបាល នៃគណៈអភិបាលខេត្ត ឧត្តរមានជ័យ លោកស្រី Kristin Parco នាយកអង្គការ IOM និងសហការី ទីស្នាក់ការច្រកជាំ វត្តមានអង្គប្រជុំមាន ២៥នាក់។ **៣៧**-ស្តីពីផែនការសេកម្មភាពការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ ឆ្លើយតបទៅនឹងការធ្វើទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋ នៅសហគមន៍នៃស្រុកកំរៀង ខេត្តបាត់ដំបង របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុកការងាររលេខាធិការដ្ឋាន និងទទួលបន្ទុកការងារជំនាញទាំង៦ ប្រធាន និងអនុប្រធាននៃក្រុមជំនួយកិច្ចការ មន្ត្រីពាក់ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាល-សរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលាប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបចំនួន ១៦នាក់(ស្រី ០៨នាក់)។ **៣៨**-ស្តីពី CTIP Planning តាមប្រព័ន្ធវីដេអូអនឡាញ រវាងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ជាមួយនឹងតំណាងអង្គការវីនរ៉ក់ (Winrock) លោក Mark Taylor ប្រធានគម្រោង CTIP លោក **អៀង ប៊ុនថន** ទីប្រឹក្សាឯករាជ្យ លោក **លឹម សារុន** នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **៣៩**-រវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយតំណាងអង្គការអាដហុកកម្ពុជា ស្តីអំពីកិច្ចសម្របសម្រួល និងសេវាគាំទ្រដល់ពលករមិនស្របច្បាប់ នៅក្រៅប្រទេស តាមប្រព័ន្ធអនឡាញ (ហ្សូម) មានការចូលរួមពីលោកជំទាវ អគ្គលេខាធិការ លោកជំទាវ អគ្គលេខាធិការរងនៃក្រុមការងារសហប្រតិបត្តិការជាតិ-អន្តរជាតិ លោកទីប្រឹក្សាអគ្គលេខាធិការដ្ឋាន មន្ត្រីជំនាញនៃលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបចំនួន ១៤នាក់(ស្រី ០៧នាក់) ។ **៤០**- រវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយនឹងអង្គការវីនរ៉ក់ ដើម្បីរៀបចំកម្មវិធីប្រកាសជាផ្លូវការគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សុវត្ថិភាពទេសន្តរប្រវេសន៍ រយៈពេល៥ឆ្នាំ (២០២១-២០២៦) អនុវត្តដោយអង្គការ វីនរ៉ក់ អន្តរជាតិ ក្រោមមូលនិធិ របស់ទីភ្នាក់ងារជំនួយថវិការបស់អាមេរិច (USAID) តាមប្រព័ន្ធវីដេអូអនឡាញ (ហ្សូម) មានការចូលរួមពីប្រធានអង្គការវីនរ៉ក់កម្ពុជា ទីប្រឹក្សាឯករាជ្យ ឯកឧត្តម Patrick Murphy អគ្គរដ្ឋទូតសហរដ្ឋអាមេរិចប្រចាំកម្ពុជា លោកជំទាវ អគ្គលេខាធិការ លោកជំទាវ អគ្គលេខាធិការរង ទីប្រឹក្សាអគ្គលេខាធិការដ្ឋាន មន្ត្រីជំនាញនៃ

	លេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការដៃគូរពាក់ព័ន្ធមួយចំនួនទៀត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមសរុបចំនួន ២៣នាក់(ស្រី ១២នាក់)។ **៤១**-រវាងអគ្គលេខាធិការ គ.ជ.ប.ជ ជាមួយតំណាងអង្គការអេ២១ និងតំណាងស្ថានីយ៍ទូរទស្សន៍បាយ័ន ពិភាក្សាការងារ ស្តីពីការផលិតវីដេអូប្រមូសិនកម្មវិធីបញ្ចប់ការកេងប្រវ័ញ្ចនិងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៤២**-ក្នុងការបង្កើតមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅក្នុងការអនុវត្តការងារ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម អគ្គលេខាធិការរង ទទួលបន្ទុកក្រុមការងារជួយជនរងគ្រោះ ទីប្រឹក្សា ប្រធាននៃក្រុមជំនួយកិច្ចការ និងមន្ត្រីពាក់ព័ន្ធនៃលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៤៣**-ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា និងភាគី គ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ភាគីស្ថានទូតអាមេរិកដឹកនាំដោយ ឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ កិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ កិច្ចប្រជុំនេះមានការចូលរួមពីសមាសភាព ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ សរុបចំនួន **៣៤**នាក់ (ស្រី **១០**នាក់) មកពី ក្រសួង ស្ថាប័ន និងអង្គភាព នៅសាលប្រជុំក្រសួងយុត្តិធម៌។ **៤៤**-កម្រិតជំនាញត្រៀមពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ តាមប្រព័ន្ធអនឡាញ ជាមួយអង្គការ IOM មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ លោកស្រី ប្រធានអង្គការ IOM ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាល-សរុប ប្រធានក្រុមជំនួយកិច្ចការទាំង៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងស្ថាប័នពាក់ព័ន្ធ សរុបចំនួន **១២០**នាក់។ **៤៥**-លើសេចក្តីព្រៀងឯកសាកែរសម្រួល MOU ជាមួយអង្គការ Hagar ចំនួន **០៣**លើកមានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ លោកជំទាវ ឯកឧត្តម អគ្គលេខាធិការរង និងតំណាងអង្គការ Hagar នៅសាលប្រជុំ គ.ជ.ប.ជ។ **៤៦**-ករណីផ្សព្វផ្សាយ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលមានលក្ខណៈស្រើបស្រាល និងអាសអាភាស តាមប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីអន្តរក្រសួង មានក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងអប់រំយុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ។ **៤៧**-ជាមួយអន្តរក្រសួង ស្ថាប័ន និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ស្តីពី «**ការគ្រប់គ្រងចំណាកស្រុក**» តាមប្រព័ន្ធអនឡាញ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួម ថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូរអភិវឌ្ឍ មាន IOM, ILO, WHO, UNICEF, UNRCO តំណាងពីអន្តរក្រសួងស្ថាប័ន មានតំណាងពីក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច ក្រសួងការងារ ក្រសួងការបរទេស ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ប្រធានអង្គភាព និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គអត្តសញ្ញាណកម្ម ទីចាត់ការព្រំដែន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានព្រំដែនទឹក នាយកដ្ឋានព្រំដែនគោក អគ្គស្នងការនគរបាលជាតិ មន្ត្រីបច្ចេកទេស សរុបមួយចំនួន **៤៥**នាក់។ **៤៨**-ពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងក្រមសីលធម៌ រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ តាមប្រព័ន្ធអនឡាញ សហការគ្នាជាមួយអង្គការ IOM ការពិគ្រោះយោបល់ថ្នាក់ជាតិនេះ ជាវេទិកាមួយសម្រាប់ តំណាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និយោជក អ្នកជ្រើសរើសការងារ និងសមាគមរបស់ខ្លួន សង្គមស៊ីវិល និងអង្គការពាក់ព័ន្ធការងារពលករ និងកម្មករ ដើម្បីចូលរួម កិច្ចសន្ទនា ស្តីពីការជំរុញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តរបស់វិស័យឯកជន ទាក់ទងនឹងការជ្រើសរើស ពលករចំណាកស្រុកកម្ពុជា។ **៤៩**-បានរៀបចំកិច្ចប្រជុំធ្លងរបាយការណ៍

	១០ខែ ឆ្នាំ២០២១ ស្តីពី "ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ស ខេង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួមប្រមាណ **១៣៥** នាក់(ស្រី **៨៤**នាក់)។ **៥០**-ពិគ្រោះយោបល់ ស្តីពី "ការអនុវត្តផែនការជាតិ សម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក" ស្តីពី"ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM)" ដោយមានការចូលរួមសហការពីអង្គការ IOM ប្រចាំកម្ពុជា។ - **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញដឹកនាំប្រជុំពិភាក្សា៖ **១.**ពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈយោគយល់រវាង គ.ជ.ប.ជ និងអង្គការ We World Onlus។ **២.**ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃ ការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។ **៣.**ពិភាក្សាផ្តល់ចម្លើយតបជូនទៅអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំង នឹងឧក្រឹដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង (Global Initiative against Transnational Organized Crime)ទាំង១២សំណួរ ពាក់ព័ន្ធអំពើជួញដូរមនុស្ស។ **៤.**ក្នុងការបើកសិក្ខាសាលា ពិគ្រោះយោបល់លើកទី២ ស្តីពី"ដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត)" Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual)តាមប្រព័ន្ធវីដេអូអនឡាញ Zoom ដែលរៀបចំសម្របសម្រួលដោយអង្គការសង់ត្រាល់។ **៥.**បំពេញបន្ថែមចូលទៅក្នុងឯកសារពីរប្រភេទ របស់ក្រសួងមហាផ្ទៃ ដើម្បីឆ្លើយតបក្នុងអនុសាសន៍ នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ២០១៩ ជុំទី៣ និងឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន នៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៦.**ត្រួតពិនិត្យ កែសម្រួលខ្លឹមសារ SOP រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ជាភាសាខ្មែរ ដោយមានការចូលរួមពី ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។ **៧.**តាមរយៈប្រព័ន្ធវីដេអូ ស្តីពីលទ្ធផលនៃការអនុវត្តសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ ជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប នៅសាលប្រជុំ គ.ជ.ប.ជ។ **៨.**តាមរយៈប្រព័ន្ធវីដេអូ ស្តីពីការពង្រឹងដំណើរការ នៃការធ្វើមាតុភូមិនិវត្តន៍ សម្រាប់ជួយជនរងគ្រោះដោយសារការជួញដូរមនុស្ស សញ្ជាតិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **មុំ ប៊ុនថន** រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ **៩.**ផែនការបណ្តុះបណ្តាលការកំណត់អត្តសញ្ញាណជនរងគ្រោះ"។ **១០.**រៀបចំបង្កើតតារាងទិន្នន័យជនរងគ្រោះដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់"។ **១១.**ការងារស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសនានា អំឡុងពេលរាតត្បាតកូវីដ-១៩" តាមប្រព័ន្ធអនឡាញ ZOOM ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការអភិវឌ្ឍន៍នានា ក្នុងប្រទេសកម្ពុជា។ **១២.**ស្តីពី "បែបបទ ផែនការសកម្មភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រាប់ដាក់បញ្ចូលផែនការជំរុញអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ" នៅសាលប្រជុំ គ.ជ.ប.ជ។ **១៣**-ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) តាមប្រព័ន្ធអនឡាញ ចំនួន៣លើក ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានអ្នកចូលរួមប្រមាណ ២០០នាក់។ **១៤**-ស្តីពីការរៀបចំកម្មវិធីអន្តរសាសនា លើកទី៤ ឆ្នាំ២០២១ ចំនួន០៣លើក តាមប្រព័ន្ធវីដេអូអនឡាញ ដែលមានការអញ្ជើញចូលរួមពីតំណាងភាគីពាក់ព័ន្ធ គណៈដឹកនាំជាន់ខ្ពស់ នៃឥស្លាមសាសនា បរិស័ទកាតូលិក គ្រិស្ទបរិស័ទ និងនិកាយសាសនាទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា តំណាងព្រះសហគមន៍កាតូលិកកម្ពុជា តំណាងពីអង្គការការីតា

	សកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១៥**-តាមប្រព័ន្ធអនឡាញ ស្តីពីវឌ្ឍនភាព និងរបៀបរបបការងារ របស់អ្នកអនុវត្តនៅក្នុងមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១៦**-ស្តីពីការរៀបចំរបាយការណ៍សមាគមនារីរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អញ្ជើញចូលរួមក្នុងកិច្ចពិភាក្សានាពេលនោះមាន លោក **កែប សារឿន** ទីប្រឹក្សា គ.ជ.ប.ជ, លោក **អោក ភានិន** កញ្ញា **សំ ច័ន្ទធីតា** និង លោក **សេង សុភ័ក្រ** នៅសាលប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ ។ **១៧**-ពិនិត្យផ្តល់ជាតុចូលបន្ថែមចំនួន៣ចំនុច ដែលនៅខ្វះខាតជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ក្រុមជំនួយកិច្ចការពាក់ព័ន្ធការជួយកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងជួញដូរកម្លាំងពលកម្ម អញ្ជើញចូលរួមក្នុងកិច្ចប្រជុំ មានលោក កែប សារឿន ទីប្រឹក្សា គ.ជ.ប.ជ លោកប្រធានក្រុម អនុប្រធាន ក្រុមជំនួយកិច្ចការយុត្តិធម៌ ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ និងក្រុមជំនួយកិច្ចការជួយជនរងគ្រោះ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ វត្តមានសរុប ០៨នាក់(ស្រី២នាក់)។ **១៨**-តាមប្រពន្ធ័ Video Zoom ស្តីពីកិច្ចពិភាក្សាសម្រាប់ត្រៀមប្រជុំទ្វេភាគី រវាងកម្ពុជា-ថៃ លើឧបសម្ព័ន្ធ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលរៀបចំឡើងដោយក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន វត្តមានអញ្ជើញចូលរួម មាន ឯកឧត្តម **លី តុងហ៊ុយ** អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ទោ **សេក ស៊ីវ៉ែត** ប្រធានក្រុមជំនួយកិច្ចការ ការពារជនរងគ្រោះ ក្រសួងនិងស្ថាបន័ពាក់ពន្ធ័មាន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងការបរទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ប្រធានមណ្ឌលសំចត ប៉ោយប៉ែត កំរៀង ព្រមទាំងស្ថាបន័ និងអង្គការដៃគូពាក់ពន្ធ័ផ្សេងទៀត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **១៩**-ស្តីពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមប្រមាណ ៦៣នាក់។ **២០**-ពិធីចុះកិច្ចព្រមព្រៀងអំពីកិច្ចសហការគ្នា ស្តីពីការផ្លាស់ប្តូរវិធ្យាបថបុគ្គល និងសហគមន៍ ដើម្បីលើកកម្ពស់សុវត្ថិភាពជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រវាង គ.ជ.ប.ជ ជាមួយអង្គការមូលនិធិហាហ្គាអន្តរជាតិ នៅសាលប្រជុំគ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង លោកស្រី **កុយ គៀង** ប្រធានអង្គការហាហ្គា ប្រចាំកម្ពុជា មានអ្នកចូលរួមចំនួន ១៦នាក់ ស្រី០៤នាក់។
អន្តរក្រសួង ស្ថាប័ន សហការ និងរៀបចំកិច្ចប្រជុំ បានចំនួន ៤៧លើក មានមនុស្សចំនួន ៦២៤នាក់ ស្រី ២១៨នាក់	
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	ការរៀបចំកិច្ចប្រជុំ បានចំនួន **២៤**លើក ដែលមានមនុស្សចូលរួមសុបចំនួន **២៨៣**នាក់ ស្រី **៨៨**នាក់ រួមមាន ▪ បានរៀបចំដឹកនាំកិច្ចប្រជុំ៖ -**១**-របាយការណ៍ឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវ ភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២១។ **២**-ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៅទីស្តីការក្រសួង ស.អ.យ។ **៣**-កែសម្រួលកិច្ចព្រមព្រៀងរបស់អង្គការបេសកកម្មទូទាំងពិភពលោក (The Mssion WorlWide) ដោយការិយាល័យនីតិកម្ម និងអធិការកិច្ច មានការចូលរួមពីមន្ត្រីជំនាញរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងតំណាងអង្គការ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ សរុបចំនួន ០៦នាក់ (ស្ត្រី ០២នាក់)។ **៤**-ចង្អៀតក្រុមការងារជួយជនរងគ្រោះចំនួន ០២លើក ស្តីពីកិច្ចពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីជួយជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា អំឡុងពេលរោគរាត្បាតកូវីដ ១៩ តាមប្រព័ន្ធអនឡាញ ZOOM មានអ្នកចូលរួមចំនួន ៣៨នាក់(ស្រី ១២នាក់)។ **៥**-ស្តីពីការគ្រប់គ្រងទិន្នន័យជនរងគ្រោះ និងងាយរងគ្រោះ និងសមាហរណកម្ម តាមអនឡាញ ដែលបានដឹកនាំមន្ត្រីគ្រប់គ្រងករណីប្រជុំ ជាមួយអង្គការរតនៈអ៊ិនធើណេសិនណល ដោយលោកស្រី **ឈា ម៉ានិត** ប្រធានមឈ្ឈ្ឈមណ្ឌលសំចតប៉ោយប៉ែត។ **៦**-ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៅទីស្តីការក្រសួង ស.អ.យ។ **៧**-កែសម្រួល

	កិច្ចព្រមព្រៀងរបស់អង្គការបេសកកម្មទូទាំងពិភពលោក (The Mission WorldWide) ដោយមានការចូលរួមពីមន្ត្រីជំនាញរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងតំណាងអង្គការ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ដែលមានអ្នកចូលរួមសរុប ០៦នាក់(ស្រី០២នាក់) (ការិយាល័យនីតិកម្ម និងអធិការកិច្ច)។ **៨**-ថ្នាក់បច្ចេកទេស (កម្រិតជំនាញ) ពិភាក្សាសម្រាប់ត្រៀមប្រជុំទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងថៃ លើទម្រង់របាយការណ៍សម្ភាសន៍ និងផែនការអនុវត្តនៃនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ZOOM អ្នកចូលរួមសរុប ៣៦នាក់ (ស្រី ១០នាក់)ដែលជាមន្ត្រីជំនាញពីបណ្តាក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធ ដោយសហការជាមួយអង្គការអន្តរជាតិ ទេសន្តរប្រវេសន៍(IOM)។ **៩**-ប្រចាំឆមាសទី១ ឆ្នាំ២០២១ ស្តីពីការត្រួតពិនិត្យ និងពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តសកម្មភាពការងាររបស់ក្រុមការងារការពារជនរងគ្រោះ អ្នកចូលរួមសរុប ៦០នាក់(ស្រី១៩នាក់)។ **១០**- ត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៅទីស្តីការក្រសួង ស.អ.យ។ **១១**-ចង្អៀតជាមួយក្រុមការងារបច្ចេកទេស ដើម្បីរៀបចំនីតិវិធីការអនុវត្តន៍គោលការណ៍ណែនាំ នៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញមនុស្ស ចំនួន ០៥លើក មានអ្នកចូលរួម ៧៣នាក់ (ស្រី ២០នាក់) ដែលអញ្ជើញមកពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង(ការងារ ការបរទេស យុត្តិធម៌ សុខាភិបាល) អគ្គស្នងការនគរបាលជាតិ នគរបាលអន្តោប្រវេសន៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ(ភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ) មណ្ឌលសំចតប៉ោយប៉ែត និងអង្គការដៃគូពាក់ព័ន្ធ មានអង្គការរតនៈអ៊ីនធើណេសិនណល អង្គការ IOM អង្គការ IJM អង្គការចាប់ដៃ និងគម្រោង កម្មវិធី ASEAN-ACT តាមប្រព័ន្ធអនឡាញ (ZOOM)។ **១២**-ថ្នាក់បច្ចេកទេសដើម្បីត្រៀមប្រជុំជាមួយភាគីថៃ ស្តីពី "ការពិនិត្យពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធក្នុងការអនុវត្តនីតិវិធីប្រតិបត្តបទដ្ឋាន SOPs រវាងព្រះរាជាណាចក្រកម្ពុជា-ថៃ" ចំនួន ០៣លើក មានសមាសភាពចូលរួម ២៧ (ស្រី ០៥នាក់) ដែលអញ្ជើញមកពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង(ការងារ ការបរទេស យុត្តិធម៌ សុខាភិបាល) អគ្គស្នងការនគរបាលជាតិ នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិ(កោះកុង កំរៀង និងស្ទឹងបត់) នាយកដ្ឋាន(សុខុមាលភាពកុមារ និងសុខុមាលភាពសង្គម) និងអង្គការដៃគូពាក់ព័ន្ធ មានអង្គការរតនៈអ៊ីនធើណេសិនណល អង្គការ IOM អង្គការ IJM អង្គការចាប់ដៃ និងគម្រោង កម្មវិធី ASEAN-ACT ។ **១៣**-រវាងក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ស្តីពី "ការពិក្សាការងារសាងសង់មណ្ឌលសំចត និងស្តានីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនរងគ្រោះផ្សេងទៀត" នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ តំណាងភាគីកម្ពុជា និងលោកស្រី Ureerat Chareontoh ប្រធានដឹកនាំគណៈប្រតិភូថៃ តាមប្រព័ន្ធ Zoom និងដោយផ្ទាល់ នៅទីស្តីការក្រសួង ស.អ.យ ដែលមានអ្នកចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបចំនួន ២៩នាក់ ស្រី ១៣នាក់ ក្នុងនោះមានភាគីថៃចំនួន ០៨នាក់។ -និងបានសហការជាមួយអង្គការរតនៈអ៊ីនធើណេសិនណលចំនួន ៤លើក ស្តីពី៖ **១.** គម្រោងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២១ របស់នាយកដ្ឋាន។ **២.**គម្រោងកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះ នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត(ខេត្តបន្ទាយមានជ័យ)។ **៣.**ការអនុវត្តសកម្មភាពការងារសម្រាប់ឆ្នាំ២០២១។ **៤.**ការពិនិត្យ ឡើងវិញនូវលំហូរ នៃដំណើរការមាតុភូមិនិវត្តន៍ និងសេចក្តីព្រាង(តាមZOOM)។
ក្រសួងអប់រំ យុវជន និងកីឡា	▪ បានដឹកនាំ និងសហការ រៀបចំកិច្ចប្រជុំ បានចំនួន **១០**លើក ដែលមានមនុស្សចូលរួមសុបចំនួន **២៣៤**នាក់ ស្រី **៧៥**នាក់ រួមមាន៖ -**ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានប្រជុំពិភាក្សា៖ **១**-រៀបចំសមាសភាពក្រុមការងារ និងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលសៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ជាមួយនាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា វត្តមានចូលរួមចំនួន ១២នាក់(ស្រី ០១នាក់)។ **២**-

	ស្តីពីការរៀបចំឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីបង្រៀនបន្តដល់គរុសិស្ស សម្រាប់បង្រៀនសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ លើសៀវភៅ **ការអប់រំស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលាគរុកោសល្យខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន ១៦នាក់(ស្រី ០៣នាក់)។ **៣**-តាមប្រព័ន្ធអនឡាញជាមួយអង្គការ APLE ស្តីពីការពង្រឹងនិងលើកកម្ពស់ការរាយការណ៍ ករណី សង្ស័យនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ នៅក្រសួងអប់រំ យុវជន និងកីឡា។ **៤**-ជាក្រុមការងារការពារជនរងគ្រោះស្តីពី "វឌ្ឍនភាពការងាររបស់ក្រុមការងារការពារជនរងគ្រោះប្រចាំត្រីមាសទី២ ឆ្នាំ២០២១"។ **៥**-ពិនិត្យលើវីដេអូមេរៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស(មធ្យមសិក្សាបឋមភូមិ) មានអ្នកចូលរួមចំនួន ១២នាក់ (ស្រី ០៥នាក់)។ **៦**-តាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យលើខ្លឹមសារមេរៀនចំណាកស្រុកដើម្បីឱ្យស្របគ្នាជាមួយឯកសាររបស់ក្រសួងអយក ដោយបានសហការជាមួយ គណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួង អ.យ.ក និងអង្គការ សាម៉ារីតាន់ ហ្វឺស មានអ្នកចូលរួមចំនួន ៣២នាក់ (ស្រី ១០នាក់)។ **៧**-ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី "ផែនការជាតិសម្រាប់អនុវត្តកតិការសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" មានអ្នកចូលរួមចំនួន ១១៧នាក់(ស្រី ៥៦នាក់)។ **៨**-ក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សបានរៀបចំកិច្ចប្រជុំប្រឹក្សាយោបល់ សម្រាប់ការពង្រឹងយន្តការក្រុមការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំយុវជន និងកីឡាក្រុង ខណ្ឌ ស្រុក គ្រឹះស្ថានសិក្សា មានអ្នកចូលរួមចំនួន ៤៥នាក់។ **៩**-ស្តីពី "គម្រោងអភិវឌ្ឍផ្នែកសមត្ថភាពភាសារបរទេស (ថៃ-ខ្មែរ) និងការចុះក្នុងតំបន់ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងសាលារៀន ក្នុងខេត្តកោះកុង"។ **១០**-ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	▪ ថ្នាក់ដឹកនាំ និងក្រុមការងារ បានរៀបចំកិច្ចប្រជុំ៖ -ថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៦ នៃប្រទេស CLMTV (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ រៀតណាម) ដើម្បីពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាងសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារ ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ក្រៅប្រទេស CLMTV ដែលត្រូវពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី៦ និងថ្នាក់មន្ត្រីការងារលើកទី៤ ដែលប្រទេសឡាវនឹងធ្វើជាម្ចាស់ផ្ទះ។ -ជាមួយសមាគមផ្នែកថែទាំសំអាតអាគារ នៃប្រទេសជប៉ុន ដែលផ្តោតទៅលើការរៀបចំតេស្តជំនាញថែទាំសំអាតអាគារក្នុងគម្រោងពលករជំនាញ នៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១។ -អនុព័ន្ធការងារប្រចាំស្ថានទូតកម្ពុជានៅប្រទេសថៃ បានជួបប្រជុំជាមួយភាគីថៃ ស្តីពីការបន្តសុពលភាពលិខិតធ្វើដំណើររបស់ពលករកម្ពុជា។ -ថ្នាក់មន្ត្រីជាន់ខ្ពស់កម្ពុជា-ថៃ តាមប្រព័ន្ធវីដេអូអនឡាញ ជាមួយក្រសួងការងារនៃព្រះរាជាណាចក្រថៃ ស្តីពី "ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា" ស្តីពី "កិច្ចសហប្រតិបត្តិការនៃវិស័យការងារ និងកិច្ចព្រមព្រៀង" ស្តីពី "ការប្រើប្រាស់កម្លាំងពលកម្មរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍" ក្នុងអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផល ៖ **(ក)**.ភាគីថៃ បានជូនដំណឹងថា ភាគីថៃបាននិងកំពុងស្នើសុំគោលការណ៍ គណៈរដ្ឋមន្ត្រីថៃ ស្តីពីការរៀបចំគោលការណ៍ណែនាំ ដើម្បីពន្យារពេល និងអនុគ្រោះដល់ពលករបរទេស អាចអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការនៅប្រទេសថៃ រហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ចំពោះពលករបរទេសដែលបំពេញបែបបទទៅតាមនីតិវិធីចំនួន២ រួមមាន៖ (១) ក្នុងករណីលិខិតឆ្លងដែន ឬឯកសារដែលប្រើជំនួសលិខិតឆ្លងដែនផុតសុពលភាពពលករត្រូវតែបន្តសុពលភាពឯកសារឱ្យរួចរាល់យ៉ាងយូរត្រឹមថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ដើម្បីដាក់ពាក្យស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នក្នុងប្រទេសថៃ និង (២)

	ដាក់ពាក្យស្នើសុំបន្តប័ណ្ណអនុញ្ញាតការងារថ្មីមុនពេលប័ណ្ណអនុញ្ញាតការងារចាស់ផុតសុពលភាព។ **(ខ).**ភាគីថៃ បានស្នើសុំភាគីកម្ពុជា បន្តសុពលភាពប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) និងលិខិតធ្វើដំណើរពលករកម្ពុជាទៅធ្វើការនៅបរទេស (TD) ដល់ពលករកម្ពុជាដែលផុតសុពលភាព/ជិតសុពលភាព។ ភាគីកម្ពុជាបានឆ្លើយតបទៅភាគីថៃថា ដោយសារការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសទាំងពីរ ភាគីកម្ពុជានឹងអនុវត្តនីតិវិធីដែលមានស្រាប់ ក្នុងការសម្របសម្រួលបន្តសុពលភាពប័ណ្ណ OCWC និងលិខិតធ្វើដំណើរ TD ក្នុងករណីបន្ទាន់។ ភាគីកម្ពុជា នឹងពិភាក្សាសារជាថ្មីជាមួយភាគីថៃ ក្នុងការបញ្ជូនក្រុមការងារផ្តល់ភាពស្របច្បាប់ទៅប្រទេសថៃ នៅពេលដែលស្ថានភាពការរីករាលដាលជំងឺកូវីដ-១៩ នៃប្រទេសទាំងពីរ ត្រូវបានគ្រប់គ្រង។ **(គ).**ភាគីទាំងពីរ នឹងពិភាក្សាការបញ្ជូន និងការទទួលពលករកម្ពុជាថ្មីទៅធ្វើការនៅប្រទេសថៃតាមរយៈប្រព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា (MOU) បន្ទាប់ពីភាគីថៃទទួលបានការអនុម័តគណៈរដ្ឋមន្ត្រីថៃ ស្តីពីការរៀបចំនីតិវិធីទទួលពលករបរទេសតាមរយៈ MOU នៅពេលស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ ត្រូវបានប្រសើរឡើងនៅប្រទេសថៃ។ -ជាមួយសមាគមផ្នែកថៃទាំសំអាតអាគារ នៃប្រទេសជប៉ុន ដែលផ្តោតទៅលើការរៀបចំតេស្តជំនាញថៃទាំសំអាតអាគារក្នុងគម្រោងពលករជំនាញ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
ក្រសួងកិច្ចការនារី	បានដឹកនាំ និងសហការរៀបចំកិច្ចប្រជុំ បានចំនួន **០៣**លើក ដែលមានមនុស្សចូលរួមសុបចំនួន **១០៧**នាក់ ស្រី **៥៥**នាក់ រួមមាន៖ ▪ ក្រោមអធិបតីភាព**លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានសហការ និងរៀបចំកិច្ចប្រជុំ៖ **១**-ត្រៀមពិនិត្យ និងពិភាក្សា ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ មុននឹងឈានទៅកការរៀបចំកិច្ចប្រជុំជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ដែលគ្រោងនឹងធ្វើនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ Zoom មានអ្នកចូលរួមចំនួន ៤៣ នាក់(ស្រី ២៣នាក់)។ **២**-ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រ ស្តីពីពាក់ព័ន្ធនឹងការដាក់ចំណាត់ថ្នាក់លេខ២ ក្រោមបញ្ជីឃ្លាំមើល និងអនុសាសន៍ ទាំង១៦ចំណុច ក្នុងរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតប និងការបកស្រាយបំភ្លឺនូវអនុសាសន៍ទាំងនេះ ដែលអាមេរិកបានស្នើមកកម្ពុជា នៅទីស្តីការក្រសួងយុត្តិធម៌។ ▪ បានសហការរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ី វណ្ណឌី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធវីដេអូ Zoom មានអ្នកចូលរួមចំនួន ៦៤ នាក់(ស្រី ៣២នាក់)។
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	▪ បានរៀបចំកិច្ចប្រជុំផែនការសម្រាប់អនុវត្តសកម្មភាពជាក់លាក់នៃគោលបំណងកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ដែលបានឯកភាពគ្នាជ្រើសរើសគោលបំណងអាទិភាពចំនួន ០៣ ក្នុងចំណោមគោលបំណងទាំង២៣ សម្រាប់ពិភពលោក តាមសំណើសុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ▪ បានសហការរៀបចំយុទ្ធនាការ «គិតគូរកូន» មាតិកាព័ត៌មាន ដូចជា វីដេអូព័ត៌ សៀវភៅអាន គន្លឹះសំខាន់ៗ ការណែនាំ សម្រង់មតិ និងកម្មវិធីផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីហានិភ័យនៃ ប្រព័ន្ធអនឡាញចំពោះកុមារ ដោយផ្តល់ព័ត៌មាន និងគន្លឹះសំខាន់ៗដល់កុមារ មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធ អំពីហានិភ័យ វិធីសាស្ត្រការពារនិងដំណោះស្រាយបញ្ហានានា ដែលកើតមានឡើងពេលកុមារ ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។

	▪ បានរៀបចំកិច្ចប្រជុំពិភាក្សាលើធាតុចូល អំពីតួនាទីភារកិច្ចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៃសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារ។
ក្រសួងទេសចរណ៍	▪ បានរៀបចំកិច្ចប្រជុំណែនាំដល់ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត តាមរយៈប្រព័ន្ធអនឡាញ ស្តីពីវិធានការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ពិសេសការធ្វើអាជីវកម្ម ផ្លូវភេទលើស្ត្រី និងកុមារនៅតាមឧស្សាហកម្មសណ្ឋាគារ។
លេខាធិការដ្ឋាន គ.ខ.ប.ជ អង្គការដៃគូ បានសហការ និងរៀបចំកិច្ចប្រជុំ បានចំនួន ៣៦៤លើក មានសិក្ខាមចំនួន ៨.២៩៤នាក់ ស្រី ៤.១១៣នាក់	
ខេត្តឧត្តរមានជ័យ	▪ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ជាមួយគណៈកម្មធិការជាតិ គ.ជ.ប.ជ ស្តីពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ លើសុខភាពផ្លូវចិត្ត ការពង្រឹងផ្លូវចិត្ត និងការជួញដូរមនុស្ស សម្រាប់បុគ្គលស្ថិតក្នុងមណ្ឌលចត្តាឡីស័ក ដោយមានអ្នកចូលរួមពីប្រធាន អនុប្រធាន និងសមាជិកក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត ចំនួន ០៤នាក់ ស្រី ០៣នាក់។
ខេត្តព្រះវិហារ	▪ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំប្រកាសសេចក្តីសំរេចគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានខេត្ត ០១ លើក អ្នកចូលរួម២៤នាក់ ស្រី១០នាក់។
ខេត្តបាត់ដំបង	▪ ប្រធានគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បាន៖ - សហការជាមួយប្រធានអង្គការ Winrock និងសហការរី ដើម្បីប្រជុំពិភាក្សាអំពីពលករដែលវិលត្រឡប់មកកម្ពុជាវិញ ដែលធ្វើការនៅក្រៅប្រទេស និងគ្រោងរបស់អង្គការដែលជួយដល់ជីវភាពពួកគាត់ ប្រព័ន្ធវីដេអូ។ - ដឹកនាំកិច្ចប្រជុំ ស្តីពីការរឹតបន្តឹងបន្ថែម និងចាត់វិធានការថ្មី ដើម្បីបង្ការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលករ នៅក្នុងភូមសាស្ត្រស្រុកកំរៀង ភ្នំព្រឹក និងស្រុកសំពៅលូន បានចំនួន ០៦លើក។ - បានសហការរៀបចំពិធីសម្ពោធមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង។ - បានរៀបចំកិច្ចប្រជុំពិភាក្សាការងារសម្ពោធមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តាមប្រព័ន្ធ Zoom។
ខេត្តប៉ៃលិន	▪ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានប្រជុំពិភាក្សាជាមួយអាជ្ញាធរថៃ បានចំនួន ០៥លើក ស្តីពីការស្នើសុំឱ្យភាគីថៃ ជួយសម្រួលពលករខ្មែរដែលវិញត្រឡប់មកកម្ពុជាវិញតាមច្រកអន្តរជាតិព្រំ។
ខេត្តសៀមរាប	▪ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត ក្រុង ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស និងឆមាស ឆ្នាំ ២០២១ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៣២លើក អ្នកចូលរួមចំនួន ១.៥៦៥នាក់ ស្រី ៦៨៨នាក់។ ▪ លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន គ.ជ.ប.ជ និង ឯកឧត្តម **អ៊ាន យុន** ប្រធានក្រុមប្រឹក្សាខេត្ត បានចំនួន ០១លើកដែលមានអ្នកចូលរួមសរុប ១៨០នាក់ ស្រី ៥៩នាក់។

	▪ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារបច្ចេកទេសមកពីស្នងការនគរបាលខេត្ត មន្ទីរអប់រំយុវជននិងកីឡា មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារី និងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំពិភាក្សា៖ **១**-ស្តីពីការអនុវត្តគម្រោងលើកម្ពស់ និងពង្រឹងអំណាចសេដ្ឋកិច្ចទៅលើវិស័យសេដ្ឋកិច្ចគ្រួសារ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាធ្ងន់ធ្ងរផ្នែកយេនឌ័រ នៅក្នុងចំណោមពលករចំណាកស្រុកដែលបានវិលត្រឡប់មកកម្ពុជាវិញ តាមប្រព័ន្ធអនឡាញ ចំនួន **០១**លើក។ **២**-បានផ្តល់បទសម្ភាសន៍ការប្រមូលធាតុចូលសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការសកម្មភាពជាតិ៥ ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអ្នកវាយតម្លៃរបស់អង្គការនីរ៉កអន្តរជាតិ តាមប្រព័ន្ធបញ្ជូនរូបភាព និងសំលេង (zoom) បានចំនួន **០១លើក**។ **៣**-លើការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២១ ជាមួយមន្ទីរ អង្គការភាព និងអង្គការដៃគូជាតិ អនត្តជាតិ បានចំនួន ០២លើក ដែលមានចំនួនចូលរួមសរុប ៧៥នាក់/ស្រី៣២នាក់។
ខេត្តកំពង់ធំ	▪ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យផែនការសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងប្រជុំប្រចាំខែ ដែលមានសមាសភាពចូលរួម សរុបចំនួន ២៦ នាក់ ស្រីចំនួន ១០នាក់ ។
ខេត្តកំពង់ចាម	▪ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានដឹកនាំរៀបចំកិច្ចប្រជុំថ្នាក់ខេត្ត ក្រុង ស្រុក ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ៥៦លើក ដែលមានមនុស្សចូលរួមសុបចំនួន ១.៦៣៧នាក់(ស្រី ៨៧៦នាក់)។ ▪ លោកជំទាវ **ប៉ាង ដានី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ខ.ប.ជ បានដឹកនាំក្រុមការងារលេខាធិការដ្ឋានខេត្ត រៀបចំកិច្ចប្រជុំ៖ **១**-ត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាសទី៣ និង ការវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ២០២១ តាមរយៈប្រព័ន្ធ Video zoom មានអ្នកចូលរួមចំនួន ៤០ នាក់ (ស្រី២២នាក់)។ **២**-បូកសរុបលទ្ធផលប្រចាំខែកក្កដា និងទិសដៅសម្រាប់ខែសីហា ឆ្នាំ២០២១ ស្តីពីការអនុវត្តការងាររបស់ក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរ មានសមាសភាពចូលរួមសរុប ១៩ នាក់ (ស្រី ០៧នាក់)។ **៣**-បានសហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ រៀបចំកិច្ចប្រជុំពី "ការផ្សព្វផ្សាយលទ្ធផលការងារ និងការរៀបចំផែនការគៀងគរធនធានដោះស្រាយបញ្ហាពលករ ក្នុងខេត្តកំពង់ចាម" សមាសភាពចូលរួមសរុប ២៤នាក់ ស្រី១៦នាក់។
ខេត្តត្បូងឃ្មុំ	▪ លោកជំទាវ **នី ចាន់ធីតា** ប្រធានធិការ គ.ខ.ប.ជ ខេត្ត បានដឹកនាំក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត រៀបចំកិច្ចប្រជុំពិភាក្សាលើការពង្រឹងតួនាទី ភារកិច្ច រចនាសម្ព័ន្ធ របៀបរបបធ្វើការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តត្បូងឃ្មុំ ។ ដោយមានការចូលរួម ពីសំណាក់ លោកព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត លោកនាយករង រដ្ឋបាលសាលាខេត្ត លោក លោកស្រី ប្រធាន អនុប្រធាន មន្ទីរអង្គភាពជុំវិញខេត្ត អភិបាលស្រុក\ក្រុងទាំង៧ ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកព្រំដែនអន្តជាតិ ច្រកទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងអ្នកពាក់ព័ន្ធចំនួន ៣៧នាក់។ ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងារ ពង្រឹងតួនាទី ភារកិច្ច រចនាសម្ព័ន្ធ របៀបរបបធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
កំពង់ឆ្នាំង	▪ លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារបានរៀបចំកិច្ចប្រជុំ៖ **១**-របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង១០ខែឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូជាមួយនឹងមន្ត្រីថ្នាក់ក្រុង ស្រុក ចំនួន១៦លើក ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងាររដ្ឋបាលផ្សេងៗ អ្នកចូលរួមចំនួន ២៩៣នាក់ ស្រី ១២៥នាក់។

	២-ប្រមូលធាតុចូលសម្រាប់ វាយតម្លៃពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សរបស់លេខាធិការដ្ឋាន (គ.ខ.ប.ជ) ខេត្ត តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេង Zoom។ ▪ ក្រុមការងារលេខាធិការថ្នាក់ស្រុក គ.ក.ស.ក សមាគមនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ស្រុក គណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក និងនាយប៉ុស្តិ៍រដ្ឋបាលឃុំ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស បានចំនួន ០៣លើក មានអ្នកចូលរួមចំនួន ៤៤៤នាក់ (ស្រី ២១៨នាក់) តាមប្រព័ន្ធអនឡាញ។ ▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ០២លើក អ្នកចូលរួមចំនួន៣៧នាក់ ស្រី៣៣នាក់។
ខេត្តកំពង់ស្ពឺ	▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូចំនួន០២លើក (១.ពិភាក្សាយុទ្ធសាស្ត្រសម្រាប់សកម្មភាពដែលនៅសល់ អ្នកចូលរួមចំនួ១១នាក់ ស្រី០៩នាក់ ២.ស្តីពីការ រៀបចំផែនការសកម្មភាពរបស់ថ្នាក់ក្រោមជាតិ ក្រោមការគាំទ្ររបស់កម្មវិធី ACCESS អ្នកចូលរួមចំនួន៣១នាក់ ស្រី២៦នាក់)។
ខេត្តព្រៃវែង	▪ ឯកឧត្តម **ជា សុមេធិ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានដឹកនាំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ រៀបចំកិច្ចប្រជុំ៖ **១**-ដើម្បីផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសិវិត្តិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតពីការជួញដូរមនុស្ស និងល្បិចកលជនល្មើសដែលមានអ្នកចូលរួម ៨៤នាក់ ស្រី១០នាក់។ **២**-និងកិច្ចសហប្រតិបត្តិការក្សាសុវត្ថិភាពនៅតាមព្រំដែន ការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនាំមនុស្សឆ្លងដែនខុសច្បាប់ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមបន្ទាត់ព្រំដែន។ **៣**-ដើម្បីត្រៀមទទួលពលករមកពីប្រទេសថៃ តាមរយៈប្រព័ន្ធវីដេអូ។ **៤**-ស្តីពីការឧបត្ថម្ភថវិកាជូនដល់ពលករដែលវិលត្រឡប់ពីប្រទេសថៃ តាមរយៈប្រព័ន្ធវីដេអូ។ **៥**-ស្តីពីបច្ចុប្បន្នភាពនៃការគ្រប់គ្រងជំងឺកូវីដ១៩ ជាពិសេសមេរោគបំលែងថ្មីប្រភេទដែលតា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រព័ន្ធវីដេអូ។ ▪ លេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែធ្នូ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន ០១លើក អ្នកចូលរួម ២៨នាក់/ស្រី២០នាក់។
ខេត្តស្វាយរៀង	▪ លោកជំទាវ **ឯក សុវណ្ណាការ** អភិបាលរងខេត្ត និងជាអនុប្រធាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារ៖ **១**-រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងបរិបទកូវីដ-១៩ ឆមាសទី១ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ (Zoom) ដែលមានអ្នកចូលរួមចំនួន ៣៩នាក់ ។ **២**-បានអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីជួបប្រជុំប៉ាន់ប្រមាណតម្រូវការផ្នែកសុខភាពជនទេសន្តរប្រវេសន៍កម្ពុជាមកពីប្រទេសវៀតណាម និងការគ្រប់គ្រងរំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ក្នុងបរិបទការរាតត្បាតកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនចំនួន ០៤ គឺច្រកទ្វារព្រំដែនដូង ច្រកទ្វារព្រំដែនទ្វេភាគីបុសមន ច្រកទ្វារព្រំដែនអន្តរជាតិបាវិត និងច្រកទ្វារព្រំអន្តរជាតិព្រៃវល្លិ៍ ។
ខេត្តក្រចេះ	▪ លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ បានចំនួន ០២លើក ដែលមានមនុស្សចូលរួមសុបចំនួន ៤៣នាក់ ស្រី ១៩នាក់។ ▪ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំប្រជុំផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅភូមិចារថ្មោល ឃុំសំបូរ ស្រុកសំបូរ សរុបបានចំនួន០១លើក សមាសភាពចូលរួម សរុបចំនួន៩៦នាក់ ស្រី៤៨នាក់។

	▪ មន្ទីរអប់រំ យុវជននិងកីឡា បានប្រជុំផ្សព្វផ្សាយពីរបៀបធ្វើទិវា ១២ធ្នូ ទប់ស្កាត់ការជួញដូរមនុស្ស និងរំលោភបំពានពលកម្មកុមារ នៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យបានចំនួន០៣ស្រុក ក្នុងនោះមានមានលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស មាតា បិតាសិស្ស សរុបចំនួន២៤៤នាក់ស្រី១៥២នាក់។ ▪ មន្ទីរបានចូលរួមប្រជុំផ្សព្វផ្សាយនៅសាលាគរុកោសល្យ និងវិក្រិតការខេត្ត តាមរយៈប្រព័ន្ធអនឡាញ ស្តីពីការរំលោភបំពានគ្រប់រូបភាពលើកុមារពិសេសកុមារី និងកុមារត្រូវបានគេជួញដូរពលកម្ម នៅតាមមូលដ្ឋាន បាន០១លើក មានអ្នក ចូលរួមចំនួន៤៨នាក់ ស្រី៣០នាក់ដោយមានការចូលរួមពីសាលាចំនួន០៥ សាលាបឋមសិក្សាត្រពាំងព្រីង សាលាបឋមសិក្សាក្រុងក្រចេះ សាលាបឋមសិក្សាក្រគរ និងសាលាបឋមសិក្សារកាកណ្តាល។
ខេត្តស្ទឹងត្រែង	▪ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាខេត្ត បានបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ដើម្បីប្រមូលធាតុចូលលើមាតិកា នៃសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា ចំនួន០១លើក តាមប្រព័ន្ធ វីដេអូ អ្នកចូលរួមចំនួន៦៨នាក់។
ខេត្តឧត្តរមានជ័យ	▪ រៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០៣លើក អ្នកចូលរួមចំនួន៥០នាក់ ស្រី២៩នាក់។ ▪ រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន២១នាក់ ស្រី១៦នាក់។
ខេត្តកណ្តាល	▪ លោកជំទាវ **ហ៊ុន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បាន៖ **១**-ដឹកនាំក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១ បានចំនួន ១២លើក ដែលមានមនុស្សចូលរួមសុបចំនួន ៣៦០នាក់ ស្រី ២៥៩នាក់។ **២**-អញ្ជើញជាគណៈអធិបតីភាព ក្នុងកិច្ចប្រជុំផ្សព្វផ្សាយផែនការកិច្ចការពារកុមារថ្នាក់ខេត្ត ផ្តោតលើការថែទាំជំនួស និងអំពើហិង្សាលើកុមារ វត្តមានចូលរួមសរុបចំនួន ៥៧ នាក់ ស្រី ២៥នាក់។ ៣-ដឹកនាំក្រុមការងារថ្នាក់ខេត្តចំនួន ១៥រូប បានជួបប្រជុំការងារជាមួយឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំកម្ពុជា ដើម្បីស្វែងយល់ពីសកម្មភាពការងារកិច្ចការពារកុមារ នៅសាលប្រជុំសាលាខេត្ត អគារ(A)។ ▪ ក្រុមការងារលេខាធិការដ្ឋាន ក្រុង-ស្រុកទាំង១១ បានប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែ បានចំនួន ៤២លើក អ្នកចូលរួមចំនួន ១.២២៦នាក់ ស្រី ៥៨៧នាក់។ ▪ លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការកិច្ចការពារកុមារថ្នាក់ខេត្ត ផ្តោតលើការថែទាំជំនួស និងអំពើហិង្សាលើកុមារ ចំនួន ០១លើក អ្នកចូលរួមចំនួន ៥៧នាក់ ស្រី ២៥នាក់។ ▪ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ប្រចាំខែ ដោយបានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពចូលរួមដោយ ថ្នាក់ដឹកនាំមន្ទីរ លោកប្រធានការិយាល័យចំណុះមន្ទីរ ប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង/ស្រុកទាំង១១ លោកស្រីនាយិកាវិទ្យាល័យទូទាំងខេត្ត សរុបចំនួន ១៣៣នាក់ ស្រី ០៥នាក់ ។
ខេត្តកំពត	▪ លេខាធិការដ្ឋានបានរៀបចំកិច្ចប្រជុំ៖ **១**-ដើម្បីបូកសរុបលទ្ធផលការងារងប្រចាំឆ្នាំ និងការបំពេញកម្រងសំណួរសម្រាប់វាយតម្លៃការងារឆ្នាំ២០២០ មានអ្នកចូលរួម ២០នាក់ ស្រី ១០នាក់។ **២**-ផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗ ពាក់ព័ន្ធការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ និងការធ្វើពលកម្មដោយបង្ខំ មានអ្នកចូលរួម ១៨នាក់ ស្រី ១០នាក់ ។

	▪ ក្រុមការងារលេខាធិការដ្ឋាន ក្រុង-ស្រុកទាំង៥ បានប្រជុំប្រចាំខែ ចំនួន ៤៥លើក ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស និងការរំលោភផ្លូវភេទលើក្មេងស្រី អ្នកចូលរួមចំនួន ៨៣៧នាក់ ស្រី ៦៥០នាក់។
ខេត្តតាកែវ	▪ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំ៖ ○ ណែនាំដល់រដ្ឋបាល ក្រុង ស្រុក ស្តីពីការរៀបចំទទួលពលករវិលត្រឡប់មកពីក្រៅប្រទេស តាមរយៈប្រព័ន្ធវីដេអូ។ ○ ស្តីពីការណែនាំទប់ស្កាត់ដល់ប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសជិតខាង និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន ០៥លើក មានអ្នកចូលរួមសរុបចំនួន ៤១៣នាក់ ស្រី ៥១នាក់ តាមរយៈប្រព័ន្ធវីដេអូ។
ខេត្តកែប	▪ ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត បានដឹកនាំគណៈប្រតិភូខេត្តកែប ទៅចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលសហប្រតិបត្តិការរយៈពេល ០២ឆ្នាំ(២០១៧-២០១៨) ដែលខេត្តទាំងពីរ(កែប-គៀនយ៉ាង) រួមគ្នាអនុវត្តសម្រេចបានក្នុងរយៈពេល ០២ឆ្នាំកន្លងមក និងបានចុះហត្ថលេខាលើកំណត់ហេតុ ដើម្បីសហប្រតិបត្តិការ ០២បន្ត (២០១៩-២០២០) រវាងរដ្ឋបាលខេត្តកែប នៃព្រះរាជាណាចក្រកម្ពុជា ជាមួយខេត្តគៀនយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម នៅមន្ទីរគណៈកម្មាធិការប្រជាជនខេត្តគៀនយ៉ាង លើវិស័យជាច្រើន ក្នុងនោះក៏មានការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារឆ្លងដែនផងដែរ ។ ▪ គណៈកម្មាធិការរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាខេត្តកែប បានឯកភាពលើកំណត់ហេតុជាមួយគណៈកម្មាធិការរណសិរ្សមាតុភូមិខេត្តគៀនយ៉ាង នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមលើវិស័យមួយចំនួន ជាពិសេស ក្នុងនោះក៏មានការបង្កើនការផ្សព្វផ្សាយអំពីគោលនយោបាយជូនដល់មន្ត្រីរាជការគ្រប់មន្ទីរ អង្គភាព សមាជិកសមាគមនារីគ្រប់លំដាប់ថ្នាក់បានយល់ដឹង និងទប់ស្កាត់ការប្រឆាំងការជួញដូរស្ត្រី និងកុមារឆ្លងដែន។ ▪ សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកែប(កម្ពុជា) បានដឹកនាំក្រុមការងារធ្វើកិច្ចប្រជុំ និងធ្វើកិច្ចសន្យាជាមួយសហព័ន្ធសមាគមនារីខេត្តគៀនយ៉ាង(វៀតណាម)លើវិស័យមួយចំនួន រួមទាំងការងារទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារផងដែរ។
ខេត្តកោះកុង	▪ លេខាធិការដ្ឋា គ.ខ.ប.ជ ខេត្ត និងក្រុមការងារថ្នាក់ក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំ ចំនួន០២លើក អ្នកចូលរួម ៥១នាក់ ស្រី១៦នាក់។ ▪ ក្រុមការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សស្រុកបូទុមសាគរ បានរៀចំកិច្ចប្រជុំផ្សព្វផ្សាយអំពីតួនាទីភារកិច្ចជូនដល់សមាជិករបស់ខ្លួន និងណែនាំឱ្យពួកគាត់ជួយផ្សព្វផ្សាយបន្តនៅថ្នាក់មូលដ្ឋានបន្ត ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភសេពសន្តវៈ ក្រោមការដឹកនាំ ដោយលោកស្រី **អ៊ិន សោភ័ណ្ឌ** អភិបាលរងស្រុក មានអ្នកចូលរួមសរុប ៥១នាក់ ស្រី ១៦នាក់ នៅសាលប្រជុំសាលាស្រុក(បូទុមសាគរ និងមណ្ឌលសីមា)។ ▪ លោកស្រី **អ៊ិន សោភ័ណ្ឌ** អភិបាលរងស្រុកបូទុមសាគរ បានដឹកនាំក្រុមការងារស្រុក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីតួនាទីភារកិច្ចជូនដល់សមាជិករបស់ខ្លួន និងណែនាំឱ្យពួកគាត់ជួយផ្សព្វផ្សាយបន្តនៅថ្នាក់មូលដ្ឋានបន្ត ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភសេពសន្តវៈ ចំនួន០១លើក អ្នកចូលរួម ១៨នាក់ ស្រី ០៨នាក់។

ឧបសម្ព័ន្ធទី៤

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៨៧៦លើក) មនុស្សចំនួន ៧២.៧៨៤នាក់ (ស្រី ២៩.៥២០នាក់)

ស្ថាប័នសម្របសម្រួល	សកម្មភាព
គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)	**គណៈកម្មាធិការជាតិបានដឹកនាំសម្របសម្រួល ចំនួន ២៦៤លើក អ្នកចូលរួមសរុបចំនួន ១.៩២២នាក់ (ស្រី ៥១៣នាក់)** ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖ (១)ចុះទៅជួបសំណេះសំណាលជាមួយក្រុមការងារធ្វើចត្តាលីស័ក នៅសាលាព្រហ្មនិមិត្ត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (២)ជាអធិបតីភាពក្នុងពិធីប្រគល់-ទទួលសម្ភារប្រើប្រាស់ចាំបាច់សម្រាប់ស្ត្រី និងកុមារ ក្នុងស្ថានភាពប្រឈមជំងឺកូវីដ១៩ ពីអង្គការអភិវឌ្ឍន៍ UNFP។ (៣)ធ្វើទស្សនៈកិច្ចក្នុងទីស្នាក់ការអង្គការ តំណាក់ទឹក ដែលជាអង្គការធ្វើកិច្ចសហប្រតិបត្តិការផ្តល់សេវាផ្នែកអប់រំ ជ្លៀវជីវៈ ទៅកាន់កុមារដែលងាយរងគ្រោះ នៅខេត្តបន្ទាយមានជ័យ។ (៤)កិច្ចប្រជុំពិភាក្សាអំពី "វឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងដំណោះស្រាយ" ជាមួយឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ វត្តមានចូលរួមចំនួន ៣៣នាក់(ស្រី ១២នាក់)។ (៥)កិច្ចប្រជុំ របាយការណ៍ "ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១" នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន **១០៥**នាក់ ស្រី **៥៩**នាក់។ (៦)ពិធីសម្ពោធការចាប់ផ្តើមអនុវត្តន៍គម្រោងបញ្ចប់អំពើហឹង្សាលើកុមារនៅក្នុង និងជុំវិញសាលារៀន "End Violence Against Children Project (EDN VAC) in and around school " នៅសណ្ឋាគារសាន់វ៉ៃ ភ្នំពេញ ដោយមានការរៀបចំសម្របសម្រួលអង្គការ Save the Children ដែលមានអ្នកចូលរួមសរុប៥០នាក់ ។ (៧)កិច្ចប្រជុំត្រួតពិនិត្យ កែសម្រួលទៅលើសេចក្តីព្រាង គោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ នៅសាលប្រជុំ គ.ជ.ប.ជ។ (៨)ដឹកនាំក្រុមការងារ គ.ជ.ប.ជ និងលោកស្រីអភិបាលរងខេត្តសៀមរាម រួមនឹងប្រធានអង្គការអាយអូអឹម អង្គការWHO អង្គការយូនីសេហ្វ អង្គការយូអិនអេហ្វភីអេ អង្គការធីកីអូ មន្ត្រីគម្រោង RCO បានចុះតាមដានត្រួតពិនិត្យការអនុវត្តផែនការគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងយូអិន សម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងតំណាក់កាលកូវីដ-១៩ នៅសាលាស្រុកក្រឡាញ់ ខេត្តសៀមរាប។ (៩) ដឹកនាំក្រុមការងារ និងអង្គការដៃគូអភិវឌ្ឍ បានចុះសាកសួរ និងសំណេះសំណាលផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ ដែលជាពលករទេសន្តរប្រវេសន៍ទើបវិលត្រលប់ពីក្រៅប្រទេស ស្ថិតក្នុងភូមិល្បើក ឃុំជួនកែវ ស្រុកពួក និងភូមិ-ឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប និងបានចុះទស្សនកិច្ច ពិនិត្យផ្ទាល់ទៅដល់ទីកន្លែងសួនច្បារដំណាំ និងរោងចិញ្ចឹមសត្វ ដែលពួកគាត់ទទួលបានពីការឧបត្ថម្ភគាំទ្រ ពីគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ (១០)ពិធីប្រគល់ទទួលសម្ភារដែលឧបត្ថម្ភដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(With compliment from ASEAN-ACT) ពីតំណាងអង្គការ ASEAN-ACT ប្រចាំកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម ០៨នាក់ ស្រី០៤នាក់។ (១១)សកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ របស់ក្រសួងសុខាភិបាល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (១២)ប្រគល់ទទួលសម្ភារៈ

	ជាម៉ាសចំនួន៥កេសធំ ពីតំណាងអង្គការការីតាសកម្ពុជា ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (**១៣**)នាំយកនូវអំណោយ ផ្តល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំង ដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត មានលោកស្រីអភិបាលរងខេត្ត លោកអភិបាលក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ចែកជូនពលករវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩។ (**១៤**)ចូលរួមកិច្ចប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និង គ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព។ (**១៥**)ក្នុងពិធីប្រគល់ទទួលសម្ភារៈការិយាល័យ មានតុ៥សម្រាប់ ជូនរដ្ឋបាលសាលាស្រុកកំរៀង ប្រើប្រាស់ក្នុងមណ្ឌលទទួលពលករកំរៀង ស្ថិតក្នុងឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ដែលអមដំណើរដោយលោកជំទាវឧត្តមសេនីយ៍ឯក **វេជ្ជ. ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម ឧត្តមសេនីយ៍ឯក **យ៉ែម ចាន់ណារ៉ុ** អគ្គលេខាធិការរង គ.ជ.ប.ជ លោក**ស្រី ស៊ុំ ចិន្តា** អភិបាលរងខេត្តបាត់ដំបង លោកស្រីស្នងការរងនគរបាលខេត្ត លោក **ទិត្យ សត្យា** អភិបាលរងស្រុកកំរៀង តំណាងពីមន្ទីរពាក់ព័ន្ធ មានមន្ទីរការងារ មន្ទីរសង្គមកិច្ច មន្ត្រីរដ្ឋបាលស្រុកកំរៀង ប្រធាន និងតំណាងអង្គការការីតាសស្វីសនៅមណ្ឌលទទួលពលករកំរៀងខេត្តបាត់ដំបង។ (**១៦**)ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តមទេសរដ្ឋមន្ត្រី **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដែលបានធ្វើកាលកិរិយា ក្នុងជន្មាយុ៧៣ឆ្នាំ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ វេលាម៉ោង១៤ និង២៥នាទី។(**១៧**)ប្រគល់ និងទទួលសៀវភៅ របាយការណ៍លទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងទិសដៅ អនុវត្តឆ្នាំ២០២១ របស់ គ.ជ.ប.ជ មានតំណាងអង្គការអាស៊ាន-អាក់ Asian-Act ដែលជាអ្នកឧបត្ថម្ភគាំទ្រដល់ការបោះពុម្ពផ្សាយរបាយការណ៍នេះ និងមានការអញ្ជើញចូលរួមពី ឯកឧត្តមលោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ (**១៨**)ដឹកនាំក្រុមការងារតាមដានត្រួតពិនិត្យ គោលនយោបាយរាជរដ្ឋាភិបាលខេត្តកំពង់ឆ្នាំង រួមនិងក្រុមការងារ លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិកា រគ.ជ.ប.ជ លោកជំទាវ **វ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង ឯកឧត្តម **យ៉ែម ចាន់ណារ៉ុ** អគ្គលេខាធិការរង បាននាំយកនូវអំណោយសម្ភារៈប្រើប្រាស់ ជា(កញ្ចប់) ចំនួន៥០ ដែលបានមកពីការឧបត្ថម្ភគាំទ្រពីអង្គការ UNFPA ផ្តល់ជូនរដ្ឋបាលក្រុងកំពង់ឆ្នាំង ដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត មាន លោកអភិបាលរងក្រុង និងមន្ត្រីចំណុះរដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រាប់ផ្តល់ជូនពលកររវិលត្រឡប់ និងប្រជាជនដែលកំពុងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នៅក្រុងកំពង់ឆ្នាំង។ សម្ភារៈសម្រាប់ផ្តល់ជូនបងប្អូនពលករ ក៏ដូចប្រជាពលរដ្ឋម្នាក់ៗ អាចទទួលបានមួយកញ្ចប់មានៈ សារ៉ុង១ ក្រម៉ា១ សាប៊ូម្សៅ សាប៊ូដុំ ដែល លាងដៃ ម៉ាស់មួយប្រអប់ សំឡីអនាម័យ ថ្នាំដុសធ្មេញ ច្រាស់ដុសធ្មេញ។ (**១៩**)ដឹកនាំតាមដានត្រួតពិនិត្យគោលនយោបាយ ភូមិ/ឃុំមានសុវត្ថិភាពខេត្តកំពង់ឆ្នាំង និងថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានលោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធីការលោកជំទាវ **វ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង ឯកឧត្តម **យ៉ែម ចាន់ណារ៉ុ** អគ្គលេខាធិការរង បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧបាសិកា **អ៊ុន គីមសាន** ត្រូវជាម្តាយបង្កើតឯកឧត្តម **ហ៊ី ណាត** ទីប្រឹក្សាក្រសួងមហាផ្ទៃ ដែលបានទទួលមរណៈកាលពីថ្ងៃអង្គារ ១៣កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ វេលាម៉ោង១៥ និង២នាទីរសៀល ក្នុងជន្មាយុ ៩១ឆ្នាំ ដោយរោគាពាធ ដែលសពបានតំកល់ធ្វើបុណ្យ នៅគេហដ្ឋានរបស់ឯកឧត្តម បិតក្នុងភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង។ ២០-ជាអធិបតីពិធីប្រគល់ទទួល សម្ភារៈសុខាភិបាល មានដូចជា អាកុលចំនួន១០កាន ម៉ាស់៦០០០ ក្រដាស់ព៉ាម៥កេស ពីអង្គការ APLE ផ្តល់ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រាប់

	ប្រើប្រាស់ក្នុងកិច្ចការមនុស្សធម៌ ទៅដល់ព្រំដែនមូលដ្ឋាន និងសហគមន៍ទេសន្តរប្រវេសន៍ ដែលកំពុងជួបប្រឈមបញ្ហា ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩។ **២១**-ចូលរួមក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឆ្នាំ(២០២១-២០២៥) តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ដែលរៀបចំឡើងដោយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ មានអ្នកចូលរួមប្រមាណជិត ៤០០នាក់(ស្រី ១៨៥នាក់) ។ **២២**-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាវឌ្ឍនភាព នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រៀមឆ្លើយតបនឹងស្ថានទូតអាមេរិក ដែលដឹកនាំដោយក្រសួងកិច្ចការនារី មានលោកជំទាវបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី តាមប្រព័ន្ធវីដេអូ ZOOM។ **២៣**-កិច្ចប្រជុំត្រួតពិនិត្យការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម** ស ខេង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រព័ន្ធវីដេអូ ZOOM កិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូសន្និសីទ ZOOM មានការអញ្ជើញចូលរួមពី រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គលេខាធិការ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលប្រធានក្រុមប្រឹក្សានីតិកម្ម ព្រមទាំងអ្នកពាក់ព័ន្ធជាច្រើនរូបទៀត។ **២៤**-ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០២១ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៅកំពង់ឆ្នាំង តាមរយៈប្រព័ន្ធវីដេអូហ្សូម (ZOOM) ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ និងជាប្រធានក្រុមការងារ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង តាមក្រសួង-ស្ថាប័ន មួយចំនួនមានដូចជា ក្រសួងផែនការ ក្រសួងសាធារណៈការងឹកជញ្ជូន ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍជនបទ ជាអនុប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង អភិបាលរងខេត្ត ស្នងការខេត្ត មេបញ្ជាការអាវុធហត្ថ មន្ត្រីរដ្ឋបាលសាលាខេត្ត តំណាងពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អាជ្ញាធរដែនដី អភិបាល អភិបាលរងក្រុង-ស្រុក អធិការ នៃអធិការដ្ឋាននគរបាលក្រុងស្រុក ជុំវិញខេត្ត និងមន្ត្រីឃុំ-សង្កាត់។ **២៥**-ធ្វើដំណើរទស្សនកិច្ចសិក្សាវាយតម្លៃ អំពីស្ថានភាព និងតម្រូវការរបស់ពលករទេសន្តរប្រវេសន៍ ក្នុងតំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ខេត្តកោះកុង។ **២៦**-ជួបពិភាក្សាការងារជាមួយមន្ត្រីមានសមត្ថកិច្ចនៅច្រកទ្វារអន្តរជាតិចាំយាម ខេត្តកោះកុង មានអភិបាលរងខេត្ត ប្រធានច្រកព្រំដែនចាំយាម មន្ត្រីបច្ចេកទេសសុខាភិបាល និងអង្គការ IOM តំណាងធនាគារ ADB។ **២៧**-បានជួបពិភាក្សាការងារជាមួយកងកម្លាំងវរព្រំដែនសេនាតូចការពារព្រំដែនគោកលេខ៨២៧ ខេត្តកោះកុង។ **២៨**-សិក្ខាសាលា ស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនីតិសម្បទា និងជាប្រធាន ក.ជ.ក។ **២៩**-ជាអធិបតីភាព ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ នៅខេត្តសៀមរាប ដោយមានកិច្ចសហការជាមួយអង្គការ A២១ និងមានការចូលរួមពីមន្ត្រីជំនាញ អង្គការដៃគូពាក់ព័ន្ធមួយចំនួន សរុបប្រមាណ ២០០នាក់(ស្រី ៥៦នាក់)។ **៣០**-បើកវគ្គបណ្តុះបណ្តាល ស្តីពីការសម្ភាស និងកោសល្យវិច្ច័យបែបកុមារមេត្រី ដែលមានការសហការគាំទ្រពីអង្គការ APLE និងអង្គការអេ២១ នៅខេត្តសៀមរាប។ **៣១**-សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោង ការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអង្គការតំណាក់ទឹក និងអង្គការការីតាសស្វីស និងEU នៅសណ្ឋាគារពូលូវ៉ៃ រាជធានីភ្នំពេញ។

	៣២-កិច្ចប្រជុំពិភាក្សា ស្តីពីគម្រោងអភិវឌ្ឍន៍សមត្ថភាពភាសាបរទេស(ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ដើម្បីសួរសុខទុក្ខ ការអនុវត្តន៍គម្រោងនៅតាមសាលារៀន ក្នុងខេត្តកោះកុង ដោយមានកិច្ចសហការគាំទ្រដោយអង្គការផ្លែនអន្តរជាតិ(Plan) អង្គការសម្ព័ន្ធចាប់ដៃ អង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្ស (Cambodia Acts)។ **៣៣**-ដឹកនាំប្រតិភូចុះត្រួតពិនិត្យទីតាំង និងការរៀបចំសម្រាប់ប្រារព្ធពិធី សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមណ្ឌលទទួលពលករស្រុកកំរៀង ស្ថិតក្នុងភូមិអូរដោ ឃុំអូររាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ **៣៤**-ពិធីបិទកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី ផែនការយុទ្ធសាស្ត្រជាតិ សុខភាពជនទេសន្តប្រវេសន៍ រយៈពេល១០ឆ្នាំ (២០២១-២០៣៣) រៀបចំដោយក្រសួង សុខាភិបាល នៅសណ្ឋាគារអិលប៊ីអិន ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានអ្នកចូលរួម ៥០នាក់/ស្រី០៦នាក់។ **៣៤**-កិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាណត្តិឆ្នាំ ២០១៨-២០២៣ នៅខេត្តសៀមរាប ដែលមានការឧបត្ថម្ភគាំទ្រដោយអង្គការផ្លែនអន្តរជាតិ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធាន ក.ក.ជ។ **៣៥**-កម្មវិធី អបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ លើកទី១៥ របស់រដ្ឋបាលខេត្តសៀមរាប។ **៣៦**-ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២១ លើកទី១៥ ក្រោមប្រធានបទ "សូមកុំយកកូវីដ ១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស" របស់ គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង។ **៣៧**-បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅស្រុកអន្លង់វែង និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដោយមានកិច្ចសហការ ជាមួយអង្គការអាស៊ានអាក់ (ASEAN ACT) មានអ្នកចូលរួមសរុប ៦៣នាក់/ស្រី២៦នាក់។ ▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ (**១**)កិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារមានអាយុក្រោម២ឆ្នាំ និងកម្មវិធីឧបត្ថមសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្នុងឆ្នាំ២០២០ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ នៅសណ្ឋាគារភ្នំពេញ។ (**២**)ដឹកនាំកិច្ចប្រជុំសម្របសម្រួល ស្តីពី ១.ការវាយតម្លៃលើកម្រងសំណួរលក្ខណៈវិនិច្ឆ័យប្រចាំឆ្នាំ២០២០ របស់រាជធានី-ខេត្ត ២.កិច្ចប្រជុំរៀបចំឯកសារ បញ្ចប់អនុស្សរណៈយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមន៍មូលនិធិ **ឈាន ឆាយ** ដើម្បីមនុស្សធម៌ ៣.កិច្ចប្រជុំត្រៀម រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS អ្នកចូលរួមចំនួន**១០**នាក់ ស្រី**០១**នាក់។ (**៤**)សិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារ និងយុវជនក្នុងការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩ នៅសណ្ឋាគារសាន់រ៉ែភ្នំពេញ។ (**៥**)ដឹកនាំសម្របសម្រួលសកម្មភាពពិនិត្យ និងបូកសរុបឯកសារនៃកិច្ចសហប្រតិបត្តិការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយបណ្តាប្រទេសជាមិត្ត និងអង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន**០៥**នាក់ ស្រី**០១**នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។ (**៥**)សិក្ខាសាលា ស្តីពីការអភិវឌ្ឍន៍សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេសន៍ ឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ក្រោមអធិបតីភាព ឯកឧត្តម **ស៊ា ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារប៉ារ៉ាឌី ខេត្តសៀមរាប។ (**៦**)ពិធីបិទកិច្ចពិភាក្សាអំពីផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេសន៍ នៅសណ្ឋាគារ ផារ៉ាដាយអង្គរ ខេត្តសៀមរាប។ (**៧**)ដឹកនាំបន្តពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ WE WORLD ONLUS និងវាយតម្លៃកម្រងសំណួររាជធានី-ខេត្ត នៅសាលប្រជុំ គ.ជ.ប.ជ។ (**៨**)បិទអង្គសិក្ខាសាលា ស្តីពីការបំប៉នគ្រូឧទ្ទេសលើការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

	និងការប្រើប្រាស់សៀវភៅ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម។ (៩)កម្មវិធីប្រគល់-ទទួល សម្ភារៈបច្ចេកវិទ្យាអនឡាញសម្រាប់ប្រើប្រាស់ ក្នុងបន្ទប់ប្រជុំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបើកវគ្គបណ្តុះបណ្តាលអនឡាញ ទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុកិមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសោមាទេវីអង្គរ ខេត្តសៀមរាប។ (១០)កិច្ចប្រជុំកែសម្រួលសេចក្តីព្រាងចុងក្រោយ ស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ កម្ពុជា-ថៃ "Pending points from the bilateral meeting" ជាមួយតំណាងអង្គការ IOM ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅប្រជុំ គ.ជ.ប.ជ។ (១១)កិច្ចប្រជុំពិភាក្សាលើចំណុចសេសសល់ទ្វេភាគីកម្ពុជា-ថៃ អំពីសេចក្តីព្រាងចុងក្រោយ នៃកិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់រវាងកម្ពុជា-ថៃ SOP ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម **២៩**នាក់ ស្រី**០៦**នាក់។ (**១២**)ប្រជុំតាមវីដេអូរ (Conference Video) រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ស្តីពី "ស្តង់ដារនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **៣២**នាក់ ស្រី **០៨**នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ ។ (**១៣**) ដឹកនាំក្រុមការងារដើម្បីយកខ្លឹមសារ នីតិវិធីស្តង់ដារប្រតិបត្តិ SOP ស្តីពីនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស ប្រទេសថៃ ដើម្បីសុំការសម្របសម្រួលចង្អុលបង្ហាញ និងកែសម្រួលភាសាខ្មែរមួយចំនួនពី ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។ (**១៤**)កិច្ចប្រជុំរវាងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកជំទាវ **ឃូ សុភា** អភិបាលរងខេត្តសៀមរាប ប្រធានអង្គការ IOM ប្រចាំប្រទេសកម្ពុជា ប្រធានអង្គការយូនីសេហ្វ UNICEF អង្គការដៃគូអភិវឌ្ឍ មានតំណាងអង្គការយូអិនអេហ្វ កីអេ UNFPA ជាមួយនឹងមន្ត្រីអភិបាលស្រុក ឃុំ សង្កាត់ និងមេភូមិ បងប្អូនប្រជាពលរដ្ឋ និងបងប្អូនដែលទើបវិលត្រលប់ពីក្រៅប្រទេស គោលបំណង ដើម្បីតាមដានត្រួតពិនិត្យ និងសិក្សាស្វែងយល់ពីគម្រោងអនុវត្តរួមគ្នារវាងរាជរដ្ឋាភិបាល និងយូអិន នៅក្នុងរដ្ឋបាលស្រុក ឃុំ និងអង្គការដៃគូរអភិវឌ្ឍ នៅសាលាឃុំចាន់ស ស្រុកសូត្រនិគម ខេត្តសៀមរាប។ (**១៥**)ដឹកនាំសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈយោគយល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ We World Onlus នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ (**១៦**)ដឹកនាំពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ នៅ គ.ជ.ប.ជ។ (**១៧**)ដឹកនាំសកម្មភាពពិភាក្សាផ្តល់ចម្លើយតបជូនទៅអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រឹដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង(Global Initiative against Transnational Organized Crime)ទាំង១២សំណួរពាក់ព័ន្ធអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។ (**១៨**)ដឹកនាំកិច្ចពិភាក្សាបំពេញបន្ថែមចូលទៅក្នុងឯកសារពីរប្រភេទ របស់ក្រសួងមហាផ្ទៃ ដើម្បីឆ្លើយតបក្នុងអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ២០១៩ ជុំទី៣ និងឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន នៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅ

	សាលប្រជុំ គ.ជ.ប.ជ។ (**១៩**)ពិធីបើកវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធវីដេអូ **«ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍»** ក្រោមអធិបតីភាពឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ រៀបចំដោយក្រសួងមុខងារសាធារណៈ និងធនាគារពិភពលោក និងទទួលបានការឧបត្ថម្ភដោយ រដ្ឋាភិបាលអូស្ត្រាលី និងសហភាពអ៊ឺរ៉ុប នៅសាលប្រជុំ គ.ជ.ប.ជ។ (**២០**)កិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូ ស្តីពីការពង្រឹងដំណើរការ នៃការធ្វើមាតុភូមិនិវត្តន៍ សម្រាប់ជួយជនរងគ្រោះដោយសារការជួញដូរមនុស្ស សញ្ជាតិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **មុំ ប៊ុនថន** រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ (**២១**)បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី**«ភាពជាអ្នកដឹកនាំ និង នវានុវត្តន៍»** តាមរយៈប្រព័ន្ធវីដេអូ រៀបចំដោយ ក្រសួងមុខងារសាធារណៈ និងសាលាភូមិន្នរដ្ឋបាល ERA មានការសហការជាមួយ Word Bank និងឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងសហគមន៍អឺរ៉ុប។ កិច្ចប្រជុំនេះមានសមាសភាពចូលរួមសរុបចំនួន **១១២**នាក់។ (**២២**)សិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការ ស្តីពីប្រធានបទ **"ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសារជាថ្មី"** តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ (**២៣**)ពិធីប្រគល់ទទួលសម្ភារៈ ជាម៉ាសចំនួន ៥កេសធំ ពីតំណាងអង្គការកាតាស់កម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ (**២៤**)កិច្ចប្រជុំ ស្តីពីសកម្មភាពការងារជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **១៩**រូប ស្រី **០៣**រូប។ (**២៥**)រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីផ្ញើទៅអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **២២**រូប ស្រី **០៥**រូប។ (**២៦**)កិច្ចប្រជុំពិភាក្សាតាមអនឡាញរវាង ASEAN-ACT និង គ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងបង្កើនកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព និងផ្តោតសំខាន់ទៅលើគម្រោងរយៈពេលមួយឆ្នាំរបស់ ASEAN-ACT ក្នុងការជំរុញការអនុវត្តអនុសញ្ញា និងផែនការអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ នៅសាលប្រជុំ គ.ជ.ប.ជ។ **២៧**-ស្តីពីការពិនិត្យអំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆមាសទី១ បញ្ហាប្រឈម និងដំណោះស្រាយ និងលើកទិសដៅការងារ ឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។ **២៨**-ពិធីប្រគល់ និងទទួលសម្ភារៈសុខាភិបាល មានដូចជាអាកុលចំនួន១០កាន ម៉ាស់៦០០០ ក្រដាសវ៉ាម៥កេស ពីអង្គការ APLE ផ្តល់ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រាប់ប្រើប្រាស់ក្នុងកិច្ចការមនុស្សធម៌ ទៅដល់ព្រំដែនមូលដ្ឋាន និងសហគមន៍ទេសន្តរប្រវេសន៍ ដែលកំពុងជួបប្រឈមបញ្ហា ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **២៩**-កិច្ចពិភាក្សា ស្តីពីការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូអនឡាញ ក្រោមអធិបតីភាព លោកជំទាវ ជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ចំនួន០២លើក នៅសាលប្រជុំ គ.ជ.ប.ជ។ **៣០**-ពិនិត្យផែនការអភិវឌ្ឍន៍ វឌ្ឍនភាពនិងរបៀបរបបការងាររបស់អ្នកអនុវត្ត នៅក្នុងមណ្ឌលទទួលពលករកំរៀង ជាមួយអង្គការកាតាសស្វីស ចំនួន០២លើក ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៣១**-តាមប្រព័ន្ធអនឡាញ ស្តីពីការរៀបចំដំណើរការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ

	ប្រឆាំងការជួញដូរមនុស្សរយៈពេល៥ឆ្នាំ(២០១៩-២០២៣) និងសកម្មភាពអទិភាពក្នុងពាក់កណ្តាលអាណត្តិ ចំនួន**០៣**លើក ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានអ្នកចូលរួមប្រមាណ **១០០**នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។ **៣២**-ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**ជាប្រធាន គ.ជ.ប.ជ**។ **៣៣**-វឌ្ឍនភាព នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រៀមឆ្លើយតបនឹងស្ថានទូតអាមេរិក ដែលដឹកនាំដោយក្រសួងកិច្ចការនារី លោកជំទាវបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី តាមប្រព័ន្ធវីដេអូ ZOOM នៅសាលប្រជុំ គ.ជ.ប.ជ។ **៣៤**-បន្ត ស្តីពីការរៀបចំកម្មវិធីអន្តរសាសនា លើកទី៤ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៣៥**-តាមប្រព័ន្ធអនឡាញ ជាមួយអង្គការ A 21 និងសហការី ចំនួន០២លើក ស្តីពីផែនការរៀបចំកម្មវិធី សេរីភាពក្នុងការដើរ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងកិច្ចសហការ ក្នុងការជួយផ្តល់សេវាគាំទ្រជនរងគ្រោះដោយទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៣៦**-តាមប្រព័ន្ធអនឡាញ ជាមួយអង្គការចាប់ដៃ ស្តីពីការកំណត់អត្តសញ្ញាណប្រព័ន្ធទិន្នន័យ សេវាបញ្ជូនជនរងគ្រោះ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៣៧**-ជាមួយ លោក **ខាំ ស៊ីង្ហន** តំណាងអង្គការីតាសស្វីស រួមនិងសហការី ស្តីពី គម្រោងផែនការសកម្មភាពការងារ សម្រាប់មណ្ឌលទទួលពលករទេសន្តរប្រវេសន៍ដែលវិលត្រលប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៣៨**-តាមប្រព័ន្ធវីដេអូZOOM ស្តីពីការផ្សព្វផ្សាយ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស TIP តាមសាលារៀនក្រោមអធិបតីភាព លោកជំទាវ អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំ គ.ជ.ប.ជ។ **៣៩**-វិសាមញ្ញ តាមប្រព័ន្ធវីដេអូ Zoom ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ស្តីអំពីការត្រួតពិនិត្យរបាយការណ៍ និងឯកសារពាក់ព័ន្ធ ត្រៀមដាក់ជូន**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ** សម្រាប់កិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់គ.ជ.ប.ជ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាមួយក្រុមការងារអន្តរក្រសួង-ស្ថាប័នទាំង៦ នាពេលខាងមុខនេះ ក្នុងកិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទទួលបន្ទុកការងារជំនាញទាំង៦ ប្រធាន និងអនុប្រធាន នៃក្រុមជំនួយកិច្ចការទាំង៦ លោកប្រធានលេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៤០**-បន្តស្តីពីការត្រៀមរៀបចំកម្មវិធី"ទិវាជាតិអន្តរសាសនាលើកទី៤ ឆ្នាំ២០២១ "តាមប្រព័ន្ធវីដេអូអនឡាញ (ZOOM) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងភាគីពាក់ព័ន្ធនា ពេលនោះមានឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ស.អ.យ លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈដឹកនាំជាន់ខ្ពស់នៃឥស្លាមសាសនា គ្រិស្តបរិស័ទកាតូលិក ប៉ូតេស្តង់ និងនិកាយសាសនាទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា តំណាងព្រះសហគមន៍កាតលិកកម្ពុជា តំណាងអង្គការដៃគូអភិវឌ្ឍន៍ តំណាងស្ថានីយ៍ទូរទស្សន៍បាយ័ន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៥០**-កិច្ចប្រជុំស្តីពីកិច្ចពិភាក្សាបន្ត សម្រាប់ត្រៀមប្រជុំទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៏ លើឧសម្ព័ន្ធ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមអនឡាញ ដែលរៀបចំ

	ឡើងដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ **៥១**-បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យកែតម្រូវ និងរៀបចំយ្លោងយ្លា អនុស្សារណៈនៃការយោគយល់គ្នារវាងអង្គការមូលនិធិហាកាអន្តរជាតិ(HAGA) ជាមួយ គ.ជ.ប.ជ ស្តីពី "ការលើកកម្ពស់វិស័យសេដ្ឋកិច្ច សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាធ្ងន់ធ្ងរផ្អែកលើយ៉ែនឌ័រ និងពលករចំណាកស្រុក ដែលបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ **៥២**-សិក្ខាសាលា ស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនីតិសម្បទា និងជាប្រធាន ក.ជ.ក។ **៥៣**-កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ កិច្ចប្រជុំមានការអញ្ជើញចូលរួមសហការពីក្រុមការងារពាក់ព័ន្ធលើការងារទេសន្តរប្រវេសន៍ ក្រសួងសុខាភិបាល និងក្រុមការងារអង្គការអន្តរជាតិទេសន្តរប្រវេសន៍(International Organization for Migration) (IOM) នៅបន្ទប់ប្រជុំហាងកាហ្វេ(Coffee de Jenny)។ **៥៤**-កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយ ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំ សម្របសម្រួលដោយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ **៥៥**-ដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ជាមួយអង្គការក្តីសង្ឃឹម ដើម្បីយុត្តិធម៌នៅកម្ពុជា ស្តីពីតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៥៦**-កម្មវិធីដាំកូនឈើ និងបើកសិក្ខាសាលា ស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងច្បាប់នានាពាក់ព័ន្ធនឹងកិច្ចការពារកុមារ ចំណាកស្រុកដោយសុវត្តិភាព ការជួញដូរមនុស្ស និង វិធីសាស្ត្រសង្គ្រោះផ្លូវចិត្តបឋម នៅមណ្ឌលទទួលពលករកំរៀង។ **៥៧**-អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ធ្វើដំណើរទស្សនកិច្ចសិក្សាវាយតម្លៃស្ថានភាពរំហូរ និងតម្រូវការរបស់ពលករទេសន្តរប្រវេសន៍ ក្នុងដំណាក់កាលនៃវិបត្តិកូវីដ-១៩ នៅខេត្តព្រៃវែង និងស្វាយរៀង។ **៥៨**-កិច្ចពិភាក្សា ស្តីពីការសាងសង់មណ្ឌលសំចត និងទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះដទៃទៀត នៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាពឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ស.អ.យ និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ តាមប្រព័ន្ធ Zoom នៅសាលប្រជុំ គ.ជ.ប.ជ។ **៥៩**-កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលបឋម នៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ (២០១៩-២០២៣) តាមប្រព័ន្ធZOOM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **៦០**-សិក្ខាសាលាថ្នាក់ជាតិតាមប្រព័ន្ធអនឡាញ ស្តីពីការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវ ពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចសហការរៀបចំឡើងដោយក្រសួងយុត្តិធ៌ម និងកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) នៅសាលប្រជុំ គ.ជ.ប.ជ។ **៦១**-កិច្ចពិភាក្សានីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅខេត្តសៀមរាប។ **៦២**-ពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលការសង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្ត ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំឡើងដោយអង្គការ IOM នៅសណ្ឋាគារសាម៉ាទេវី ខេត្តសៀមរាប។

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ១-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ **៩៧**ច្បាប់ លិខិតចូល **៥៥**ច្បាប់។ **២**-លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ **៩០**ច្បាប់ លិខិតចូល **៦០**ច្បាប់។ **៣**-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ **៤**-ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី។ **៥**-បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៦**-បូកសរុបរបាយការណ៍ខែ ត្រីមាស ឆមាស ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **៧**-ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ **៨**-រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ **៩**-ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារឌីជីតាល ចំនួន **១០១**សកម្មភាព។ **១០**-អាប់ឡូតឯកសារចូលបណ្ណាល័យឌីជីតាល បានចំនួន **១៨០**ច្បាប់។ **១១**-សហការជាមួយក្រុមការងារ ចម្រុះទទួលពលករប៉ោយប៉ែត (ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពលករ បញ្ជូនត្រលប់ពីប្រទេសថៃ តាមប្រព័ន្ធបញ្ជូលទិន្នន័យស្វ័យប្រវត្តិ)។ **១២**-ចុះបំពេញបេសកកម្មនៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១៣**-បង្កើតផេកថ្មីក្នុងបណ្ណាល័យឌីជីតាលសម្រាប់រក្សាទុកឯកសារ និងរូបភាពសកម្មភាពរបស់ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **១៤**-ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ **១៥**-ធ្វើបច្ចុប្បន្នភាពការងារព័ត៌មាន ទៅក្នុងគេហទំព័រ និងតាមបណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ គ.ជ.ប.ជ ស្តីពីសកម្មភាពការងារថ្នាក់ដឹកនាំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១៦**-សហការ ស្រាវជ្រាវ ប្រមែប្រមូល ព័ត៌មានពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការពិនិត្យ វិភាគ សន្និដ្ឋាន វាយតម្លៃរាល់សកម្មភាព ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស។ **១៧**-សហការជាមួយក្រុមការងារចម្រុះទទួលពលករ (ប៉ោយប៉ែត) ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពលករ បញ្ជូនត្រឡប់ពីប្រទេសថៃ តាមប្រព័ន្ធបញ្ជូលទិន្នន័យស្វ័យប្រវត្តិ។ **១៨**-ថែទាំប្រព័ន្ធអ៊ិនធើណែត និងម៉ាស៊ីន Sever និងអនុវត្តការងារជាក់ស្តែងមួយចំនួន ដែលថ្នាក់ដឹកនាំដាក់បញ្ជាមក។ **១៩**-ចូលរួមពិភាក្សាការងារ ស្តីពីរបៀបរបបការងារ នៃការប្រព្រឹត្តិទៅមណ្ឌលទទួលពលករប្រចាំមណ្ឌលទទួលពលករស្រុកកំរៀង ខេត្តបាត់ដំបងជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **២០**-ធ្វើ Backdrop ពិធីចុះអនុស្សរណៈយោគយល់គ្នា រវាងគ.ជ.ប.ជ និងអង្គការវើរើលអនលូស(We World Onlus)។ **២១**-ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន **២៩២**ច្បាប់។

▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖

១.កិច្ចប្រជុំរៀបចំឯកសារបទបង្ហាញ សម្រាប់អង្គសិក្ខាសាលា ស្តីពីវគ្គបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិ លើការប្រើប្រាស់ សៀវភៅអប់រំ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន ក្រោមការដឹកនាំលោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅសាលប្រជុំក្រសួងអប់រំ។ **២**.ចូលរួមកិច្ចប្រជុំពិនិត្យ និងវាយតម្លៃការផ្តល់ពិន្ទុជូន គ.រ.ប.ជ/គ.ប.ខ.ជ ឆ្នាំ២០២០ នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម **២៤**នាក់ ស្រី **០៣**នាក់។ **៣**.បានចូលរួមពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការ សកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់(២០១៧-២០៣០) ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ **៤**.បានទទួលការចាត់តាំងដើម្បីដើម្បីចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពី

	ការបាត់ខ្លួនជនទេសន្តរប្រវេសន៍អំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ ក្រោមការសម្របសម្រួលពីតំណាងអង្គការដៃគូ មកពីប្រទេសពាក់ព័ន្ធមួយចំនួនផងដែរ។ **៥.** ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual) តាមប្រព័ន្ធវីដេអូអនឡាញ ហ្ស៊ូម ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ មានការរៀបចំសម្របសម្រួល ដោយអង្គការសង់ត្រាល់។ **៦.**សិក្ខាសាលាប្រចាំឆមាសរបស់សមាជិកអង្គការសម្ព័ន្ធចាប់ដៃទាំង៥៣អង្គការ តាមប្រព័ន្ធអនឡាញ ស្តីពីប្រធានបទ **"ចលនាឆ្ពោះទៅមុខចេញពីបរិបទកូវីដ១៩ការសម្របខ្លួនទៅនឹងបរិបទរស់នៅសារជាថ្មី"** តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសិក្ខាកាមសរុបចំនួន **១៦៣**នាក់។ **៧.**បន្តចូលរួមកិច្ចប្រជុំពិនិត្យទៅលើការអនុវត្តសកម្មភាពអទិភាព សម្រាប់អនុវត្តក្នុងត្រីមាសទី២ របាយការណ៍វឌ្ឍនភាពការងារ និងលើកទិសដៅបន្ត ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ **៨.** រៀបចំកសាងឯកសារស្នើសុំចុះហត្ថលេខាពី លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ស្តីពីកិច្ចសហការពីនិយ័តករទូរគមនាគមន៍កម្ពុជា ដើម្បីបញ្ជូនការស្នើសុំរត់អក្សរសារទៅតាមបណ្តាញទូរស័ព្ទចល័តទូទាំងប្រទេសក្នុងកម្មវិធីទិវាកុមារអន្តរជាតិ១មិថុនា ឆ្នាំ២០២១ ដែលមានខ្លឹមសារថា **"យើងប្តេជ្ញាចិត្តរួមគ្នាលុបបំបាត់អំពើហិង្សាលើកុមារ និងអំពើរំលោភបំពានគ្រប់រូបភាពលើកុមារ"**។ **៩.**បានបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ **១០**-បានបន្តផ្សព្វផ្សាយឯកសារ លិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមផេកផ្លូវការរបស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។ **១១**-បានបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី ខេត្ត និងក្រសួងស្ថាប័នពាក់ព័ន្ធ។ **១២**-បានបន្តផ្សព្វផ្សាយឯកសារលិខិតបទដ្ឋាននានាពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈផេកផ្លូវការរបស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក៏ដូចជាសកម្មភាពការងារនានារបស់ថ្នាក់ដឹកនាំ។ **១៣**-តាមដានព័ត៌មានជាប្រចាំតាមរយៈបណ្តាញសង្គមនានា និងតាមរយៈ Telegram របស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងារផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់ ភាពរងគ្រោះដល់ប្រជាពលរដ្ឋនៅតាមសហគមន៍។ **១៣**-និងដឹកនាំក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ចូលរួមកិច្ចប្រជុំពិភាក្សាតាមរយៈប្រព័ន្ធវីដេអូ ស្តីពី **"វឌ្ឍនភាពនៃការអនុវត្តគម្រោងសាកល្បង វគ្គបណ្តុះបណ្តាលថ្នាក់បឋមសិក្សា វៀតកម្ពុជា និងថៃ នៅខេត្តកោះកុង និងខេត្តត្រាត"** ចំនួន **០៣**លើក ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ **សឿ សុជាតា** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា។ - លោកឧត្តមសេនីយ៍ទោ **វ៉ែន សុភ័ក្ត្រវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមសិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោងការការពារ និងសិទ្ធិកុមារនៅកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានកិច្ចសហការរវាង គ.ជ.ប.ជ និងអង្គការតំណាក់ទឹក អង្គការកាវីតាសស្វីស និង EU នៅសណ្ឋាគារពូលូវ៉ៃ រាជធានីភ្នំពេញ។ ▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ:** ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកប្រធានក្រុមការងារបានចូលរួម៖ **១.**សិក្ខាសាលាពិគ្រោះយោល់ជាមួយកុមារ និងយុវជនលើសេចក្តីព្រាងផែនការ សកម្មភាពគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៩ ក្រោមអធិបតីភាព លោកជំទាវ **ខៀវ ឃូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសាន់រ៉ៃ ភ្នំពេញ។ **២.**កិច្ចប្រជុំ

	ឆ្លងសេចក្តីព្រាងផែនការសកម្មភាព ស្តីពីការរៀបចំសន្ទានុក្រម បច្ចេកទេសសព្ទ ក្នុងវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នៃក្រសួងមហាផ្ទៃ រយៈពេល២ឆ្នាំ (២០២១-២០២២) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា នៅសាលប្រជុំបណ្ឌិត្យសភានគរបាលជាតិកម្ពុជា ជីឥដ្ឋ។ **៣.**កិច្ចប្រជុំ ពិភាក្សាការងារ ជាមួយអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារជនរងគ្រោះ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៤.**និងសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះស្វែងយល់ពីបច្ចុប្បន្នភាព ក្នុងការបញ្ជូនពលករត្រឡប់មកវិញ និងការគ្រប់គ្រងពលករដែលតម្រូវឱ្យធ្វើចត្តាឡីស័ក ចំណុចប្រឈមផ្សេងៗ ដើម្បីរួមគ្នាដោះស្រាយ នៅតាមបណ្តាច្រក នៃខេត្តជាប់ព្រំដែន(ឧត្តរមានជ័យ បាត់ដំបង ប៉ៃលិន) ក្រោមការដឹកនាំរបស់ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ **៥.**អមដំណើរលោកជំទាវ អគ្គលេខាធិការ ចុះចែកសម្ភារៈមានដូចជា អាល់កុល ម៉ាស់ ជូនបុគ្គលិក សុខាភិបាល និងបានជួបសំណេះសំណាលជាមួយពលករ ចំនួន ៥០រូប ដែលទើបបានបញ្ជូនត្រឡប់មកពីប្រទេសថៃ នៅមណ្ឌលសំចត ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ **៦.**បានធ្វើការបូកសរុបរបាយការណ៍ខែឧសភា ឆ្នាំ២០២១ ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបញ្ជូនមកអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។ **៧-**ធ្វើការបូកសរុបរបាយការណ៍ប្រចាំឆមាសទី១ និងខែកក្កដា ឆ្នាំ២០២១ ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជូនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៨-**កិច្ចប្រជុំថ្នាក់បច្ចេកទេសកម្រិតជំនាញ ត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ លើការអនុវត្តន៍(SOP) ស្តីពីការពិនិត្យពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ **៩-**ប្រជុំត្រៀមរៀបចំមេរៀនបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងចុះបណ្តុះបណ្តាលតាមបណ្តាខេត្តគោលដៅ នៅសាលប្រជុំ គ.ជ.ប.ជ។ **១០-**សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីសេចក្តីព្រាងច្បាប់ដំបូងកិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអនុរក្រសួង និងអង្គការដៃគូពាក់ព័ន្ធ ក្រោមអធិបតីភាព លោកជំទាវ **ខៀវ ឃូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមប្រព័ន្ធអនឡាញ។ **១១-**សិក្ខាសាលា ស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុវជន និងយុវនីតិសម្បទា និងជាប្រធាន ក.ជ.ក។ **១២-**កិច្ចប្រជុំពិភាក្សា ដើម្បីត្រៀមប្រជុំទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើកឧបសម្ព័ន្ធ ស្តីពីការបញ្ជូន ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ។ **១៣-**វគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពការងារប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ក្រោមអធិបតីភាព លោកជំទាវ **ញ៉ែប សុភាព** អគ្គលេខាធិការ នៃអគ្គយកដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសាលាខេត្តកែប។ **១៤-**ធ្វើជាគ្រូឧទ្ទេស និងសម្របសម្រួលដល់សិក្ខាកាម មកពីស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ និងលោក **ណៃ ឈួន** ប្រធានអង្គការ អេស៊ានអាក់ ប្រចាំប្រទេសកម្ពុជា មានអ្នកចូលរួមចំនួន ៦៨នាក់។ **១៥-**កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ លើការអនុវត្ត SOPs ស្តីពីការពិនិត្យការពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធ ក្នុងការអនុវត្តនីតិវិធីប្រតិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាព ឯកឧត្តម

ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។ **១៦**-សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ ការគាំទ្រ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ ក្នុងចំណោមអ្នកអនុវត្ត ក្រោមអធិបតិភាព លោកជំទាវ **ហ៊ូ និរមិត្តា** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅសណ្ឋាគារពេជ្រដា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។ **១៧**-សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោងការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអង្គការតំណាក់ទឹក និងអង្គការការីតាសស្វីស និង EU នៅសណ្ឋាគារពូលូវ៉ៃ រាជធានីភ្នំពេញ។ **១៨**-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ស្តីពីការពិនិត្យការពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធ ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ(SOPS) រវាងកម្ពុជា-ថៃ តាមប្រព័ន្ធ ZOOM ក្រោមអធិបតីភាព ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប។ **១៩**-ជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។ **២០**-វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការសង្កេតអត្តសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្ត ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ក្រោមអធិបតីភាព លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ** លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង បានចូលរួម ៖

១.កិច្ចប្រជុំសម្របសម្រួលពិនិត្យ កែសម្រួល និងផ្តល់ធាតុចូលទៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៩-២០២១ នៅសាលប្រជុំ គ.ជ.ប.ជ។ **២**.កិច្ចប្រជុំពិភាក្សាជាមួយលោក **អៀង ប៊ុនថន** អ្នកប្រឹក្សាយោបល់ និងសម្របម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល ដោយទទួលបានការអនុញ្ញាត ចូលជំនួបពិភាក្សាជាមួយឯកឧត្តម **ហ៉ៃ ហ៊ុនឡេង** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ស្តីពីការរកដំណោះស្រាយ ឬក៏ជាគោលការណ៍ក្នុងការជួយជំរុញឱ្យពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញ ដើម្បីទទួលបានការងារសមស្របធ្វើការនៅក្នុងស្រុក នៅសាលប្រជុំទីភ្នាក់ងារជាតិ។ **៣**.កិច្ចប្រជុំក្រុមជំនួយកិច្ចការ ស្តីពីការរៀបចំតារាងបច្ចុប្បន្នភាព ព័ត៌មាន អនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងនានា តាមទម្រង់មួយ ដែលត្រូវបានផ្តល់ឱ្យក្រសួងមហាផ្ទៃ នៅសាលប្រជុំ គ.ជ.ប.ជ។ **៤**.កិច្ចប្រជុំលើកទី១ ស្តីពីក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន ក្រោមអធិបតីភាពឯកឧត្តម **ផាត សុផានិត** នៅក្រសួងមហាផ្ទៃ។ **៥**.និងតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយ ឯកឧត្តមអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមបើកសិក្ខាសាលាឆ្លុះបញ្ចាំង លទ្ធផលការងារប្រចាំឆ្នាំ នៃគម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាពគម្រោងប្រចាំឆ្នាំរបស់អង្គការយែរ សហការជាមួយ គ.ខ.ប.ជ ខេត្តកំពង់ស្ពឺ អ្នកចូលរួមសរុបចំនួន **៥០**នាក់ ស្រី **៣៥**នាក់។ **៦**.តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយ ឯកឧត្តមអគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំរបស់អង្គការយែរ ដែលបានសហការជាមួយ គ.ខ.ប.ជ ខេត្តព្រះសីហនុ ក្រោមការគាំទ្រពីមូលនិធិ UNWOMEN និងសហភាពអឺរ៉ុប អ្នកចូលរួមសរុបចំនួន**៤៥**នាក់ ស្រី**៣២**នាក់។ **៧**.កិច្ចប្រជុំ និងតំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពេញអង្គ "គណៈកម្មាធិការជាតិ

	គាំពារ និងអភិវឌ្ឍកុមារតូច អាណត្តិទី២ លើកទី១ ឆ្នាំ២០២១" ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច ដឹកនាំកិច្ចប្រជុំ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ **៨.**កិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ និងអនុសាសន៍ ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍ ដោយមានគាំទ្រពីគម្រោងអភិវឌ្ឍន៍របស់ USAID ក្នុងការអនុវត្តការងារនេះ។ **៩.**កិច្ចប្រជុំ ស្តីពីសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល ក្រោមការសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ **១០.**កិច្ចប្រជុំពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់(២០១៧-២០៣០) ក្រោមសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ **១១.**ជំនួបកិច្ចប្រជុំក្រុមអ្នកជំនាញក្នុងតំបន់ ស្តីពី"កិច្ចសហប្រតិបត្តិការជំរុញការធ្វើពាណិជ្ជកម្មរវាងវិស័យសាធារណៈ និងឯកជនដើម្បីប្រឆាំងការជួញដូរមនុស្សនៅអាស៊ីប៉ាស៊ីហ្វិក" ដែលមានការសម្របសម្រួលដោយអង្គការ UNODC។ **១២.**សិក្ខាសាលាពិគ្រោះយោបល់លើកទី២ តាមវីដេអូ ZOOM ស្តីពីដំណើរការជ្រើសពលករប្រកបដោយក្រមសិលធ៌ម(និម្មិត) ក្រោមការដឹកនាំសម្របសម្រួលរបស់លោកជំទាវឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ដែលរៀបចំសម្របសម្រួល ដោយអង្គការសង់ត្រាល់ នៅ គ.ជ.ប.ជ។ **១៣.**កិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធ Video Conference កែសម្រួលកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN-ACT ស្តីពីការឆ្លើយតបដោយយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មី សិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្ត្ររបស់ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងឯជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលរៀបចំ និងសម្របសម្រួលដោយអង្គការ ASEAN-ACT ។ **១៤.**សិក្ខាសាលាពិគ្រោះយោបល់ SOMTC លើផែនការការងារអាស៊ាន អូស្ត្រាលី ២០២០-២០២៣ ស្តីពី **«ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស»** ដែលមានសមាជិកអាស៊ានទាំង១០ និងតំណាង ASEAN-ACT Australia, ASEAN-ACT Cambodia, ASEAN-ACT Philippine, ASEAN-ACT Vietnam និង Asia Foundation សរុបអ្នកចូលរួមចំនួន **៩២**នាក់ ដឹកនាំសម្របសម្រួលដោយប្រធាន SOMTC Philippine។ **១៥.**កម្មវិធីប្រជុំអនឡាញលើកិច្ចពិភាក្សារវាង ASEAN-ACT និង គ.ជ.ប.ជ ស្តីពីការកំណត់បញ្ហាប្រឈមក្នុងកិច្ចការពារពលករ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្កើនកិច្ចសហការរវាង ស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមឱ្យកាន់តែមានប្រសិទ្ធភាព ការចូលរួមឆ្លើយតបទៅនឹងបញ្ហាប្រឈមតាមរយៈអង្គការដៃគូរបស់កម្មវិធី ASEAN-ACT។ ការពិភាក្សានេះ បានផ្តោតសំខាន់ទៅលើគម្រោងរយៈពេលមួយឆ្នាំ របស់ ASEAN-ACT ក្នុងការជំរុញការអនុវត្តអនុសញ្ញា និងផែនការអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គម្រោងនេះនឹងចាប់ ផ្តើមពីខែកក្កដា ឆ្នាំ២០២១នេះតទៅ។ **១៦-**ពិគ្រោះយោបល់ពាក់ព័ន្ធជាមួយប្រទេសដៃគូសន្ទនា(SOMTC+Dialogue Partner) លើវិស័យនានានៃការងារឧក្រិដ្ឋកម្មឆ្លងដែន ដែលជាផ្នែកមួយនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី២១ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រទេសព្រុយណេ គឺជាប្រធានដឹកនាំ។ ភាគីកម្ពុជា ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ

	នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា ដោយមានការចូលរួមពីអនុប្រធាន សមាជិក នៃក្រុមការងារ SOMTC ព្រមទាំងមន្ត្រីបង្គោលទទួលផែនការងារពាក់ព័ន្ធ នៃក្រុមការងារក្រសួងមហាផ្ទៃទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) ជាច្រើនរូប។ **១៧**-ពិភាក្សា ស្តីពីការរៀបចំកម្មវិធីអន្តរសាសនា លើកទី៤ ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១៨**-ក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ដែលបានរៀបចំឡើងដោយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**ជាប្រធាន គ.ជ.ប.ជ។ ១៩**-ពិភាក្សាពិនិត្យផែនការអភិវឌ្ឍន៍ វឌ្ឍនភាព និងរបៀបរបបការងាររបស់អ្នកអនុវត្ត នៅក្នុងមណ្ឌលទទួលពលករកំរៀង ជាមួយអង្គការការីតាសស្វីស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **២០**-តាមប្រព័ន្ធអនឡាញ ជាមួយអង្គការ A 21 និងសហការី ចំនួន០២លើក ស្តីពីផែនការរៀបចំកម្មវិធីសេរីភាពក្នុងការដើរ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងកិច្ចសហការ ក្នុងការជួយផ្តល់សេវាគាំទ្រជនរងគ្រោះដោយទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២១**-វគ្គបណ្តុះបណ្តាលរយៈពេល ៣ថ្ងៃតាមរយៈប្រព័ន្ធអនឡាញ ស្តីពីការយកចិត្តទុកដាក់ចំពោះយេនឌ័រ នៅពេលធ្វើការជាមួយស្ត្រីជាជនរងគ្រោះដោយសារការជួញដូរមនុស្ស ដែលត្រូវបានរៀបចំដោយ AICHR-ASEAN វគ្គបណ្តុះបណ្តាលនេះ បានផ្តោតសំខាន់លើការយកចិត្តទុកដាក់ចំពោះជនរងគ្រោះ និងសិទ្ធិរបស់ពួកគេ។ **២២**-សិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ស្តីពីការពិគ្រោះយោបល់ វាយតម្លៃសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព តាមប្រព័ន្ធអនឡាញ នៃកម្មវិធី ASEAN-ACT ដែលមានរយៈពេល២ថ្ងៃ គោលបំណងរួមនៃសិក្ខាសាលាបានផ្តោតសំខាន់ទៅលើការពិនិត្យមើលយុទ្ធសាស្ត្រ និងអភិក្រមនៃកម្មវិធី ASEAN-ACT ការពិភាក្សាសេចក្តីសង្ខេបនៃការវិភាគស្ថានភាពដៃគូ និងកិច្ចដំណើរការមុនពេលរៀបចំផែនការការងារ និងការពិភាក្សាជាមួយដៃគូវិស័យយុត្តិធម៌ និងសង្គមកិច្ច អាទិភាពអភិវឌ្ឍន៍យុទ្ធសាស្ត្រសំខាន់ៗ និងចំណុចខ្លាំងបច្ចុប្បន្ននៃស្ថាប័នទាំងនេះ ក្នុងការឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងការអនុវត្តអនុសញ្ញាអាស៊ាន ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ នៅកម្ពុជា។ **២៣**-ចុះធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ នៅមណ្ឌលចត្តាឡីស័ក ដែលធ្វើឡើងនៅក្នុងខេត្តចំនួន៥គឺ៖ ខេត្តតាកែវ ខេត្តកែប ខេត្តកំពតព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដើម្បីរៀបចំវគ្គ ស្តីពីក្រមសីលធម៌មន្ត្រីនៅតាមមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ។ **២៤**-ចុះធ្វើបទសម្ភាស សម្រាប់មណ្ឌលចត្តាឡីស័កក្នុងខេត្តចំនួន៧ មានដូចជា ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន សៀមរាប និងខេត្តកំពង់ធំ។ ក្នុងនោះក្រុមការងារបានចុះពិនិត្យមណ្ឌលចំនួន៥ គឺមណ្ឌលសំពៅលូន មណ្ឌលប៉ៃលិន មណ្ឌលកូបធំ មណ្ឌលកងរ៉ា និងមណ្ឌលសៀមរាប។ ដោយទទួលស្គាល់នូវតម្រូវការបន្ទាន់ថ្នាំពេទ្យមួយចំនួនសម្រាប់ផ្តត់ផ្គង់នៅមណ្ឌលចត្តាឡីស័កសំពៅលូន។ **២៥**-ចុះធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីបញ្ហាប្រឈម ដំណោះស្រាយ ក៏ដូចជាសំណូមពរ និងផ្តល់ឯកសារមួយចំនួន នៅមណ្ឌលចត្តាឡីស័ក សម្រាប់ខេត្តដែលមិនទាន់ទទួលបាន និងធ្វើការវាយតម្លៃការអនុវត្តនូវក្រមសីលធម៌របស់មន្ត្រីដែលបានចែងនៅក្នុងវគ្គផ្សព្វផ្សាយ សម្រាប់មណ្ឌលចត្តាឡីស័កនីមួយៗ នៅខេត្តព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ចាម។ **២៦**-សិក្ខាសាលា ស្តីពីការអនុវត្តគោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងរដ្ឋដែលជាសមាជិកអាស៊ាន រៀបចំដោយ ASEAN ACT តាមប្រព័ន្ធអនឡាញ។ **២៧**-សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោង ការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្ស ជាមួយនឹងអង្គការតំណក់ទឹក និងអង្គការការីតាសស្វីស និង EU នៅសណ្ឋាគារពូលូវ៉េ រាជធានីភ្នំពេញ។ **២៨**-សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការបង្ហាញបេកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអេយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។ **២៩**-ជាឧទ្ទេស និងបិទវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖

១.កិច្ចប្រជុំជាមួយគណៈកម្មាធិការប្រឹក្សាគ្រោង ស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាពបន្ត សម្រាប់អនុវត្តគម្រោង ILI-Triangle ឆ្នាំ២០២០ ដោយរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុធ្លី** រដ្ឋលេខាធិការក្រសួងការងារ នៅសណ្ឋាគារភ្នំពេញ។ **២.**សិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងប្រចាំឆ្នាំ គម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព និងធ្វើជាវាគ្មិន ក្រោមការដឹកនាំរបស់លោកជំទាវ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង នៅសាលាខេត្តកំពង់ស្ពឺ ក្រោមការឧបត្ថម្ភគាំទ្រដោយអង្គការឃែរអន្តរជាតិ ប្រចាំកម្ពុជា។ **៣.**បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ក្រោមការឧបត្ថមគាំទ្រមូលនីធិ UN-WOMEN អង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ CWCC នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។ **៤.**ពិនិត្យ និងកែតម្រូវខ្លឹមសារសេចក្តីព្រាង MOU រវាង គ.ជ.ប.ជ និងអង្គការវីវើលអនលូស (WE WORLD ONLUS) ក្រោមការដឹកនាំដោយ លោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ **៥.**ពិនិត្យ និងកែសម្រួលខ្លឹមសារ "សេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ" របស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៦.** ពិនិត្យពិភាក្សា និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជំណាក់កាលទី១ និងផ្តល់ធាតុចូលក្នុងផែនការសកម្មភាពជំណាក់កាលទី២ នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ (២០១៧-២០៣០) ក្រោមការសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៧.**ពិភាក្សាផ្តល់ចម្លើយតបពាក់ព័ន្ធអំពើជួញដូរមនុស្សទាំង១២សំណួរ របស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង (Global Initiative against Transnational Organized Crime) ដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅគ.ជ.ប.ជ។ **៨.**ពិនិត្យខ្លឹមសារពាក់ព័ន្ធអំពើជួញដូរមនុស្សដែលមាននៅក្នុងឯកសារពីរប្រភេទរបស់ក្រសួងមហាផ្ទៃបញ្ជូនមកដូចជា៖ ១-សេចក្តីសង្កេតសន្និដ្ឋាននៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) និង២-ឆ្លើយតបនូវអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ ២០១៩ ជុំទី៣ ក្នុងនាមលោកជំទាវជាអនុប្រធានក្រុមការងារទទួលបន្ទុកសិទ្ធិមនុស្ស ក្រសួងមហាផ្ទៃ ដើម្បីប្រមូលធាតុចូលឆ្លើយតបទៅវិញ។ **៩.**ពិនិត្យ ពិភាក្សា ផ្តល់ធាតុចូលបំពេញចម្លើយទៅក្នុងឯកសារទាំងពីរប្រភេទរបស់ក្រសួងមហាផ្ទៃ នូវចំណុចណាដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវឧត្តម សេនីយ៍ឯក អគ្គលេខាធិការ។

	១០.បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ ដើម្បីស្នើសុំជួបសម្ភាសន៍ជាមួយមន្ត្រីជំនាញ នាយកដ្ឋានទទួលបន្ទុកអធិការកិច្ចការងារ នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនាយកដ្ឋានកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធអនឡាញ។ ១១.បានបញ្ជូនលិខិតទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជជីវៈ ដើម្បីស្នើសុំចាត់អញ្ជើញ **ឯកឧត្តម ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ដើម្បីចូលរួមកិច្ចប្រជុំសម្រាប់ត្រៀមកិច្ចប្រជុំពិគ្រើយោបល់តុមូល ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រព្រត្តិទៅនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១១-បើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។ ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ ៖** - ឯកឧត្តម ឧត្តមសេនីយ៍ទោ **តែ សុថារ៉ែត** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួម៖ **១.**កិច្ចប្រជុំ ឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១ ជាមួយអន្តរក្រសួង ស្ថាប័ន ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃអគារ S ។ **២.**កិច្ចប្រជុំប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន(SOMTC) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **៣.**កិច្ចប្រជុំ ក្រុមការងារបច្ចេកកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT កម្ពុជានៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ **៤**-និងបានសហការជាមួយលោក ឧត្តមសេនីយ៍ទោ **ប៉ុណ្ណ ចន្ថា** ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ គ.ជ.ប.ជ បានចូលរួមកិច្ចប្រជុំ៖ **៥**-ពិនិត្យលើការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាស នីមួយៗ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី លោកជំទាវអគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ទីប្រឹក្សា គ.ជ.ប.ជ ប្រធានក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការ ដ្ឋានរដ្ឋបាលសរុប និងមន្ត្រីពាក់ព័ន្ធផងដែរ។ **៦**-អំពីសកម្មភាពការងារជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ **៧**-បានចូលរួមកិច្ចប្រជុំបន្តស្តីពីសកម្មភាពការងារជាអាទិភាពសំខាន់ៗប្រចាំត្រីមាសទី១ និងទិសដៅត្រីមាសទី២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៨**- ស្តីពីផែនការសកម្មភាព ការងារ ជាអាទិភាពសំខាន់ៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតី ភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៩**-តាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីការពិនិត្យអំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆមាសទី១ ឆ្នាំ២០២១ ដែលសម្រេចបានការប្រឈម ដំណោះស្រាយ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១០**-បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីការរៀបចំ ដំណើរការ វាយតម្លៃ ពាក់កណ្តាល អាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ ប្រឆាំងការជួញដូរមនុស្ស រយៈពេល ៥ឆ្នាំ(២០១៩-២០២៣) និងសកម្មភាពអាទិភាពក្នុងពាក់កណ្តាលអាណត្តិ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចំនួន០២ លើកនៅសាលប្រជុំ គ.ជ.ប.ជ។ **១១**-សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល

	៥ឆ្នាំ(២០១៩-២០២៣) កាងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។ **១២**-កិច្ចប្រជុំស្តីអំពីការត្រួតពិនិត្យរបាយការណ៍ និងឯកសារពាក់ព័ន្ធ ត្រៀមដាក់ជូន**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធាន គ.ជ.ប.ជ** សម្រាប់កិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ គ.ជ.ប.ជ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាមួយក្រុមការងារអន្តរក្រសួងស្ថាប័នទាំង៦។ **១៣**-កិច្ចប្រជុំក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង៦ ប្រចាំឆមាសទី១ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធវីដេអូអនឡាញ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**ជាប្រធាន គ.ជ.ប.ជ** នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួមប្រមាណ៥០នាក់ ។ **១៤**-កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយ ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំសម្របសម្រួលដោយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា មានអ្នកចូលរួមប្រមាណ ៣៨នាក់។ **១៥**-ពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅចុងឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានក្រុមការងារបច្ចេកទេសកម្មវិធី ASEAN ACT ជាមួយក្រុមការងារបច្ចេកទេសកម្មវិធី ASEAN ACT ជាច្រើនរូបទៀត តាមប្រព័ន្ធអនឡាញ។ **១៦**-សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។ - លោកឧត្តមសេនីយ៍ត្រី **ហែម បូរ៉ា** អនុប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានចូលរួមកិច្ចប្រជុំ ស្តីពី"ផែនការសកម្មភាពការងាររបស់ក្រុមជំនួយកិច្ចការទាំង៦ឆ្លើយតបទៅនឹងការធ្វើទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋ នៅសហគមន៍នៃស្រុកកំរៀង ខេត្តបាត់ដំបង" របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម រិះ** អគ្គលេខាធិការរង គ.ជ.ប.ជ និងឯកឧត្តម ឧត្តមសេនីយ៍ទោ **នី គឹមស្រេន** អគ្គលេខាធិការរង គ.ជ.ប.ជ ទទួលបន្ទុកថ្មីបានចូលរួម៖ **១.**ពិធីប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និង ជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំ "S"តូច ទីស្តីការក្រសួងមហាផ្ទៃ។ **២.**ជាតំណាង លោកជំទាវ ឧត្តមសេនីយ៍ឯកអគ្គលេខាធិការ គ.ជ.ប.ជ ប្រជុំក្រុមការងារបច្ចេកទេសកម្មវិធី អាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ស្តីពីវឌ្ឍនភាពដែលកម្មវិធីនេះ សម្រេចបានក្នុងឆ្នាំ ២០២០ និងសេចក្តីព្រាងផែនការការងារឆ្នាំ ២០២១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្យសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT កម្ពុជា នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ **៣.**ប្រជុំជាមួយតំណាងក្រុមការងារជំនាញអន្តរក្រសួងទាំង០៦ ដើម្បីពិភាក្សាពីចំណុចសេសសល់ ដែលមាននៅក្នុងសេចក្តីព្រាង "SOP" ទ្វេភាគី កម្ពុជា -ថៃចុងក្រោយ

ស្តីពី« កិច្ចសហប្រតិបត្តិពង្រឹងការអនុវត្តច្បាប់ រវាងកម្ពុជា-ថៃ ដោយផ្តោតសំខាន់ទៅលើឧត្តមប្រយោជន៍ និងសិទ្ធិមនុស្សពិតប្រាកដរបស់ពលករ និងពលរដ្ឋខ្មែរដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ» ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ **៤.**ពិនិត្យផ្ទៀងផ្ទាត់ខ្លឹមសារ និងឃ្លោងឃ្លាSOP ស្តីពីនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាង គ.ជ.ប.ជ និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សរបស់ប្រទេសថៃជាភាសាខ្មែរម្តងទៀត មុននឹងនាំយកទៅសុំការណែនាំចង្អុរបង្ហាញពី ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ តាមអនុសាសន៍ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ៥.**ពិនិត្យ កែសម្រួល និងផ្ទៀងផ្ទាត់ខ្លឹមសារ SOP រវាងភាសាខ្មែរ និងអង់គ្លេស តាមការចង្អុរបង្ហាញពី ឯកឧត្តម **ឡាំ ជា** មុននឹងដាក់ជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធាន គ.ជ.ប.ជ** ពិនិត្យ និងស្នើសុំ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ផ្តល់សិទ្ធិប្រទានជូន **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ចុះហត្ថលេខជំនួស។ **៦.**ប្រជុំពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ ជាមួយថ្នាក់ដឹកនាំអគ្គលេខាដ្ឋាន គ.ជ.ប.ជ ដើម្បីពិនិត្យ កែសម្រួលទិន្នន័យ និងខ្លឹមសារមួយចំនួនទៀត ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ។ **៧.**ចូលរួមពិនិត្យកម្រងសំណួរលក្ខណៈវិច្ច័យ នៃ សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.រ.ប.ជ/គ.ខ.ប.ជ ប្រចាំឆ្នាំ ២០២០ " និងបន្តចូលរួម រៀបចំសេចក្តីជូនដំណឹងទៅ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ស្តីពីការបញ្ចប់អនុស្សរណៈ យោគយល់រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង សមាគមមូលនិធិ ឈាន ឆាយ ដើម្បីមនុស្សធម៌ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តរប្រវេសន៍នៅប្រទេសថៃ ក្រោមការសម្របសម្រួលដោយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៨.**ក្នុងពិធីប្រកាសសមាសភាពក្រុមការងារក្រសួងមហាផ្ទៃទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) ដើម្បីបានស្គាល់គ្នា និងស្វែងយល់ពីការងារពាក់ព័ន្ធមួយចំនួនដែលត្រូវធ្វើទៅថ្ងៃមុខ ជាមួយអគ្គលេខាធិការរង គ.ជ.ប.ជ (ឈ្មោះក្នុងសេចក្តីសម្រេចលេខ៤៧៣៩ សសរ ចុះថ្ងៃទី១៦ ធ្នូ ២០២០) ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ា ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **៩.**ចូលរួមជាមួយ ឯកឧត្តម ឧត្តម.ត្រី **តែ សុថារ៉ែត** អគ្គលេខាធិការរង គ.ជ.ប.ជ ជាតំណាងលោកជំទាវឧត្តមសេនីយ៍ឯកអគ្គលេខាធិការ គ.ជ.ប.ជ នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស កម្មវិធីអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (ASEAN-ACT) ស្តីពី វឌ្ឍនភាពដែលកម្មវិធីនេះសម្រេចបានក្នុងឆ្នាំ ២០២០ និងសេចក្តីព្រាងផែនការការងារឆ្នាំ ២០២១ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ សាលី** អគ្គនាយកកិច្ចការអយ្យការនិងព្រហ្មទ័ណ្ឌក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារកម្មវិធី ASEAN-ACT និងលោកជំទាវ នាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ នៅសណ្ឋាគារ កាំបូឌីយ៉ាណា។ **១០.**កិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាងក្រុមការងារជំនាញអន្តរក្រសួងទាំង០៦ ដើម្បីពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ ២០២១ ដើម្បីបំពេញបន្ថែមនូវភាពខ្វះចន្លោះ មុននឹងធ្វើការជួបប្រជុំផ្សព្វផ្សាយជាផ្លូវការ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **១១.**កិច្ចប្រជុំពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងរបាយការណ៍ជាតិឆ្នាំ២០២០ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តឆ្នាំ២០២១ ជាមួយថ្នាក់ដឹកនាំអគ្គលេខាដ្ឋាន គ.ជ.ប.ជ និងក្រុមធ្វើរបាយការណ៍ ដើម្បីបំពេញទិន្នន័យនៅខ្វះចន្លោះដែលសាមីក្រសួងនីមួយៗស្នើសុំដាក់បញ្ចូលបន្ថែម ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំក្រសួងមហាផ្ទៃ។ **១២.**បានទំនាក់ទំនងទៅលោកស្រី **ស៊ុន សុខាលីដា** ប្រធាននាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោសនៃក្រសួងយុត្តិធម៌ ដើម្បីស្នើសុំបច្ចុប្បន្នភាព ស្តីពីវឌ្ឍនភាព ការ

	ចុះអនុសញ្ញា សន្ធិសញ្ញា បត្យាប័ន ដែលក្រសួងយុត្តិធម៌បានធ្វើជាមួយប្រទេសពាក់ព័ន្ធ ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាលទ្ធផលបានទទួលហើយ។ **១៣.**ចូលរួមប្រជុំដើម្បីពិភាក្សាពីលទ្ធផលការងារដែលអនុវត្តកន្លងមករយៈពេល ០៦ ឆ្នាំ(២០១៥-២០២១) តាមវិស័យរៀងខ្លួន ឆ្លើយតបសំណើអង្គការទេសន្តរប្រវេសន៍អន្តរជាតិ តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវ អគ្គលេខាធិការ។ **១៤.**ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ដើម្បីពិភាក្សាពីការជំរុញការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលក្នុងនោះគ.ជ.ប.ជ មានទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១ ចំនួន០៦ចំណុចធំ តម្រូវឱ្យក្រុមជំនួយកិច្ចការទាំង០៦ ពិនិត្យមើលផែនការធ្វើសកម្មភាពរបស់ខ្លួន ទាំង០៤ត្រីមាសនិងលើកទិសដៅការងារច្បាស់លាស់។ **១៥.**ចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ស្តីពីការជំរុញទិសដៅអនុវត្តការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ដែលបានដាក់ចេញ០២ចំណុចគឺ សកម្មភាពការងារអាទិភាពសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ស្របតាមការអនុវត្តទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និងរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តទិសដៅការងារអាទិភាពប្រចាំត្រីមាសនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។ **១៦.**បានស្រាវជ្រាវ និងដកស្រង់សកម្មភាព របស់ក្រុមការងារជំនាញកិច្ចការយុត្តិធម៌អន្តរក្រសួង ចេញពីផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៣-២០១៩) ដើម្បីបង្កើតតារាងផែនការអនុសកម្មភាពឆ្នាំ២០២១ របស់ ក្រុមជំនួយកិច្ចការយុត្តិធម៌។ **១៧.**បានចូលរួមប្រជុំដើម្បីពិភាក្សាការងារជាមួយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងឯកឧត្តម **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីត្រៀមផ្តល់ជាតុចូលក្នុងកិច្ចប្រជុំពិគ្រោះ តុមូលមួយ **«ស្តីពីគោលការណ៍មិនដាក់ទណ្ឌកម្មលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស»** ដែលគ្រោងនឹងធ្វើនៅពាក់កណ្តាលខែមិថុនាខាងមុខ ទៅតាមការស្នើសុំរបស់អង្គការកម្មវិធីអាស៊ានអូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ឱ្យខាងគ.ជ.ប.ជ ជួយសម្របសម្រួល។ **១៨.**បានទំនាក់ទំនងទៅប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងឧក្រឹដ្ឋកម្មឆ្លងដែន នៃក្រសួងយុត្តិធម៌ ទទួលបន្ទុកធ្វើរបាយការណ៍ផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស ដើម្បីស្នើសុំទិន្នន័យផ្តន្ទាទោសទាំង៣ដំណាក់កាល នៃនីតិវិធីតុលាការក្នុងត្រីមាសទី១ឆ្នាំ២០២១។ **១៩-**បានទំនាក់ទំនងទៅលោក **ឌី រីដា** ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងឧក្រឹដ្ឋកម្មឆ្លងដែន នៃក្រសួងយុត្តិធម៌ ដើម្បីស្នើសុំទិន្នន័យផ្តន្ទាទោសបទល្មើសជួញដូរមនុស្សទាំងបីដំណាក់កាល នៃនីតិវិធីតុលាការ ប្រចាំត្រីមាសទី២ ឬឆមាសទី១ ឆ្នាំ២០២១ ជាលទ្ធផលបានទទួលហើយ។ **២០-**ស្រាវជ្រាវ និងដកស្រង់យកតែការងារដែលពាក់ព័ន្ធដល់កុមារ ចេញពីទិន្នន័យផ្តន្ទាទោសបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ទាំងកុមាររងគ្រោះ និងកុមារប្រព្រឹត្តល្មើស) នៅដំណាក់កាលទី៣(ដំណាក់កាលចៅក្រមជំនុំជម្រះ) ទៅតាមផែនការសកម្មភាពជាតិរយៈពេល៥ឆ្នាំ ២០១៤-២០២១ យោងតាមមតិដឹកនាំរបស់ លោកជំទាវ អគ្គលេខាធិការ នៅក្នុងកិច្ចប្រជុំព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ដើម្បីឆ្លើយតបនឹងសំណើសុំផ្តល់ជាតុចូលបន្ថែមចំនួន៣របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីត្រៀមបញ្ចូលទៅក្នុងរបាយការណ៍រួមរួចរាល់ហើយ។ **២១-**ក្នុងសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញ ស្តីពីការវាយតម្លៃសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព រៀបចំឡើងដោយកម្មវិធី ASEAN-ACT ដោយផ្តោតសំខាន់ទៅលើការពិនិត្យមើលយុទ្ធសាស្ត្រ និងអភិក្រមនៃកម្មវិធី ASEAN-ACT ដើម្បីយល់ដឹងរួមអំពីចំណុចខ្លាំងនៃស្ថាប័នដៃគូ លើវិស័យយុត្តិធម៌ និងសង្គមកិច្ច ក្នុងការការពារសិទ្ធិ និងរកយុត្តិធម៌ជូនជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២២-**កិច្ចប្រជុំក្រុមគ្រូបង្គោលរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីបែងចែកមេរៀនស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដើម្បីត្រៀមបើកវគ្គបណ្តុះបណ្តាលនៅតាមបណ្តាខេត្តគោលដៅ ជាពិសេសក្នុងស្រុកចំនួន២ នៅខេត្តបាត់ដំបង។ **២៣-**ពិនិត្យពិភាក្សា ខ្លឹមសារមេរៀនកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំគ.ជ.ប.ជ។ **២៤-**ពិនិត្យពិភាក្សា និងផ្តល់យោបល់លើកម្រងសំណួរយល់ដឹងមុនវគ្គ

	និងក្រោយវគ្គ(Pre-test និង Post-test) សម្រាប់សិក្ខាកាម នៅខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២៥**-កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំ សម្របសម្រួលដោយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ **២៦**-ប្រជុំគ្រូបង្គោលស្តីពីលទ្ធផលនៃការវាយតម្លៃ និងផ្តល់ពិន្ទុដល់សិក្ខាកាម ក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងការកែលម្អចំណុចខ្វះខាតក្នុងវិធីសាស្ត្របង្រៀនរបស់គ្រូបង្គោលមួយចំនួន ដើម្បីត្រៀមអនុវត្តការបណ្តុះបណ្តាលនេះតាមបណ្តាខេត្តដទៃឱ្យបានល្អនៅពេលក្រោយ។ **២៧**-ប្រជុំគ្រូបង្គោល ដើម្បីទទួលលទ្ធផលនៃការប្រើប្រាស់ទម្រង់សម្ភាសន៍(ទម្រង់វែង និងទម្រង់ខ្លី) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់សិក្ខាកាមនៅក្នុងស្រុកចំនួន២នៃខេត្តសៀមរាប គឺស្រុកពួក និងស្រុកស្រីស្នំ ដែលបានទទួលការបណ្តុះបណ្តាលរួច។ **២៨**-កិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅចុងឆ្នាំ២០២១ ស្តីពីសកម្មភាពនៃកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់កម្មវិធីអាស៊ាន-អូស្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃ ក្រោមអធិបតីភាពឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធី ASEAN-ACT និង លោកជំទាវ នាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ។ **២៩**-ប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចប្រជុំត្រៀមពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលបឋមនៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ(២០១៩-២០២៣) ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។ **៣០**-សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។ **៣១**-ជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។
អន្តរក្រសួង ស្ថាប័ន និងអង្គការដៃគូ បានដឹកនាំសម្របសម្រួល ចំនួន ១១៩លើក អ្នកចូលរួមសរុបចំនួន ៥៨៩នាក់ (ស្រី ២៧០នាក់)	
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	**បានដឹកនាំសម្របសម្រួល ចំនួន ៤៩លើក** - ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញចុះពិនិត្យទីតាំងសំណង់អគារមជ្ឈមណ្ឌលស្តាយុវនីតិសម្បទា នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ - ក្រុមការងារអន្តរក្រសួង (ក្រុមការងាការពារជនរងគ្រោះ) ដែលដឹកនាំដោយ ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច បានចូលរួមអធិបតីភាពៈ ១-ចុះពិនិត្យការគ្រប់គ្រង ស្ថានភាពការទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលវិលត្រឡប់តាមច្រកព្រំដែនអន្តរជាតិ និងច្រកតំបន់នៃ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកោះកុង ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង បានរៀបចំកិច្ចប្រជុំ ត្រួតពិនិត្យ វាយតម្លៃ

	លទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្តរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។ ២-កិច្ចប្រជុំ ស្តីពីគ្រោងកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះ រវាងអង្គការរតនៈអន្តរជាតិ ជាមួយមជ្ឈមណ្ឌលប៉ោយប៉ែត នៅខេត្តបន្ទាយមានជ័យ។ ៣-សិក្ខាសាលាផ្សព្វផ្សាយអនុសាសន៍ នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារលើកទី១៣ នៅសណ្ឋាគារភ្នំពេញ។ ៤-សហការជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បើកវគ្គបណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើការគ្រប់គ្រងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។ ៥-កិច្ចប្រជុំជាមួយ គ.ជ.ប.ជ ចំនួន ០៣លើក៖ (១.កិច្ចប្រជុំឆ្លងបាយការណ៍ឆ្នាំ២០២០។ ២- កិច្ចប្រជុំត្រៀម និងកិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ ស្តីពី ស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់)។ ៦-កិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ដែលរៀបចំដោយក្រសួងយុត្តិធម៌ និងASEAN-ACT ចំនួន០១លើក។ ៧-ក្នុងវគ្គបណ្តុះបណ្តាលចំនួន០៣លើក៖ (១.គ្រូបង្គោលស្តីពី ផែនការសមាហរណកម្មជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ CWCC ។ ២.ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការតំណក់ទឹកប៉ោយប៉ែត(មណ្ឌលសំចតប៉ោយប៉ែត)។ ៧.ស្តីពីការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋានសម្រាប់នៅមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីគ្រប់គ្រងការវិលត្រឡប់មកវិញនៃជនទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប)។ ៩-កិច្ចប្រជុំពិគ្រោះយោបល់ លើកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដោយផ្តោតលើកិច្ចការពារកុមារ តាមវីដេអូរ Zoom។ - ក្រុមការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស បានចូលរួម៖ ១-ទទួលជនរងគ្រោះដែលមាតុភូមិនិវត្តន៍ពីក្រៅប្រទេសនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ០៦លើក និងនៅច្រកព្រំដែនអន្តរជាតិបាវិត ម៉ុកបាយ ០១លើក។ ២-ធ្វើសមាហរណកម្ម និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើចត្តាឡីស័ក ចំនួន១៤នាក់ ត្រឡប់ទៅសហគមន៍វិញ ដែលមានទីតាំងនៅ២៥រាជធានី ខេត្ត ដោយមានការចូលរួមគាំទ្រពីអង្គការដៃគូ។ ៣- កិច្ចប្រជុំត្រៀម និងពិភាក្សាស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជា ០២លើក តាមប្រព័ន្ធអនឡាញ នៅក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ។ ៤-កិច្ចប្រជុំពិភាក្សា ការរៀបចំកម្មវិធីអន្តរសាសនា លើកទី៤ តាមប្រព័ន្ធអនឡាញ។ ៥-កិច្ចប្រជុំពិភាក្សាឡើងវិញនូវកម្មវិធីប្រចាំប្រទេស ២០១៩-២០២៣ នៃកម្មវិធីកិច្ចការពារកុមារ ជាមួយអង្គការយូនីសេហ្ វ តាមប្រព័ន្ធអនឡាញ។ ៦-សិក្ខាសាលាតាមប្រព័ន្ធអនឡាញ ចំនួន០៣លើក ស្តីពីការអនុវត្តបែបកុមារមេត្រីដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមាររងគ្រោះនៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ក្នុងនីតិវិធីព្រហ្មទណ្ឌ និងការអនុវត្តសំណងរដ្ឋប្បវេណីតាមនីតិវិធីតុលាការ រៀបចំដោយក្រសួងយុត្តិធម៌ សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE)។ ៧-ធ្វើការសំភាសន៍ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងចំណោមពលករដែលអាជ្ញាធរថៃបានបញ្ជូនមក។ ៨-"Asian-Pacific Regional Review of Implementation of the Globle Copeat of Safe, Orderly and Reguler Migration" ដែលរៀបចំដោយគណៈកម្មការជាតិអេស្កាល់។ ៩-បានសហការជាមួយមជ្ឈមណ្ឌលចំចតប៉ោយប៉ែត ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខត្តេ-ក្រុង និងមន្ទីរសុខាភិបាល បានស្នើសុំមជ្ឈមណ្ឌលជាគោលដៅ ដើម្ពីទទួលពលករវិលត្រឡប់ពីប្រទេសថៃ ដែលតម្រូវឱ្យពលករទាំងអស់នោះសម្រាកបណ្តោះអាសន្ន ក្នុងការយកសំណាកពិនិត្យរកមេរោគកូវីដ បានចំនួន ១០លើក។ ១០-ឆ្លងរបាយការណ៍ ១០ខែ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១។ ១១-វគ្គបណ្តុះបណ្តាល ស្តីពី "ការលើកកម្ពស់កាអនុវត្តគោលនយោបាយជាតិ អំពីប្រព័ន្ធ

	កិច្ចការពារកុមារឆ្នាំ២០១៩-២០២៩ និងផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ"។ **១២**-បានសហការជាមួយអង្គការតេន:អ៊ីន ធើណេសិនណល ធ្វើការសម្ភាសបឋមជននិរទេស មាតុភូមិនិវត្តន៍ដែលមកពីប្រទេសថៃតាមរយៈទូរស័ព្ទដៃ ដើម្បីស្វែងរកមុខសញ្ញាជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ **១៣**-ជាមួយមណ្ឌលសំចតប៉ោយប៉ែត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ ដើម្បីទទួលពលរដ្ឋកម្ពុជាវិលត្រឡប់មកពីប្រទេសថៃ តាមច្រកអន្តរជាតិប៉ោយប៉ែត ច្រកអូរបីជាន់ ច្រកម៉ាឡៃ និងច្របឹងត្រកួន។ **១៤**-មន្ត្រីមណ្ឌលសំចតប៉ោយប៉ែតបានសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញច្រកទ្វារអន្តរជាតិប៉ោយប៉ែត ជាមួយខាងភាគីថៃ និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ក្នុងការសម្របសម្រួលបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សសញ្ជាតិខ្មែរ(កម្មករទូកនេសាទ) ដើម្បីសម្ភាសបន្តរឿងក្តីនៅក្រុងអារញ្ញប្រាថេត ខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ។ **១៥**-បានចូលរួមសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការទទួល និងផ្តល់ព័តមានជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រៅប្រទេស ដែលត្រូវធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ **១៦**-សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ ជួយសម្របសម្រួលក្នុងការសម្ភាសដើម្បីស្វែងរកជនសង្ស័យ និងអ្នកពាក់ព័ន្ធការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ដើម្បីជាឧត្តមប្រយោជន៍ដល់ជនរងគ្រោះ។ **១៧**-សហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពេទ្យកាល់ម៉ែត ក្នុងការសម្របសម្រួលជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យបានទទួលការពិនិត្យ និងព្យាបាលជម្ងឺដោយឥតគិតថ្លៃចំនួន ០២នាក់ (ស្រី ០១នាក់) ក្នុងករណីវះកាត់បេះដូង ០១នាក់ និងពិនិត្យ និងព្យាបាលបេះដូង ០១នាក់។ **១៨**-ធ្វើការសម្របសម្រួល និងបញ្ជូនជនរងគ្រោះ ០១នាក់ មកពីប្រទេសម៉ាឡេស៊ី(ករណីទូកនេសាទ) ដែលមានបញ្ហាវិបល្លាសស្មារតី ទៅមណ្ឌលថែទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី ដើម្បីទទួលសេវាស្នាក់នៅ និងព្យាបាលថែទាំ។ - លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលចំចតប៉ោយប៉ែត បានចូលរួមកិច្ចប្រជុំ៖ **១**-តាមប្រព័ន្ធអនឡាញ ស្តីពីវឌ្ឍនភាពការងាររបស់ក្រុមការងារការពារជនរងគ្រោះប្រចាំឆមាសទី១ ឆ្នាំ២០២១ ក្រោមអធិបតីភាព ឯកឧត្តម **មុំ ប៊ុនថន** រដ្ឋលេខាធិការក្រសួងស.អ.យ។ **២**-កិច្ចប្រជុំពិភាក្សាបន្តស្តីពី ការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ ដែលរៀបចំដោយ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៣**-ចាំឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀបចំដោយ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៤**-ធ្វើបទសម្ភាសជាមួយអង្គការ UNICEF THAILAND ស្តីពីប្រព័ន្ធការពារកុមារ តាមប្រព័ន្ធអនឡាញ។
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	**បានដឹកនាំសម្របសម្រួល ចំនួន ៣៣លើក អ្នកចូលរួមសរុបចំនួន ៧៧៦នាក់ (ស្រី ២០៩នាក់)** - បានចាត់មន្ត្រីជំនាញ**១០**រូប និងមន្ត្រីជាន់ខ្ពស់**១**រូប ចូលរួមកិច្ចប្រជុំ៖ **១.**ត្រៀមសម្រាប់ការប្រជុំទ្វេភាគីវាង គ.ជ.ប.ជ និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃរដ្ឋាភិបាលថៃ ស្តីពីស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការការអនុវត្តច្បាប់។ **២.**"Asia-pacific Regional Review of Implementation of Global Compact for Safe, Orderly and Regular Migration"។ **៣**-ពិភាក្សាការងារជាមួយគណៈប្រតិភូអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO)។ **៤**-ជាមួយគណៈកម្មការអាស៊ាន ស្តីពីការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារនិងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ លើកទី១៤ (14th ACMW) តាមរយៈប្រព័ន្ធវីដេអូ។ **៥**-ពិភាក្សាត្រៀមឆ្លើយតបនឹងកម្រងសំណួរនៃគម្រោងស្រាវជ្រាវ "Integrating Human Mobility into Cross-Border Trade Facilitation, and Border Management in the Greater Mekong Subregion" របស់អង្គការជាតិខាងការងារ (IOM)។ **៦**-គណៈកម្មការអាស៊ាន ស្តីពី "ការអនុវត្តសេក្តីថ្លែងការណ៍អាស៊ាន អំពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍លើកទី ១៤ (14 th ACMW)" តាមរយៈប្រព័ន្ធវីដេអូ

	ដែល រៀបចំដោយប្រទេសប្រុយណេ។ **៧**-ជនបង្គោលជំនាញបច្ចេកទេសលើកទី ៧ ស្តីពីស្ថិតិនៃទេសន្តរប្រវេសន៍ការងារអន្តរជាតិ ក្នុងតំបន់អាស៊ាន តាមរយៈប្រព័ន្ធវីដេអូ។ **៨**-នៃក្រុមការងារតាមវិស័យលើកទី ៨ ស្តីពីការជំរុញ ការអនុវត្តជ្រើសរើសពលករប្រកបដោយក្រមសីលធម៌ នៃយុទ្ធការកូឡុមបូ។ **៨**-ថ្នាក់បច្ចេកទេស (កម្រិតជំនាញ) ដើម្បីត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ លើការអនុវត្ត SOP នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ។ **៩**-ត្រៀមសម្រាប់ការប្រជុំទ្វេភាគីរវាង គ.ជ.ប.ជ និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃរដ្ឋាភិបាលថៃ ស្តីពីស្តង់ដានៃនិតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការការអនុវត្តច្បាប់ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១០**-ត្រួតពិនិត្យការអនុវត្តកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅថ្ងៃទី១០-១២ ខែមីនា ឆ្នាំ២០២១។ **១១**-កម្រិតជំនាញ ត្រៀមពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី "ផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់" នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ។ **១២**-អនុវត្តផែនការសកម្មភាព នៃផែនទីបង្ហាញផ្លូវអាស៊ាន ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ **១៣**-រៀបចំរបាយការណ៍ឆ្លើយតប ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារលេខ ១៣៨ ១៨២ និង២៩។ **១៤**-ពិនិត្យ និងពិភាក្សា ស្តីពី"វឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងដំណោះស្រាយជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា" នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។ **១៥**-ជាមួយតំណាងអង្គការ JICA អំពីសំណើសុំកិច្ចសហប្រតិបត្តិការ និងការគាំទ្រសម្រាប់ "ការស្វែងមតិប្រមូលពត៌មានសម្រាប់កិច្ចសហប្រតិបត្តិការអប់រំរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនក្នុងការីករាលដាលនៃជំងឺកូវីដ-១៩ កុមារក្រៅសាលា"។ **១៦**-ផ្ទាល់ជាមួយភាគីថៃស្តីពី "កិច្ចពិភាក្សាបន្ត អំពីការសាងសង់មជ្ឈមណ្ឌលសំចតនិងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ" ដែលប្រព្រឹត្តទៅនាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ **១៧**-ជាមួយក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ដើម្បីពិភាក្សាលើការអនុវត្ត SOPs ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ នៅខេត្តសៀមរាប។ **១៨**-ត្រួតពិនិត្យ និងឆ្លើយតបកម្រងសំណួររបស់ស្ថានទូតអាមេរិកចំនួន ៣លើក។ - បានចាត់មន្ត្រី ៣៥រូប ចូលរួមសិក្ខាសាលា ៖ **១**.ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីរបាយការណ៍ សូចនាករ អភិបាលកិច្ចទេសន្តរប្រវេសន៍ និងកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ **២**.ពិគ្រោះយោបល់ និងកែសម្រួលលើ "សៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស" លើកទី២។ **៣**.ស្តីពីការណែនាំសៀវភៅសិក្សា ភាសាជប៉ុនថ្មី អ៊ីរ៉ូដូរី សម្រាប់សិក្ខាកាមដែលមានបំណងចង់ទៅធ្វើការនៅប្រទេសជប៉ុន។ **៤**.ពិគ្រោះយោបល់ និងផ្តល់ធាតុចូលក្នុងកម្រងព័ត៌មានជាតិលើកទី២ ស្តីពីសុខភាព និងសុវត្ថិភាពការងារ នៃព្រះរាជាណាចក្រកម្ពុជា។ **៥**.ភាពជាដៃគូក្នុងតំបន់អាស៊ីតាមប្រព័ន្ធអនឡាញ ស្តីពីការបាត់ខ្លួនជនទេសន្តរប្រវេសន៍ អំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ។ **៦**.ស្តីពីក្របខណ្ឌត្រួតពិនិត្យតាមដានផែនទីបង្ហាញផ្លូវអាស៊ាន សម្រាប់ការលុបបំបាត់ ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ **៧**- ចាត់មន្ត្រី**៧**រូប ចូលរួមវេទិកាផ្សព្វផ្សាយ និងប្រកាសជាផ្លូវការនូវរបាយការណ៍សិក្ខាសាលា ស្តីពីផលិតភាពការងារនៅក្នុងអាស៊ានតាមប្រព័ន្ធអនឡាញ។ **៨**-បានចាត់មន្ត្រីចំនួន ៨រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់តុមូលស្តីពីគោលការណ៍តុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១។ **៩**-ស្តីពីការទំនាក់ទំនងដោយប្រើប្រាស់ព័ត៌មានអប់រំក្នុងកម្មវិធីសិទ្ធិពលកររនេសាទនៅអាស៊ីអាគ្នេយ៍។ **១០**-ភាពជាដៃគូក្នុងតំបន់អាស៊ី តាមប្រព័ន្ធអនឡាញ ស្តីពីការបាត់

	ខ្លួនជនទេសន្តរប្រវេសន៍ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ។ **១១**-ស្តីពីក្របខណ្ឌត្រួតពិនិត្យតាមដានផែនទីបង្ហាញផ្លូវអាស៊ាន សម្រាប់ការលុបបុះបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០២៥។ **១២**-ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីរបាយការណ៍ សូចនាករ អភិបាលកិច្ចទេសន្តរប្រវេសន៍ និងកតិកាសញ្ញាពិភពលោកសម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១។ - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានចូលរួមជាមួយក្រុមការងារលេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្របសម្រួលទទួលពីអាជ្ញាធរខេត្ត និងដឹកជញ្ជូនបងប្អូនពលករពីខេត្តបន្ទាយមានជ័យសរុបចំនួន ៣២៤នាក់ (ស្រី ១៣៨នាក់) ទៅមណ្ឌលចត្តាឡីស័កគរុកោសល្យខេត្តសៀមរាប។
ក្រសួងអប់រំ យុវជន និងកីឡា	**បានដឹកនាំសម្របសម្រួល ចំនួន ១៤លើក អ្នកចូលរួមសរុបចំនួន ២៨៩នាក់ (ស្រី ២០៩នាក់)** - បានចូលរួមកិច្ចប្រជុំ៖ (**១**)ឆ្លងរបាយការណ៍ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ នៅទីស្តីការក្រសួងមហាផ្ទៃ។ (**២**)ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។ (**៣**)ក្នុងកម្មវិធី ស្តីពី"យុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ដើម្បីសុវត្ថិភាពសង្គម" នៅវិទ្យាស្ថានជាតិអប់រំ។ (**៤**)ជួបសម្ភាសន៍ជាមួយក្រុមហ៊ុនរ៉ាពីតអេសៀ(Rapid Asia) ដែលជាក្រុមហ៊ុនឯករាជ្យផ្តល់សេវាកម្មប្រឹក្សាការងារ ធ្វើការវិភាគ ស្តីពីការការពារជនរងគ្រោះពីអំពើជួញដូរក្នុងតំបន់អាស៊ាន តាមរយៈការសម្របសម្រួលរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងអប់រំ មានអ្នកចូលរួមចំនួន ២២៦នាក់(ស្រី ១២៣នាក់)។ **៥**-ឆ្លងរបាយការណ៍ឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស** តាមប្រព័ន្ធអនឡាញ (Zoom)។ **៦**-និងពិភាក្សាលើរបាយការណ៍ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរយៈពេល ១០ខែ ឆ្នាំ២០២១ និងទិសដៅឆ្នាំ ២០២២ តាមប្រព័ន្ធអនឡាញ ។ **៧**-ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **៨**-ពិភាក្សាបន្ត ស្តីពីការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមចំនួន ៤៤នាក់(ស្រី ០៨នាក់)។ **៩**-ពិភាក្សាជាមួយ គ.ជ.ប.ជ និងអង្គការ សាម៉ារីតាន់ ស្តីពីការអប់រំផ្សព្វផ្សាយ TIP នៅតាមសាលារៀន ទាក់ទងនឹងការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន ១២នាក់។ **១០**-ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំ នៅព្រះរាជាណាចក្រកម្ពុជា។ - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការសកម្មភាពជាតិ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមចំនួន ២២១នាក់(ស្រី ៧០នាក់)។ - បានចងក្រង និងផ្សព្វផ្សាយសៀវភៅសិក្សា ស្តីពីការអប់រំ បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

	- បានសហការជាមួយ គណៈកម្មាធិការជាតិ គ.ជ.ប.ជ អង្គការសាម៉ារីតាន់ ហ្វឺស និងក្រសួង អ.យ.ក ពិនិត្យលើខ្លឹមសារមេរៀនចំណាកស្រុក ដើម្បីឱ្យស្របគ្នាជាមួយឯកសាររបស់ក្រសួង អ.យ.ក តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមចំនួន ២៤នាក់(ស្រី ០៨នាក់)។ និងបានត្រួតពិនិត្យវីដេអូមេរៀន ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលា(មធ្យមសិក្សាបឹងកុមិ)។
ក្រសួងកិច្ចការនារី	**បានដឹកនាំសម្របសម្រួល ចំនួន ០៣លើក** - បានចូលរួមពិនិត្យ និងកែសម្រួលលើសំណៅបកប្រែឯកសារជាភាសារអង់គ្លេស មកជាភាសារខ្មែរ របស់គណៈកម្មការអាស៊ាន(ACWC) ដើម្បីលើកកម្ពស់ការពារសិទ្ធិស្ត្រី និងកុមារ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់នៃគណៈកម្មការអាស៊ានទទួលបន្ទុក សម្រាប់ឆ្លើយតបតម្រូវការនៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ - បានចូលរួមបង្កើតគណៈកម្មាការប្រឹក្សាយោបល់ ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាសសម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៃកម្មវិធីក្នុងតំបន់អាស៊ាន ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ - ក្រុមការងាររបស់នាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី បានធ្វើការបញ្ជូន និងសម្របសម្រួលដល់គ្រួសាររបស់ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស នៅប្រទេសចិន ចំនួន ០៣ករណី ដោយបានដាក់ពាក្យប្តឹងនៅអគ្គស្នងការនគរបាលជាតិ និងសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបានផ្តល់ប្រឹក្សាដោយផ្ទាល់ដល់ស្ត្រីរងគ្រោះនៅចិនតាម Wechat , Telegram , Fecebook រហូតបានធ្វើមាតុភូមិនិវត្តន៍មកដល់ប្រទេសកម្ពុជា ដោយសិរីសួស្តីភាព ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផងដែរ។
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	**បានដឹកនាំសម្របសម្រួល ចំនួន ០៣លើក** - ចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ នៅទីស្តីការក្រសួងមហាផ្ទៃ។ - ចូលរួមប្រជុំកិច្ចប្រជុំពិនិត្យអំពីលទ្ធផលនៃការអនុវត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ ឆ្នាំ២០២១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ រយៈពេល០១ថ្ងៃ តាមប្រព័ន្ធអនឡាញ (Zoom)។ - ចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស** តាមប្រព័ន្ធអនឡាញ (Zoom)។
ក្រសួងទេសចរណ៍	- បានចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលាក្រោមប្រធានបទ "ការពារកុមារ ពីការរំលោភបំពានផ្លូវភេទ" និង "កិច្ចការពារកុមារក្នុងវិស័យទេសចរណ៍" ដែលរៀបចំឡើងដោយរដ្ឋាភិបាលអូស្ត្រាលី សហការជាមួយស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	ថ្នាក់ដឹកនាំ និងក្រុមការងារ បានចូលរួមកិច្ចប្រជុំពិភាក្សា ៖ **១**-ស្តីពីការរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ចំនួន ២លើក។ **២**-ឆ្លងរបាយការណ៍ឆមាសទី១ ឆ្នាំ២០២១ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

	ក្រសួងមហាផ្ទៃ និងជា**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស** តាមប្រព័ន្ធអនឡាញ (Zoom)។ **៣**-ពិគ្រោះយោបល់ថ្នាក់ជាតិ អំពីផែនការជាតិសម្រាប់អនុវត្តន៍កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ **៤**-ជាមួយអន្តរក្រសួង ស្ថាប័ន ស្តីពីការបង្ហាញរូបភាពមានលក្ខណៈអាសអាភាស និងស្រើបស្រាលតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ **៥**-ត្រៀមរាបចំទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២១។ **៦**-ឆ្លងរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០២១ លើលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ **៧**-ពិគ្រោះយោបល់ ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ។ **៨**-និងបានចូលរួមសិក្ខាសាលាពិនិត្យ ឡើងវិញពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ។
អគ្គនាយកដ្ឋានអន្តោប្រវេសន៍	**បានដឹកនាំសម្របសម្រួល ចំនួន ០៣លើក** - ចាត់បញ្ជូនមន្ត្រីនគរបាល ចំនួន**០៦**រូប ចូលរួមវគ្គបណ្តុះបណ្តាល(BCAMP)លើកទី២៥ អន្តោប្រវេសន៍ឆ្ពោះទៅកាន់ឆ្នាំ២០៣០។ - ប្រជុំកែសម្រួលខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីច្បាប់អន្តោប្រវេសន៍ថ្មី នៅសាលប្រជុំអគ្គនាយកដ្ឋានអន្តោប្រវេសន៍។ - ប្រជុំ ស្តីពីសកម្មភាព វិធានការអនុវត្តក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីតំបន់បិទខ្ទប់។
អង្គការរតនៈអ៊ីនធើណេសិនណល	**បានដឹកនាំសម្របសម្រួល ចំនួន ០៥លើក** បានចូលរួមកិច្ចប្រជុំ៖ **១**-តុមូល ស្តីពីប្រព័ន្ធតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ និងរៀបចំឡើងដោយអង្គការ ASEAN-ACT ។ **២**-ជាមួយក្រសួង ស.អ.យ ដែលមានផែនការរួមគ្នា នៃនិតិវិធីបទដ្ឋាន ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងកម្ពុជា ថៃ ឆ្នាំ២០១៩-២០២១។ **៣**-ជាមួយអង្គការដៃគូរ ដែលធ្វើការងារប្រឆាំងការជួញដូរមនុស្ស ដើម្បីបង្ហាញពីបញ្ហាប្រឈម និងទិសដៅអនុវត្តបន្តក្នុង ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលរៀបចំឡើងដោយ គ.ជ.ប.ជ និងអង្គការ USAID។ **៤**-ស្តីពីកិច្ចសហការរវាងមឈ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការពិភាក្សាអំពីករណី ដែលបានកំណត់អត្តសញ្ញាណ និងការរៀបចំផែនការសកម្មភាពចុះកំណត់អត្តសញ្ញាណជនរងគ្រោះជាផ្លូវការ។ **៥**-បានចូលរួមសិក្ខាសាលា ពិគ្រោះយោបល់ និងកែសម្រួលលើសៀវភៅគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ច ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សលើកទី២ ដែលមានអ្នកចូលពីបណ្តាក្រសួង និងអង្គការដៃគូពាក់ព័ន្ធ។
	លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៤៩៣លើក អ្នកចូលរួមសរុបចំនួន ៧០.២៧៣នាក់ (ស្រី ២៨.៧៣៧នាក់)
ខេត្តកណ្តាល	- ក្រុមការងារលេខាធិការដ្ឋានថ្នាក់ខេត្ត និងថ្នាក់ស្រុក បានចូលរួមកិច្ចប្រជុំពិភាក្សាតាមតេឡេក្រាម ជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) ០១លើក ស្តីពីការលើកកម្ពស់ការរាយការណ៍ករណីសង្ស័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។ - ឯកឧត្តម **គង់ សោភ័ណ** អភិបាលខេត្ត រួមជាមួយឯកឧត្តម លោកជំទាវ អភិបាលរងខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួន បានចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A) តាមប្រព័ន្ធអនឡាញ។

	- លោកជំទាវ **ហ៊ុន កុសនី** អនុប្រធានអចិន្ត្រៃយ៍ គ ខ ប ជខេត្ត បានចូលរួមក្នុង៖ **១**-កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ ០៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ ប ជ។ **២**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៣**-សិក្ខាសាលា ស្តីពីការអនុវត្តគាំពារ និងអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ **៤**-ពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ " ផែនការអនុវត្តគោលនយោបាយ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ " តាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព **លោកជំទាវកត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**។ **៥**-បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៦**-កិច្ចប្រជុំឆ្លងរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល ១០ខែ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៧**-ជាមួយក្រុមការងារថ្នាក់ខេត្ត ចុះសួរសុខទុក្ខ និងចែកអំណោយដល់ពលករចំណាកស្រុកមកពីក្រៅប្រទេស ចំនួន ១១លើក ស្មើនឹង ១១ក្រុង/ស្រុក ក្នុងខេត្តកណ្តាល មានចូលរួមសរុប ៥២៩នាក់ ស្រី ២៦៩នាក់។ - លោកស្រីឧត្តមសេនីយ៍ត្រី **ឈឹម វណ្ណនី** ស្នងការរងនគរបាលខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមក្នុងសិក្ខាសាលាស្តីពីការគាំទ្រដល់កុមារងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ និងប្រជុំស្តីពីការត្រួតពិនិត្យការងារសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតស្រាវជ្រាវផលនៃបទល្មើសសម្អាតប្រាក់ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនៃបទល្មើសជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ។ - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រទាំង៧(INSPIRE) ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហឹង្សាលើកុមារ តាមប្រព័ន្ធអនឡាញ ០១លើក អ្នកចូលរួម ៥០នាក់។
ខេត្តស្វាយរៀង	- លោកស្រីអនុប្រធានលេខាធិការដ្ឋាននៃ គ.ខ.ប.ជ បានចូលរួម៖ **១**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២**-សិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៣**-កិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៤**-ពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ " ផែនការអនុវត្តគោលនយោបាយ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ " តាមប្រព័ន្ធអនឡាញ (Zoom Meeting)ក្រោមអធិបតីភាព**លោកជំទាវកត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**។

	- លោកជំទាវ **ឯក សុវណ្ណាវ:** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ខេត្ត ដឹកនាំក្រុមការងារ បានសហការជាមួយ: **១**-លោក **យ៉ា កុប ស៊ីម** នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ប្រចាំប្រទេស ចុះសួរសុខទុក្ខពលករដែលបានវិលត្រឡប់មកពីប្រទេសថៃ ចំនួន **១៣២នាក់** ដែលកំពុងធ្វើចត្តាឡីស័ក នៅតាមបណ្តាឃុំទាំង១២ ក្នុងស្រុករមាសហែក ក្នុងម្នាក់ទទួលបានយីត ០១កញ្ចប់ (មី១កេស ត្រីខកំប៉ុង០១យូ និងម៉ាស០១ដុំ) ដែលជាជំនួយ របស់**អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ។ ២**-អង្គការសម្ព័ន្ធចាប់ដៃបានយកសម្ភារៈស្បៀង ជូនដល់នារីរងគ្រោះចំនួន **១៧នាក់** ដែលត្រូវចាញ់បោកមេខ្យល់ នាំឆ្លងដែនខុសច្បាប់ទៅកកាងារធ្វើនៅប្រទេសចិនដែលត្រូវបញ្ចប់ចត្តាឡីស័ក និងវិលត្រឡប់ទៅស្រុកកំណើតវិញ។ **៣**-អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJMចុះសួរសុខទុក្ខប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមទីសារធារណៈនៅប្រទេសវៀតណាម បានវិលត្រឡប់មកខេត្តស្វាយរៀងវិញ និងកំពុងធ្វើចត្តាឡីស័កនៅតាមនៅមណ្ឌលចត្តាឡីស័កនៅស្រុកកំពង់រោទ៍ និងស្រុកចន្ទ្រា។ **៤**-កិច្ចប្រជុំឆ្លងរបាយការណ៍ ១០ខែ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៥**-បានអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដើម្បីជួបប្រជុំប៉ាន់ប្រមាណតម្រូវការផ្នែកសុខភាពជនទេសន្តរប្រវេសន៍កម្ពុជាមកពីប្រទេសវៀតណាម និងការគ្រប់គ្រងរំហូរទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ក្នុងបរិបទការរាតត្បាតកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនចំនួន ០៤ គឺច្រកទ្វារព្រំដែនដូង ច្រកទ្វារព្រំដែនទ្វេភាគីបុសមន ច្រកទ្វាព្រំដែនអន្តរជាតិបាវិត និងច្រកទ្វារព្រំអន្តរជាតិព្រៃវល្លិ៍ ។ - ក្រុមការងារជំនាញ គ.ខ.ប.ជខេត្ត បានទទួលប្រជាពលរដ្ឋខ្មែរដែលជាជនរងគ្រោះចាញ់បោកមេខ្យល់ឆ្លងដែនទៅប្រទេសចិន និងប្រជាពលរដ្ឋដែលរស់នៅតាមទីសារធារណៈនៃប្រទេសប្រទេសវៀតណាមត្រូវបានអាជ្ញាធរវៀតណាមចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **០៧លើក** មានចំនួន **៣១គ្រសារ** មនុស្សរួម **៣៧នាក់** ស្រី**២២នាក់** មនុស្សចាស់ **២៣ នាក់** ស្រី **១៨ នាក់** កុមារ **១៣ នាក់** កុមារី **០៧នាក់** កុមារា**០៦ នាក់** (តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ,ច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍)។
ខេត្តកំពត	- ប្រធានលេខាធិការដ្ឋាននៃ គ.ខ.ប.ជ បានចូលរួម: **១**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២**-សិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៣**-កិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៤**-សិក្ខាសាលាផ្សព្វផ្សាយ គោលការណ៍ណែនាំ ស្តីពីការដោះស្រាយវិវាទ ទាក់ទងនឹងពលកររទេសន្តរប្រវេសន៍ និងគោលនយោបាយ ស្តីពីទេសន្តរប្រវេសន៍ នៅខេត្តសៀមរាប ។ **៥**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ **៦**-ពិធីសំណេះសំណាលសាកសួរសុខទុក្ខ ជាមួយពលកររទើបវិលត្រឡប់មកពី ក្រៅប្រទេស នៅឃុំស្វាយទងខាងត្បូង ស្រុកកំពង់ត្រាច ចំនួន ៥០នាក់ ស្រី ៣១នាក់ ព្រមទាំង បានឧបត្ថម្ភគ្រឿងឧបភោគបរិភោគម្នាក់ៗទទួលបានអង្ករ ១០គ.ក ត្រីខ ប្រេងឆា ទឹកត្រី ទឹកស៊ីអ៊ីវ ។ **៧**-វគ្គបណ្តុះបណ្តាល ការមិនបង្កការឈឺចាប់បន្ថែម និងការគ្រប់គ្រងករណី ពលករចំណាកស្រុក ។

	- មន្ត្រីនគរបាល ០៣រូប បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការគាំទ្រកុមារឆេងគ្រោះ និងបច្ចេកទេស ក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ តាមប្រព័ន្ធ Zoom។ - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន អធិការនគរបាលស្រុក និងប៉ុស្តិ៍រដ្ឋបាល បានទទួល និងសម្ភាសន៍ពលករទើបនឹងវិលត្រឡប់ពីប្រទេសថៃ ដែលកំពុងជាក់ឱ្យសម្រាកនៅមណ្ឌលធ្វើចត្តាឡីស័កនៅ ក្រុងកំពត ស្រុក (ជុំគិរី ឈូក និងដងទង់ កំពង់ត្រាច និងស្រុកបន្ទាយមាស) ដែលមានពលកររុបចំនួន ៦០នាក់ (ស្រី ១៦នាក់ កុមារា ០២នាក់ កុមារី ០១នាក់) ហើយជាលទ្ធផល ពួកគាត់មួយចំនួនចាញ់បោកមេខ្យល់ និងមួយចំនួនទៀតឆ្លងដែនខុសច្បាប់ដោយខ្លួនឯង ក្រោយពីសម្ភាសន៍ចប់ក្រុមការងារលេខាធិការដ្ឋាន បានអប់រំ ណែនាំដល់ពួកគាត់ កុំឲ្យចាញ់បោកមេខ្យល់ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានបន្តទៀត។
ខេត្តកែប	- បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - ឯកឧត្តម **សោម ពិសិដ្ឋ** អភិបាលនៃគណៈអភិបាលខេត្តកែប និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកែប បានអញ្ជើញសំណេះសំណាលអប់រំ ផ្សព្វផ្សាយដល់កម្មករ កម្មការនីនៅរោងចក្រផលិតគ្រឿងផ្សំស្បែកជើងចូវអ៊ីស៊ូ ចំនួន ០២លើក។ - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះផ្សព្វផ្សាយច្បាប់នានា និងអប់រំវិធានការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ដល់កម្មករ និយោជិត ចំនួន៦លើក មានអ្នកចូលរួមចំនួន ៤៦៤នាក់ ស្រី២៤៧នាក់។ - លោកជំទាវ **អ៊ុល កីរុណ** អភិបាលរងខេត្ត និងជាប្រធានលេខាធិការ គ.ជ.ប.ជ ខេត្តកែប បានដឹកនាំសមាសភាពអញ្ជើញៈ **១**-ចូលរួមកិច្ចប្រជុំ ស្តីពី ការពិនិត្យលទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆមាសទី១ (បញ្ហាប្រឈម ដំណោះស្រាយ) និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធ Zoom Meeting ចំនួន ០១លើក។ **២**-ដឹកនាំសមាសភាពអញ្ជើញចូលរួមចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ ០៥ឆ្នាំ(២០១៩-២០៣០) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធ Zoom Meeting ចំនួន ០១លើក ។ **៣**-ដឹកនាំសមាសភាពអញ្ជើញចូលរួមវគ្គផ្សព្វផ្សាយស្តីពី ក្រមសីលធម៌ របស់មន្ត្រី និងអ្នកពាក់ព័ន្ធក្នុងមណ្ឌលចត្តាឡីស័ក ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធ Zoom Meeting ចំនួន ០១លើក ។ ៤-បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។

	- នាយ នាយរង និងមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន ០៥នាក់/ស្រី០៤នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគាំទ្រកុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ តាមប្រព័ន្ធអនឡាញ។ - មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន ០៣នាក់/ស្រី០២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការឆ្លើយតប និងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណែត នៅស្នងការដ្ឋាននគរបាលខេតត្តកែប។
ខេត្តតាកែវ	- លោកស្រី ប្រធានលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានដឹកនាំលេខាធិការដ្ឋាន គ.ខ.ប.ជ ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ៖ ○ ក្នុងការអនុវត្តសេចក្តីសម្រេចរបស់រដ្ឋបាលខេត្ត ស្តីពីការអនុវត្តការវិលត្រឡប់របស់ពលករមកពីប្រទេសថៃ និងបំរាមគោចរណ៍ របស់រដ្ឋបាលខេត្ត។ ○ ស្តីពីការរៀបចំមណ្ឌលចត្តាលីស័ក ដោយមិនយកអាគារសាលារៀនធ្វើមណ្ឌលចត្តាឡីស័ក និងរកទីកន្លែងផ្សេងៗទៀត សម្រាប់ធ្វើចត្តាឡីស័ក។ ○ ជាមួយអនុគណៈកម្មការ ស្រាវជ្រាវកូវីដ១៩ ដែលរដ្ឋបាលខេត្ត ត្រូវទទួលពលករ ដែលត្រូវធ្វើចត្តាឡីស័ក។ ○ ស្តីពីការទទួលពលកររវិលត្រឡប់មកពីក្រៅប្រទេស(ថៃ) ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុន ម៉ានិត។** ○ ជាមួយគណៈបញ្ជាឯកភាពរដ្ឋបាលខេត្ត ស្តីពីការទទួលពលការវិលត្រឡប់ពីក្រៅប្រទេស(ថៃ) ត្រូវធ្វើចត្តាឡីស័កនៅតាម បណ្តាក្រុង ស្រុក។ - បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - លោកលោកស្រី **គា សុភ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជខេត្តចូលរួម៖ **១**-ទទួលប្រជាជន និងនិស្សិតមកពីក្រៅប្រទេស វិលត្រឡប់មកស្រុកកំណើតវិញ ក្នុងនោះប្រទេសវៀតណាម សរុបចំនួន ៣៣៩ នាក់ និស្សិត ១២ នាក់ ស្រី ៣ នាក់ ប្រជាពលរដ្ឋ ៣២៧នាក់ ស្រី ១៥៣ នាក់ និងប្រជាជនមកពីក្រៅប្រទេសថៃ វិលត្រឡប់មកស្រុកកំណើតវិញសរុបចំនួន ២.៤២៤ នាក់ ស្រី ១.០៦៥ នាក់ ។ **២**-បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ **៣**-វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ដើម្បីលប់បំបាត់បានការចំណាកស្រុកខុសច្បាប់។ **៤**-សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ របស់ក្រសួងកិច្ចការនារី ដើម្បីអនុវត្តនូវគោលការណ៍គ្រឹះសំខាន់របស់ CEDAW។ **៥**-ប្រជុំបូកសរុបការងារ គ.ក.ស.ក ប្រចាំឆ្នាំ របស់ក្រុងដូនកែវ ០១លើក។ **៦**-វគ្គបណ្តុះបណ្តាល ការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ។
ខេត្តសៀមរាប	- លោកជំទាវ **យូ សុភា** ប្រធានលេខាធិការដ្ឋានខេត្ត បានចូលរួម៖ **១**-សហការជាមួយរដ្ឋបាលខេត្តបន្ទាយមានជ័យ ស្តីពីការផ្ទេរពលករខេត្តសៀមរាប មកពីប្រទេសថៃ ពីមណ្ឌលចត្តាឡីស័កខេត្តបន្ទាយមានជ័យ មកធ្វើចត្តាឡីស័កបន្តនៅខេត្តសៀមរាប ០១លើក។ **២**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ

	មនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** ជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ **៣**-អមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អង្គការ UNFPA, UNICEF, WHO និងអង្គការ IOM ចុះពិនិត្យ និងវាយតម្លៃបញ្ចប់គម្រោងលើកកម្ពស់ជីវភាពពលករចំណាកស្រុកពីក្រៅប្រទេស ចំនួន០១លើក នៅស្រុកសូទ្រនិគម ស្រុកក្រឡាញ់ និងស្រុកពួក ខេត្តសៀមរាប។ **៤**-កិច្ចប្រជុំ សិក្ខាសាលា ជាមួយក្រសួងស្ថាប័ន និងអង្គការដៃគូ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **០៥**លើក។ **៥**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A) តាមប្រព័ន្ធអនឡាញ។ **៦**-សិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៧**-កិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៨**-កិច្ចប្រជុំត្រួតពិនិត្យ លើការរៀបចំផែនការសកម្មភាពសៅសង្គម ដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល បានចំនួន ០២លើក។ **៩**-សិក្ខាសាលាដាក់ឱ្យដំណើរការគម្រោង លើកកម្ពស់ និងពង្រឹងអំណាចសេដ្ឋកិច្ចទៅលើវិស័យសេដ្ឋកិច្ចគ្រួសារសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាធ្ងន់ធ្ងរផ្នែកយេនឌ័រនៅក្នុងចំណោមពលករចំណាកស្រុកដែលបានត្រឡប់មកកម្ពុជាវិញ តាមប្រព័ន្ធអនឡាញ បានចំនួន ០១លើក។ **១០**-កិច្ចប្រជុំពិនិត្យលើលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆមាសទី១ និងលើកទិសដៅការងារបន្តសម្រាប់ឆមាសទី២ ឆ្នាំ២០២១ ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចំនួន ០១លើក តាមប្រព័ន្ធបញ្ជូនរូបភាព និងសំលេង (កម្មវិធី ZOOM Meeting)។ **១១**-ពិធីផ្សព្វផ្សាយផែនការសកម្មភាព ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានចំនួន ០១លើក តាមប្រព័ន្ធបញ្ជូនរូបភាព និងសំលេង (កម្មវិធីZOOM Meeting)។ **១២**-កិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពី**ការបង្កើនសេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍** ក្រោមអធិបតីភាព លោកជំទាវ**ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅបន្ទប់ប្រជុំធំ រដ្ឋបាលសាលាខេត្ត បានចំនួន ០១លើក។ **១៣**-ដឹកនាំក្រុមការងារមានៈ ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរនានាដែលពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាស្រុក ការិយាល័យអប់រំ ក្រុមប្រឹក្សាឃុំ និងក្រុមយុវជន សហការជាមួយមន្ទីរធម្មការនិងសាសនា និងសមាគមនិកាយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានរៀបចំកម្មវិធី វេទិកាអន្តរសាសនា ក្រោមប្រធានបទ " សូមពិភពលោករួចផុតពីគ្រោះចង្រៃ នៃជំងឺរាតត្បាតសកលកូវីដ-១៩ និងអំពើជួញដូរមនុស្ស" និងបានចែកអំណោយជូនដល់ប្រជាពលរដ្ឋក្រីក្រ ចាស់ជរា ជនមានពិការភាព កុមារកំព្រា ស្ត្រីមេម៉ាយ ចំនួន ១០០គ្រួសារ ដែលកំពុងជួបការខ្វះខាតក្នុងជីវភាពនាពេលរីករាលដាលកូវីដ-១៩។ **១៤**-ធ្វើការទំនាក់ទំនង និងសម្របសម្រួលជាមួយស្ថានទូត កម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃ និងបានសហការជាមួយអាជ្ញាធរខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង មន្ទីរសុខាភិបាលខេត្តសៀមរាប រដ្ឋបាលស្រុកសូទ្រនិគម និងរដ្ឋបាលស្រុកអង្គរជុំ បានជួយអន្តរាគមន៍ បញ្ជូននិងទទួលសពពលករ ដែលបានស្លាប់ដោយ សារជំងឺគាំងបេះដូង នៅខេត្តរ៉ាក់យ៉ងប្រទេសថៃ បានចំនួន **០២លើក**។ - ស្នងការដ្ឋាននគរបាលខេត្តៈ មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តបែបកុមារមេត្រី ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមាររងគ្រោះ នៃអំពើរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តសំនងរដ្ឋប្បវេណីតាមនីតិវិធីតុលាការ ដែលរៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ តាមប្រព័ន្ធវីដេអូ។

	- រដ្ឋបាលស្រុកពួក៖ បានចូលរួមបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការលើកកម្ពស់និងការការពារសិទ្ធការងារសម្រាប់ពលករ ចំណាកស្រុកកម្ពុជាដែលមានជំនាញទាប នៅប្រទេសថៃ បានចំនួន ០១លើក ។
ខេត្តកំពង់ចាម	- ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំក្រុមការងារចូលរួម៖ **១**-សិក្ខាសាលា ស្តីពីគោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលកររទេសន្តរប្រវេសន៍ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារប្រទេសកម្ពុជា ២០១៩-២០២៣ នៅខេត្តសៀមរាប អ្នកចូលរួម ៤៥នាក់ ស្រី០៥នាក់។ **២**-វគ្គបណ្តុះបណ្តាលចំនួន០៣លើក ស្តីពីចំណេះដឹងក្នុងការគ្រប់គ្រងការងារទេសន្តរប្រវេសន៍ ការដោះស្រាយវិវាទ ព្រមទាំងការផ្តល់សេវាគាំទ្រដល់ ពលករ ដែលរៀបចំដោយអង្គការ OLO, Legal Aids និង LSCW អ្នកចូលរួមចំនួន**១១០**នាក់ ស្រី**៤៦**នាក់។ **៣**-វគ្គបណ្តុះបណ្តាលចំនួន**០១**លើក ស្តីពីការអនុវត្តការងារ និងបញ្ហាប្រឈម ការដោះស្រាយវិវាទ ព្រមទាំងការផ្តល់សេវាគាំទ្រដល់ពលករ ដែលរៀបចំដោយអង្គការ LSCW អ្នកចូលរួមចំនួន ១១នាក់ ស្រី ០៦នាក់។ **៤**-ក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៥**-ធ្វើបទបង្ហាញ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ០១លើក តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមប្រមាណ ១៥នាក់។ **៦**-ធ្វើបទបង្ហាញ ស្តីពី "លទ្ធផលការងារទេសន្តរប្រវេសន៍ និងការគៀគរធនធានជួយដល់ពលករ ព្រមទាំងការគ្រប់គ្រងករណី និងការផ្តល់សេវាដល់ជន រងគ្រោះ" ចំនួន០២លើក ដែលរៀបចំដោយអង្គការភ្នំស្រី និង LSCW។ **៧**-បានចូលរួមធ្វើបទបង្ហាញ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាពក្នុងកិច្ចប្រជុំ និងវេទិកាសហគមន៍ ០២លើក នៅស្រុកចំការលើ និងស្រុកស្ទឹងត្រង់ មានអ្នកចូលរួមប្រមាណ ១០៤នាក់។ **៨**-បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ - មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានចូលរួមសិក្ខាសាលា ចំនួន០៣វគ្គ លើប្រធានបទ ស្តីពី៖ ការប្រើប្រាស់សៀវភៅអប់រំការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សនិង លំនាំការបង្រៀនដែលរៀបចំតាមប្រព័ន្ធអនឡាញ ដែលមានសមាសភាពចូលរួម ក្រសួងអយក មន្ទីរអយក លោកគ្រូ អ្នកគ្រូ ផ្នែកបឋមសិក្សា និងផ្នែកមធ្យមសិក្សា ដែលមានអ្នកចូលរួមចំនួនសរុប ៥៣ ស្រី ៣១នាក់ ។ - មន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមសិក្ខាសាលា លើប្រធានបទស្តីពី ៖ ១-ការជួញដូរមនុស្ស ការងារដោយបង្ខំ និង ទាសភាព ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលរៀបចំដោយ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ នៃប្រទេសកូរ៉េខាងត្បូង។ ២-គោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលកររទេសន្តរប្រវេសន៍ និង គោលនយោបាយទេសន្តរប្រវេសន៍ ការងារប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ មានអ្នកចូលរួមចំនួន ៤៥នាក់ស្រី០៥នាក់។ ៣-សិទ្ធិពលកររនេសាទនៅអាស៊ីអាគ្នេយ៍ ចំនួន ០១ លើក ដែលរៀបចំដោយអង្គការ ILO ។ ៤-ពលកររទេសន្តរប្រវេសន៍ ចំនួន ០១ លើក តាមប្រព័ន្ធ ZOOM MEETING ដែលមានអ្នកចូលរួមចំនួន ៦១នាក់ - គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែ ចំនួន០១លើក អ្នកចូលរួមចំនួន ៣១នាក់ ស្រី២២នាក់។
ខេត្តត្បូងឃ្មុំ	- លោកជំទាវ **នី ចាន់ធីតា** បានចូលរួម ៖ **១**-សិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

	តាមប្រព័ន្ធអនឡាញ។ **២**-កិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី ២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ - មន្ត្រីជំនាញនៃមន្ទីរ ស.អ.យ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះរយៈពេលពីរថ្ងៃ ដែលរៀបចំឡើងដោយអង្គការសម្ព័ន្ធចាប់ដៃ ដោយមានគ្រូឧទ្ទេសមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងមានការសមាសភាពចូលរួមសរុបចំនួន ៣៥ នាក់(ស្រី៥នាក់)។ - លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយរដ្ឋបាលខេត្តធ្វើការរៀបចំពិធីប្រកាសសមាសភាពគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)ដែលមានអ្នកចូលរួមសរុបចំនួន ៤២នាក់ ។
ខេត្តក្រចេះ	- **មន្ទីរអប់រំ យុវជន និងកីឡាខេត្តៈ ១**.បានចុះផ្សព្វផ្សាយពីរបៀបធ្វើទិវាទប់ស្កាត់ការជួញដូរមនុស្សនៅស្រុកចិត្របុរី តាមសាលាបឋមសិក្សា១០៥ និងបឋមសិក្សាស្រះដែលមានលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចូលរួមសរុបចំនួន ២៧នាក់ ស្រី១៦នាក់។ **២**.មន្ទីរបានរៀបចំឲ្យមានគណៈកម្មការទប់ស្កាត់ការជួញដូរមនុស្ស ពីថ្នាក់មន្ទីរអប់រំរហូតដល់ថ្នាក់ស្រុក និងសាលារៀន។ - បានចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A) តាមប្រព័ន្ធអនឡាញ។ - បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - លោកស្រី **ខាំ សុភាព** អភិបាលរងខេត្ត និងជាប្រធានលេខាធិការ គ.ខ.ប.ជ បានចូលរួមៈ **១**-ជួបសំណេះសំណាលជាមួយ អង្គការសម្ព័ន្ធចាប់ដៃ ដើម្បីធ្វើបច្ចុប្បន្នភាព សេវាកម្មរបស់អង្គការសម្ព័ន្ធចាប់ដៃ ស្នើសុំកិច្ចសហការប្រតិបត្តិការក្នុងការបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងខេត្តក្រចេះ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការបណ្តុះបណ្តាលដល់មន្ត្រីកិច្ចការនារី មន្ត្រីសង្គមកិច្ច មេឃុំ/សង្កាត់ មេភូមិ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចគាំពារកុមារ និងការជួញដូរមនុស្ស នៅសាលាប្រជុំសាលាខេត្ត។ **២**-កិច្ចប្រជុំពិនិត្យអំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆមាសទី១ ឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តការងារឆមាសទី២ ឆ្នាំ២០២១ (តាមប្រព័ន្ធOnline)

	ក្រោមអធិបតីភាពលោកជំទាវ**ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។ **៣**-បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។
ខេត្តកំពង់ឆ្នាំង	- មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួមប្រជុំផ្សព្វផ្សាយប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ របាយការណ៍ស្តីពី ការអនុវត្តផែនការសកម្មភាពធ្វើឲ្យប្រសើរឡើងនូវការថែទាំ និងការសមាហរណកម្មកុមារ ក្រោមអធិបតីភាព ឯកឧត្តម **នឹម ចូត** រដ្ឋលេខាធិការ ក្រសួងស.អ.យ មានអ្នកចូលរួម២១៥នាក់ (ស្រី ៩៧នាក់) តាមប្រព័ន្ធ ZOOM។ - លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំ តាមប្រព័ន្ធវីដេអូ ចំនួន ០៥លើក អ្នកចូលរួមចំនួន១៣៨នាក់ ស្រី៦៥នាក់ ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ - បានចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A) តាមប្រព័ន្ធអនឡាញ។ - បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។
ខេត្តកពំង់ធំ	លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួម៖ **១**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A) តាមប្រព័ន្ធអនឡាញ។ **២**-ទទួលពលករវិលត្រឡប់ពីប្រទេសថៃ ០១លើក។ **៣**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ **៥**-ផ្តល់បទសម្ភាសន៍ដល់ក្រុមការងាររបស់ក្រុមហ៊ុន Research and Communication group (RCG) ដើម្បីសិក្សាស្វែងយល់ពីបទពិសោធន៍នៃដំណើររឿងក្តី និងការងារប្រយុទ្ធប្រឆាំងលើបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន ដែលសមាសភាពត្រូវចូលរួម សម្ភាសន៍មាន ០៦រូប ស្រី០៣ រូប។ **៦**-សួរសុខទុក្ខពលករចំណាក ស្រុកដែលបានវិលត្រលប់មកពីធ្វើការនៅប្រទេសថៃ និងស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនៅក្រុងស្រុកទាំង៩ ដែលមានមនុស្សចំនួន ៥២នាក់ និងបានធ្វើការផ្សព្វផ្សាយអំពីផលវិបាកនៃការចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស។ **៧**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សប្រចាំរយៈពេល ១០ ខែ ឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខា ធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធ ZOOM។

	- បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - បានចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - ឯកឧត្តមអភិបាលខេត្ត បានដឹកនាំក្រុមការងារ គ.ខ.ប.ជ ខេត្ត ចុះសួរសុខទុក្ខពលករវិលត្រឡប់ពីប្រទេសថៃ ដែលត្រូវដាក់ក្នុងមណ្ឌលចត្តាឡីស័កតាមបណ្តាក្រុង ស្រុកទាំង៩ ក្នុងខេត្ត ចំនួន០២លើក និងបានចែកសម្ភារប្រើប្រាស់ ថវិកាមួយចំនួនផងដែរ។ - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ។ - បានចូលរួមកិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យការងារប្រឆាំងការសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើប អង្កេតស្រាវជ្រាវផលនៃបទល្មើសសម្អាតប្រាក់ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនៃបទល្មើសជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស តាមប្រព័ន្ធ Zoom ។
ខេត្តព្រៃវែង	- លោកជំទាវ **លៀង ស្រីម៉ុល** អភិបាលរង និងជាប្រធានលេខាធិកា គ.ខ.ប.ជខេត្ត បានដឹកនាំលេខាធិការ គ.ខ.ប.ជខេត្ត ចូលរួម ៖ **១**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២**-ពិធីសម្ភោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ(A)។ **៣**-ក្នុងសិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៤**-កិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **៥**-ប្រជុំពិភាក្សាការងារជាមួយអង្គការផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីក្រុមការងារទាំង៦ និងតំណាងអង្គការ តាមរយៈប្រព័ន្ធវីដេអូ។ **៦**-ប្រជុំពិភាក្សាការងារជាមួយអង្គការផ្លូវច្បាប់ដល់កុមារ និងស្ត្រី ស្តីពីការជំរុញឱ្យទទួលបានភាពយុត្តិធម៌ និងសេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីក្រុមការងារទាំង៦ និងតំណាងអង្គការ តាមរយៈប្រព័ន្ធវីដេអូ។ **៧**-ជាកិត្តិយសក្នុងពិធីដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការ អនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**តាមប្រព័ន្ធអនឡាញ ZOOM។ **៨**-កិច្ចប្រជុំឆ្លងរបាយការណ៍ ១០ខែ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

	តាមប្រព័ន្ធអនឡាញ។ **៩**-រៀបចំគម្រោងបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការចំណាកស្រុកដោយប្រជុំយ ប្រថានចំនួន ០១លើក រៀបចំដោយក្រសួងកិច្ចការនារី នៅសាលាខេត្តព្រៃវែង មានអ្នកចូលរួម ៤២នាក់/ស្រី៣២នាក់។ - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការស៊ើបអង្កេតបទល្មើសជួញដូរ និងអាជីវកម្មផ្លូវភេទ រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការសម្ព័ន្ធចាប់ដៃ ០១លើក តាមប្រព័ន្ធអនឡាញ អ្នកចូលរួម ០៦នាក់/ស្រី០២នាក់។ - ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមកិច្ចប្រជុំ ស្តីពីបច្ចុប្បន្នភាពនៃការគ្រប់គ្រងជំងឺកូវីដ១៩ ជាពិសេសមេរោគបំលែងថ្មីប្រភេទដែលតា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** តាមរយៈប្រព័ន្ធវីដេអូ។
ខេត្តកោះកុង	- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានចូលរួមកិច្ចប្រជុំ៖ **១**-ឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០ ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **២**-ពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - ស្នងការដ្ឋានទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស បានចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលប្រជុំអគារ (A) តាមប្រព័ន្ធអនឡាញ។ - លោក **ស្រេង ហុង** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន បានដឹកនាំក្រុមការងារលេខាធិការដ្ឋានខេត្ត ចូលរួម៖ **១**-សិក្ខាសាលាពិគ្រោះយោបល់ពាក់កណ្តាលអាណតិនៃផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងជួញដូរមនុស្សតាមប្រព័ន្ធ (ZOOM) ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ **២**-អញ្ជើញទទួលស្វាគមន៍លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងប្រតិភូក្រសួងសុខាភិបាល ក្នុងដំណើរចុះមកស្វែងយល់ក្នុងការដាក់ចេញគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ នៅក្នុងខេត្តកោះកុង។ **៣**-អញ្ជើញអមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខា ធិការក្រសួងមហាផ្ទៃ ក្នុងកិច្ចប្រជុំសំណេះសំណាល ស្តីពីទេសន្តប្រវេសន៍ និងសួរសុខទុក្ខដល់កងកម្លាំងប្រចាំការនៅតាមខ្សែបន្ទាត់ព្រំដែន។ **៤**-កិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ - ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី«ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ដល់មន្ត្រីជំនាញ» តាមរយៈប្រព័ន្ធ ZOOM។

	- លោក **សុវណ្ណ ប៊ុនធឿន** ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ២០២១-២០៣០ នៅសណ្ឋាគារអង្គរប៉ារ៉ាដាយ(ANGKOR PARADISE) ខេត្តសៀមរាប ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
ខេត្តប៉ៃលិន	- លោកជំទាវ **បាន ស្រីមុំ** អភិបាល នៃគណៈអភិបាលខេត្ត បានដឹកនាំគណៈប្រតិភូមួយក្រុមអញ្ជើញ៖ **១**-ចុះត្រួតពិនិត្យ និងសិក្សាមើលទីកន្លែងដើម្បីសាងសង់រោងទទួលពលករកម្ពុជា ដែលត្រឡប់មកពីប្រទេសថៃ និងទីតាំងពិនិត្យសំណាកនៅទីស្នាក់ការក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ(ច្រកព្រំ) ព្រមទាំងអញ្ជើញចុះសួរសុខទុក្ខពលករដែលកំពុងសម្រាកធ្វើចត្តាឡីស័ក បានចំនួន ០៥លើក។ **២**-អមដំណើរដំណើរ ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អនុប្រធានគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទទួលបន្ទុកអនុគណៈកម្មការបច្ចេកទេស និងព្យាបាល ចុះពិនិត្យវឌ្ឍនភាព នៃការរៀបចំមណ្ឌលព្យាបាលកម្រិតស្រាល ត្រៀមសម្រាប់ព្យាបាលជូនបងប្អូនពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ។ - លោកស្រី **ជា លាភ** អភិបាលរង នៃគណៈអភិបាលខេត្ត បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំពិនិត្យ អំពីលទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ - លោកស្រី **ឡូញ ឈាន** អភិបាលរង នៃគណៈអភិបាលខេត្ត បានដឹកនាំក្រុមការងារចូលរួម៖ **១**-សិក្ខាសាលាពិគ្រោះយោល់ថ្នាក់ជាតិ ការពិនិត្យឡើងវិញនៅពាក់កណ្តាលអាណត្តិ នៃផែនការយុទ្ធសាស្ត្រជាតិ រយៈពេល ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ **២**-កិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីកិច្ចប្រជុំការពង្រឹងសេវាសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅមណ្ឌលទទួលពលករស្រុកកំរៀង ខេត្តបាត់ដំបង។ - បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។
